មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

Cambodian Center for Human Rights

# ស្ថានភាពនៃសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាននៅកម្ពុជា

## របាយការណ៍ប្រចាំឆ្នាំ៖ ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២១ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២

ខែវិច្ឆិកា ឆ្នាំ២០២២

## អំពីមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា («ម.ស.ម.ក») គឺជាអង្គការមិនមែនរដ្ឋាភិបាល មិនចូលបក្សសម្ព័ន្ធ និងឯករាជ្យ («អង្គការ») ដែលធ្វើការដើម្បីលើកកម្ពស់និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្សជាពិសេសសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា («កម្ពុជា»)។ ចក្ខុវិស័យរបស់ ម.ស.ម.ក គឺចង់ឃើញប្រទេសកម្ពុជាមានសន្តិភាព ដែលពលរដ្ឋគ្រប់រូបអាចអនុវត្តសិទ្ធិមនុស្សមូលដ្ឋានដែលខ្លួនមានពីកំណើតទទួលបាននីតិរដ្ឋដោយគ្មាននិទណ្ឌភាព ទទួលបានការគោរពស្មើភាពគ្នាដោយគ្មានការរើសអើងទទួលបានការពង្រឹងភាពអង់អាចក្លាហានដើម្បីចូលរួមយ៉ាងពេញលេញក្នុងដំណើរការលទ្ធិប្រជាធិបតេយ្យ ព្រមទាំងទទួលបានចំណែកនៃអត្ថប្រយោជន៍ពីការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយនិរន្តរភាពរបស់ប្រទេសកម្ពុជា។ ស្លាកសញ្ញារបស់ ម.ស.ម.ក មានរូបសត្វព្រាបស ហើរចេញពីរង្វង់មូលនៃផ្ទៃពណ៌ផ្ទៃមេឃពណ៌ខៀវដែល ជានិមិត្តរូបនៃការទាមទារសេរីភាពរបស់កម្ពុជា។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់ www.cchrcambodia.org ។

## អំពីរបាយការណ៍

របាយការណ៍នេះគឺជាលទ្ធផលរួមគ្នានៃ *គម្រោងបង្កើនការគោរពសិទ្ធិនៅកម្ពុជា* និង *គម្រោងលើកកម្ពស់និងការពារសេរីភាពខាងការបញ្ចេញមតិ និងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ*។ គម្រោងទាំងពីរនេះបានចាប់ផ្តើមនៅអំឡុងខែកញ្ញា ឆ្នាំ២០២០។ គម្រោងបង្កើនការគោរពសិទ្ធិនៅកម្ពុជា មានគោលបំណងពង្រឹង ក៏ដូចជាលើកកម្ពស់សិទ្ធិទទួលព័ត៌មាន និងសេរីភាពសារព័ត៌មាននៅកម្ពុជា។ គម្រោងលើកម្ពស់សេរីភាពខាងការបញ្ចេញមតិមានគោលបំណងពង្រីកលំហសេរីភាពខាងការបញ្ចេញមតិ និងបរិយាកាសពហុនិយម និងឯករាជ្យសម្រាប់ប្រព័ន្ធផ្សព្វផ្សាយដែលសេរី និងដើម្បីបង្កើនឱកាសសម្រាប់ប្រជាពលរដ្ឋក្នុងការចូលរួមក្នុងដំណើរការប្រជាធិបតេយ្យ និងធ្វើការសម្រេចចិត្តប្រកដដោយការទទួលបានព័ត៌មានពេញលេញ។

របាយការណ៍នេះជារបាយការណ៍ប្រចាំឆ្នាំលើកទីពីរ ដែលគម្រោងបង្កើនការគោរពសិទ្ធិនៅកម្ពុជា និងសេរីភាពខាងការបញ្ចេញមតិបានផលិតឡើង។ របាយការណ៍ដំបូងចេញផ្សាយក្នុងខែមេសា ឆ្នាំ២០២១ ដែលអាចរកបាននៅលើគេហទំព័ររបស់ ម.ស.ម.ក។

## ចម្លល់ និងមតិចូលរួម

ប្រសិនបើអ្នកមានសំណួរ ឬចង់ផ្តល់មតិចូលរួមទៅលើរបាយការណ៍នេះ សូមផ្ញើអ៊ីម៉ែលមកកាន់ ម.ស.ម.ក តាមរយៈ info@cchrcambodia.org ។ របាយការណ៍នេះ ក៏ដូចជាឯកសារបោះពុម្ពផ្សាយផ្សេងៗទៀតរបស់ ម.ស.ម.ក អាចស្វែងរកបាននៅលើគេហទំព័ររបស់ ម.ស.ម.ក. www.cchrcambodia.org ឬនៅលើគេហទំព័រសិទ្ធិមនុស្សកម្ពុជា www.sithi.org របស់ ម.ស.ម.ក ដែលទទួលបានពានរង្វាន់។

ព័ត៌មានបន្ថែម សូមទាក់ទងមកកាន់ ម.ស.ម.ក តាមរយៈអាសយដ្ឋាន៖ ផ្ទះលេខ ៧៩៨ ផ្លូវ ៩៩ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរសព្ទ៖ +៨៥៥ (០) ២៣ ៧២ ៦៩ ០១ ។

# មាតិកា


មាតិកា i

បញ្ជីអក្សរកាត់ និងពាក្យបំព្រួញ ii

វិសាលភាព និងវិធីសាស្ត្រស្រាវជ្រាវ 1

ខ្លឹមសារសង្ខេប 3

I. សេចក្តីផ្តើម 5

II. សារៈសំខាន់នៃសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាន 8

III. ក្របខណ្ឌច្បាប់ស្តីពីសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាន 11

IV. ការវិភាគផ្នែកច្បាប់ទៅលើការវិវត្តន៍នីតិបញ្ញត្តិចុងក្រោយបង្អស់ 17

V. ស្ថានភាពនៃសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាននៅកម្ពុជា 22

VI. សេចក្តីសន្និដ្ឋាន និងអនុសាសន៍ 51

VII. ឧបសម្ព័ន្ធ 54

# បញ្ជីអក្សរកាត់ និងពាក្យបំព្រួញ

| | |
|---|---|
| **កម្ពុជា** | ព្រះរាជាណាចក្រកម្ពុជា |
| **រដ្ឋធម្មនុញ្ញ** | រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រ |
| **ម.ស.ម.ក** | មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា |
| **គ.ក.ស.ក** | គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា |
| **ក.អ.ស.ព.ន** | កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ |
| **ច្បាប់អង្គការ** | ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល |
| **ក.ប.ទ** | ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| **ការិយាល័យឧត្តមស្នងការ** | ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស |
| **រដ្ឋាភិបាល** | រាជរដ្ឋាភិបាលកម្ពុជា |
| **និយតករ** | និយតករទូរគមនាគមន៍កម្ពុជា |
| **ស.ស.ស.ម** | សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស |
| **អ.ស.ប** | អង្គការសហប្រជាជាតិ |
| **យូណេស្កូ** | អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌របស់អង្គការសហប្រជាជាតិ |
| **គ.ស.ម.អ.ហ** | គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ |
| **វីអូអេ** | វិទ្យុសំឡេងសហរដ្ឋអាមេរិក |
| **វីអូឌី** | វិទ្យុសំឡេងប្រជាធិបតេយ្យ |

# វិសាលភាព និងវិធីសាស្ត្រស្រាវជ្រាវ

## *វិសាលភាព*

របាយការណ៍នេះបង្ហាញពីព័ត៌មានសំខាន់ៗពាក់ព័ន្ធនឹងសិទ្ធិសេរីភាពខាងការបញ្ចេញមតិសេរីភាពសារព័ត៌មាន សិទ្ធិទទួលព័ត៌មាន និងរបកគំហើញទាក់ទងនឹងស្ថានភាពនៃសិទ្ធិទាំងនេះនៅក្នុងព្រះរាជាណាចក្រកម្ពុជា («កម្ពុជា») ក្នុងរយៈពេលមួយឆ្នាំចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២១ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២ («អំឡុងពេលនៃរបាយការណ៍»)។ របាយការណ៍ប្រចាំឆ្នាំនេះ ផ្តោតជាពិសេសទៅលើសិទ្ធិសេរីភាពខាងការបញ្ចេញមតិរបស់អ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស ក៏ដូចជាសិទ្ធិទទួលព័ត៌មានរបស់អ្នកសារព័ត៌មាន និងសាធារណជនទូទៅនៅកម្ពុជា។

## *វិធីសាស្ត្រស្រាវជ្រាវ*

ព័ត៌មានដែលមាននៅក្នុងរបាយការណ៍នេះត្រូវបានចងក្រង ដោយប្រើប្រាស់ទិន្នន័យកត់ត្រាជាលក្ខណៈប្រព័ន្ធដែលបានមកពីប្រភពជាច្រើនផ្សេងគ្នា។ ដើម្បីធ្វើរបាយការណ៍អំពីបច្ចុប្បន្នភាពនៃសិទ្ធិសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាន ការសិក្សាស្រាវជ្រាវលើទិន្នន័យដែលមានស្រាប់ត្រូវបានធ្វើឡើងដើម្បីបង្ហាញពីក្របខណ្ឌច្បាប់អន្តរជាតិ និងច្បាប់ជាតិ ដែលពាក់ព័ន្ធនឹងសិទ្ធិទាំងនេះ។ ជាពិសេស ការស្រាវជ្រាវនេះក៏ពិនិត្យមើលឡើងវិញទៅលើការវិភាគផ្នែកច្បាប់ស្តីអំពី *អនុក្រឹតស្តីពីការគ្រប់គ្រង និងការប្រើប្រាស់ឈ្មោះដែនជាតិក្នុងប្រព័ន្ធអ៊ីនធឺណិត* («អនុក្រឹត្យស្តីពីឈ្មោះដែនជាតិ») ដើម្បីវាយតម្លៃពីភាពស្របគ្នាជាមួយបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។

ទិន្នន័យដែលបានប្រើក្នុងរបាយការណ៍នេះ ត្រូវបានប្រមូលតាមរយៈការតាមដានប្រព័ន្ធផ្សព្វផ្សាយប្រចាំថ្ងៃ និងការរាយការណ៍អំពីហេតុការណ៍ របស់គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាននៃ ម.ស.ម.ក។ ទិន្នន័យទាំងនេះ ត្រូវបានបំពេញបន្ថែមជាមួយគ្នានឹងទិន្នន័យដែលគម្រោងបង្កើនការគោរពសិទ្ធិនិងគម្រោងលើកកម្ពស់និងការពារសេរីភាពខាងការបញ្ចេញមតិ និងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យបានកត់ត្រានៅពេលចាំបាច់។ របាយការណ៍នេះក៏បានបញ្ចូលផងដែរនូវករណីសិក្សាសំខាន់ៗ ស្តីពីការរំលោភលើសេរីភាពខាងការបញ្ចេញមតិសេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាន ដែលព័ត៌មានទាំងនេះត្រូវបានប្រមូលតាមរយៈអ៊ីនធឺណិត។

បន្ថែមពីនេះ ក៏មានការសម្ភាសន៍ជាមួយអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស ដើម្បីប្រមូលនូវទស្សនៈយល់ឃើញរបស់ពួកគេលើស្ថានភាពបច្ចុប្បន្ននៃសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាន ព្រមទាំងបទពិសោធន៍ និងបញ្ហាប្រឈមក្នុងការអនុវត្តសិទ្ធិទាំងនេះ នៅពេលដែលអនុវត្តភារកិច្ចរបស់ខ្លួន។ បុគ្គលិក ម.ស.ម.ក បានសម្ភាសអ្នកសារព័ត៌មានចំនួន ១៨ នាក់ ក្នុងនោះមានស្ត្រី ០៨ នាក់ ព្រមទាំងអ្នកការពារសិទ្ធិមនុស្ស ០៥ នាក់ ក្នុងនោះមានអ្នកស្រឡាញ់ភេទដូចគ្នាចំនួនពីរនាក់។ ការសម្ភាស ត្រូវបានធ្វើឡើងទាំងដោយជួបសម្ភាសន៍ផ្ទាល់ និងតាមប្រព័ន្ធអនឡាញ។ ការសម្ភាសម្តងទៀតបានធ្វើឡើងតាមអនឡាញ ដើម្បីបញ្ជាក់ពីចម្លើយមួយចំនួនដែលបានផ្តល់ ឬដើម្បីទទួលព័ត៌មានបន្ថែម។ ឈ្មោះរបស់

អ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស និងស្ថាប័នរបស់ពួកគេត្រូវបានរក្សាជាការសម្ងាត់ តាមការស្នើសុំរបស់អ្នកដែលផ្តល់កិច្ចសម្ភាស។ ទោះយ៉ាងណា តម្លៃនៃសក្ខីកម្មទាំងនេះគឺជាទស្សនៈ និងបទពិសោធន៍ដែលពួកគេបានចែករំលែក ជាជាងការបង្ហាញអត្តសញ្ញាណ។

## ដែនកំណត់

សូមបញ្ជាក់ផងដែរថា ទិន្នន័យដែលប្រមូលបាន និងករណីដែលបានរាយការណ៍ គឺមិនមែនបង្ហាញពីស្ថានភាពទាំងស្រុងនោះទេ ព្រោះករណីនៃការរំលោភបំពានលើសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន ឬសិទ្ធិទទួលព័ត៌មានខ្លះអាចមិនត្រូវបានរាយការណ៍។

# ខ្លឹមសារសង្ខេប

សិទ្ធិសេរីភាពខាងការបញ្ចេញមតិ គឺជាសិទ្ធិដែលរួមបញ្ចូលទាំងសិទ្ធិសេរីភាពសារព័ត៌មាន និងសិទ្ធិទទួលបានព័ត៌មាន។ សិទ្ធិទាំងបីនេះគឺជាប់ទាក់ទងគ្នានិងអាស្រ័យគ្នាទៅវិញទៅមក។ សិទ្ធិទាំងនេះគឺជាមូលដ្ឋានគ្រឹះនៃសង្គមមួយប្រកបដោយសមធម៌ និងសេរី ដែលលទ្ធិប្រជាធិបតេយ្យអាចលូតលាស់ និងរីកចម្រើន។

សេរីភាពខាងការបញ្ចេញមតិ ដែលភ្ជាប់មកជាមួយសេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មានត្រូវបានការពារដោយច្បាប់ជាតិកម្ពុជា និងច្បាប់អន្តរជាតិ។ ទោះយ៉ាងណា ច្បាប់នៅកម្ពុជាបានកំណត់ឧបសគ្គជាច្រើនដល់ការអនុវត្តពេញលេញចំពោះសេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា។ ការវិវត្តន៍ផ្នែកនីតិបញ្ញត្តិ តែងប៉ះពាល់ដល់សេរីភាពខាងការបញ្ចេញមតិ ដោយសារតែការវិវត្តន៍នេះមិនអនុលោមទៅតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។ អំឡុងពេលនៃរបាយការណ៍នេះ រាជរដ្ឋាភិបាលកម្ពុជា («រដ្ឋាភិបាល») បានអនុម័ត *អនុក្រឹត្យស្ដីពីការគ្រប់គ្រងនិងការប្រើប្រាស់ឈ្មោះដែនជាតិកាលពីខែធ្នូ ឆ្នាំ២០២១។* ច្បាប់នេះមានភាពមិនច្បាស់លាស់ ហើយអាចត្រូវបានអាជ្ញាធរប្រើប្រាស់ជាឧបករណ៍មួយទៀត ដើម្បីដកហូតសេរីភាពដែលត្រូវបានរឹតត្បិតយ៉ាងធ្ងន់ធ្ងររួចស្រាប់ទៅហើយ។ ដូចគ្នានេះដែរ ខណៈដែលច្បាប់ការពារសិទ្ធិទទួលព័ត៌មានត្រូវបានលើកទឹកចិត្ត សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានរបស់រដ្ឋាភិបាលមិនបានអនុលោមទៅតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិទាំងស្រុងនោះទេ ហើយអាចនឹងទទួលបានអត្ថប្រយោជន៍ពីវិសោធនកម្មដែលនាំឱ្យច្បាប់នេះកាន់តែប្រសើរឡើងស្របតាមបទដ្ឋានអន្តរជាតិ[1]។ លើសពីនេះ រដ្ឋាភិបាលនៅតែបន្តពន្យារពេលក្នុងការអនុម័តច្បាប់នេះ បើទោះបីជាមានការអំពាវនាវពីសំណាក់សង្គមស៊ីវិលឱ្យអនុម័តច្បាប់នេះឱ្យបានឆាប់ក៏ដោយ។

ច្បាប់ដែលមានលក្ខណៈរឹតត្បិត គឺគ្រាន់តែជាឧបករណ៍មួយក្នុងចំណោមឧបករណ៍ជាច្រើនទៀតដែលរដ្ឋាភិបាលបាននិងកំពុងប្រើប្រាស់ ដើម្បីបង្ក្រាបលើសេរីភាពខាងការបញ្ចេញមតិក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ។ ការបំភិតបំភ័យ ការឃ្លាំមើល ការគំរាមកំហែង ឬការយាយីតាមប្រព័ន្ធតុលាការក៏ត្រូវបានប្រើប្រាស់ជាប្រចាំផងដែរ ដើម្បីកំណត់មុខសញ្ញាអ្នកដែលហ៊ានបញ្ចេញមតិជាមួយអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស គឺជាគោលដៅចម្បងរបស់រដ្ឋាភិបាលដែលប្រឆាំងនឹងសំឡេងរិះគន់។ សិទ្ធិសេរីភាពខាងការបញ្ចេញមតិរបស់អ្នកការពារសិទ្ធិមនុស្ស និងសេរីភាពសារព័ត៌មាន បានបន្តរងការប៉ះពាល់នៅចន្លោះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២១ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២ ដោយមានអ្នកសារព័ត៌មានយ៉ាងហោចណាស់ ២០ នាក់ និងអ្នកការពារសិទ្ធិមនុស្ស ១៣នាក់ បានទទួលរងនូវផលប៉ះពាល់ពីការបន្តគាបសង្កត់ និងរងគ្រោះដោយសារតែគោលការណ៍មិនអត់ឱនចំពោះការរិះគន់ពីសំណាក់រដ្ឋាភិបាល។ ស្រដៀងគ្នានេះដែរ កម្ពុជានៅមានកិច្ចការជាច្រើនដែលត្រូវបំពេញ មុនពេលដែលសិទ្ធិទទួលព័ត៌មានត្រូវបានប្រកាន់ខ្ជាប់យ៉ាងពេញលេញ។

---

[1] សម្រាប់សេចក្តីវិភាគពេញលេញលើសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន សូមមើលរបាយការណ៍ប្រចាំឆ្នាំរបស់ ម.ស.ម.ក ស្តីពីស្ថានភាពនៃសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាននៅកម្ពុជា, ថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ ២០២១ ដល់ថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០២២, (ម.ស.ម.ក ខែមេសា ឆ្នាំ២០២២)

របាយការណ៍នេះបង្ហាញអំពីស្ថានភាពនៃសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មានក្នុងអំឡុងពេលនេះ។ របាយការណ៍នេះផ្ទុកនូវទិន្នន័យសំខាន់ៗស្តីពីស្ថានភាពសេរីភាពខាងការបញ្ចេញមតិ ដែលបានប្រមូលក្នុងអំឡុងពេលនៃការសរសេររបាយការណ៍នេះ បានបង្ហាញនូវករណីជាច្រើននៃការឃាយីខាងផ្លូវច្បាប់លើអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស ការលុបនូវអាជ្ញាបណ្ណផ្សព្វផ្សាយមួយចំនួន និងបញ្ហាប្រឈមផ្សេងៗទៀតនៃសិទ្ធិទទួលព័ត៌មាននៅក្នុងប្រទេសកម្ពុជា។ របាយការណ៍នេះក៏មានសក្ខីកម្មរបស់អ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្សដែលបង្ហាញពីបញ្ហាប្រឈមដែលបានជួបប្រទះក្នុងពេលអនុវត្តការងារស្របច្បាប់ នៅក្នុងបរិយាកាសដែលកាន់តែមានសភាពគ្រោះថ្នាក់។

នៅក្នុងបរិបទនេះ របាយការណ៍នេះក៏ផ្តល់នូវអនុសាសន៍ដល់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីចាត់វិធានការជាក់ស្តែង ក្នុងការបំពេញកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់ខ្លួនក្នុងការការពារ និងលើកកម្ពស់សេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាននៅកម្ពុជា។

## I. សេចក្ដីផ្ដើម

សិទ្ធិសេរីភាពខាងការបញ្ចេញមតិ គឺជាសសរស្តម្ភដ៏សំខាន់នៃការរីកចម្រើនផ្នែកលទ្ធិប្រជាធិបតេយ្យ។[2] យ៉ាងណាក៏ដោយ សិទ្ធិនេះជាញឹកញាប់ រងការគាបសង្កត់នៅទូទាំងសកលលោក[3] ហើយសិទ្ធិនេះបានធ្លាក់ចុះយ៉ាងឆាប់រហ័សចាប់តាំងពីការចាប់ផ្តើមនៃជំងឺរាតត្បាតសកលកូវីដ-១៩ ក្នុងឆ្នាំ២០២០។[4] ស្រដៀងគ្នានេះដែរ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាន បានធ្លាក់ចុះយ៉ាងខ្លាំងដោយសារតែការរឹតត្បិតនៃជំងឺរាតត្បាតជាសកល។[5] ប្រការនេះបណ្តាលឱ្យមានការវាយប្រហារដែលមិនធ្លាប់មានពីមុនមកចំពោះលទ្ធិប្រជាធិបតេយ្យនៅលើពិភពលោកក្នុងឆ្នាំ២០២០[6] ហើយបានបន្តធ្លាក់ចុះដល់កម្រិតមួយទាបនៅក្នុងឆ្នាំ២០២១ ដោយភាគរយរបស់ប្រជាជននៅលើពិភពលោក ដែលរស់នៅក្នុងប្រទេសប្រជាធិបតេយ្យ មានការធ្លាក់ចុះរហូតក្រោម ៥០% ដែលជារឿងមួយគួរឱ្យព្រួយបារម្ភ។[7]

ការធ្លាក់ចុះផ្នែកសេរីភាពខាងការបញ្ចេញមតិនៅកម្ពុជាមិនមែនជារឿងថ្មីនោះទេ។ ហើយមានស្ថានភាពគួរឱ្យព្រួយបារម្ភដោយសារតែការរឹតត្បិតសេរីភាពខាងការបញ្ចេញមតិ និងការបំបិទមតិរិះគន់ ហើយការគាបសង្កត់បានកើនឡើងដោយជំងឺកូវីដ ១៩។ ចាប់តាំងពីឆ្នាំ២០១៧ មក ស្ថានភាពសិទ្ធិមនុស្សបានបន្តធ្លាក់ដុនដាបហើយលំហសង្គមស៊ីវិលកាន់តែរួមតូច ជាមួយនឹងការដៅមុខសញ្ញារបស់រដ្ឋាភិបាលចំពោះអ្នកដែលហ៊ានបញ្ចេញមតិ និងគំនិតផ្ទុយពីថ្នាក់ដឹកនាំកម្ពុជា រួមទាំងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងអ្នកការពារសិទ្ធិមនុស្ស។ របាយការណ៍ដែលទើបចេញផ្សាយដោយគម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានរបស់ ម.ស.ម.ក បង្ហាញថាសេរីភាពខាងការបញ្ចេញមតិនៅក្នុងប្រទេសកម្ពុជាតែងតែរងនូវការរារាំង រួមជាមួយនឹងការរំខានជាញឹកញាប់ចំពោះអ្នកសារព័ត៌មាន នៅពេលរាយការណ៍អំពីបញ្ហាដែលមានលក្ខណៈ"រសើប" និងការបន្តរឹតត្បិតលើការបញ្ចេញមតិស្របច្បាប់តាមប្រព័ន្ធអ៊ីនធឺណិត។[8] លើសពីនេះ សិទ្ធិទទួលព័ត៌មាននៅកម្ពុជាមិនទាន់ត្រូវបានប្រកាន់ខ្ជាប់ពេញលេញនៅឡើយ។ ការទទួលព័ត៌មានពីស្ថាប័នសាធារណៈនៅតែជាឧបសគ្គក្នុងប្រទេសមួយ

---

2 សូមមើលគណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ, "ការយល់ឃើញលើករណីរ៉ាហ្វាអែល ម៉ាក្វែអើស (Rafael Marques) ជាមួយនឹងអង់ហ្គូឡា(Angola)",(ឯកសារអង្គការសហប្រជាជាតិ, CCPR/C/83/D/ 1128/2002, ២៩ មិនា ២០០៥)កថាខណ្ឌទី ៦.៨

3 អេឌ្រៀន ហ្សាបាស (Adrian Shahbaz) និង អាល្លី ហ្វង់ (Allie Funk), "ដំណើរការសកលដើម្បីគ្រប់គ្រងបច្ចេកវិទ្យាធំទូលាយ", (ហ្វ្រីដឹមហៅវ៍, ២០២១) ។

4 អេឌ្រៀន ហ្សាបាស(Adrian Shahbaz)និងអាល្លី ហ្វង់(Allie Funk),"ស្រមោលឌីជីថលនៃជំងឺរាតត្បាត"(ហ្វ្រីដឹមហៅវ៍, ២០២០)

5 អ្នកសារព័ត៌មានគ្មានព្រំដែន "សន្ទស្សន៍សេរីភាពសារព័ត៌មានពិភពលោកឆ្នាំ ២០២១" (អ្នកសារព័ត៌មានគ្មានព្រំដែន, ២០២១)។

6 The Economist "លទ្ធិប្រជាធិបតេយ្យសកលមានឆ្នាំអាក្រក់ណាស់" (The Economist, ឆ្នាំ ២០២១) ។

7 The Economist, "លទ្ធិប្រជាធិបតេយ្យសកលមានការធ្លាក់ចុះយ៉ាងខ្លាំង" (The Economist, ៩ កុម្ភៈ ២០២២) អង្គភាពស៊ើបការណ៍សេដ្ឋកិច្ច "សន្ទស្សន៍ប្រជាធិបតេយ្យឆ្នាំ ២០២១៖ ការប្រកួតប្រជែងរបស់ប្រទេសចិន" (សន្ទស្សន៍ប្រជាធិបតេយ្យរបស់អង្គភាពស៊ើបការណ៍សេដ្ឋកិច្ចឆ្នាំ ២០២១) ទំព័រ ៣-៤ (អង្គភាពស៊ើបការណ៍សេដ្ឋកិច្ច, ២០២២) ។

8 *ម.ស.ម.ក,* "ការឃ្លាំមើលសេរីភាពមូលដ្ឋានកម្ពុជា។ របាយការណ៍ប្រចាំឆ្នាំទី ៦ ខែមករា ដល់ខែធ្នូ ឆ្នាំ ២០២១," ទំព័រ ៣១–៣៦, (ម.ស.ម.ក, ឆ្នាំ ២០២២)។

ដែលមានភាពស្រពិចស្រពិលក្នុងការគ្រប់គ្រង ហើយគណនេយ្យភាពរបស់ស្ថាប័នរដ្ឋាភិបាលហាក់មានភាពតិចតួចនៅឡើយ។

ជាលទ្ធផល ប្រទេសកម្ពុជាបានជាប់ចំណាត់ថ្នាក់លេខ ១៤២ ក្នុងចំណោម ១៨០ ប្រទេសដែលអង្គការអ្នកសារព័ត៌មានគ្មានព្រំដែនបានធ្វើការវាយតម្លៃ នៅក្នុងសន្ទស្សន៍សេរីភាពសារព័ត៌មានពិភពលោកឆ្នាំ ២០២២[9] របស់ខ្លួន ដែលចាត់ថ្នាក់ស្ថានភាពសេរីភាពសារព័ត៌មានថា «ពិបាក»។ ស្រដៀងគ្នានេះដែរ របាយការណ៍ស្តីពីសេរីភាពពិភពលោកឆ្នាំ២០២២ របស់អង្គការហ្វ្រីដឹមហៅស៍[10] បានចាត់ថ្នាក់ប្រទេសកម្ពុជាថា «មិនសេរី» ដោយបានពិន្ទុសេរីភាពជាសកល ២៤ ក្នុងចំណោម ១០០ ហើយក្នុងរបាយការណ៍ស្តីពីសេរីភាពតាមប្រព័ន្ធអ៊ីនធឺណិតឆ្នាំ២០២២ របស់ខ្លួន[11]បានចាត់ថ្នាក់ជាប្រទេសកម្ពុជាថាមាន «សេរីភាពខ្លះ» ដោយបានពិន្ទុសេរីភាពតាមប្រព័ន្ធអ៊ីនធឺណិត ៤៣ លើ ១០០។ ជាចុងក្រោយ សន្ទស្សន៍ប្រជាធិបតេយ្យឆ្នាំ២០២១ របស់អង្គភាពស៊ើបការណ៍សេដ្ឋកិច្ច[12] បានដាក់ចំណាត់ថ្នាក់ប្រទេសកម្ពុជានៅលេខរៀង ១៣៤ លើ ១៦៧ ប្រទេសដែលត្រូវបានវាយតម្លៃ ដោយចាត់ថ្នាក់ថាជា «ប្រទេសផ្តាច់ការ»។[13] សន្ទស្សន៍ប្រជាធិបតេយ្យឆ្នាំ២០២១ ក៏បានគូសបញ្ជាក់ផងដែរអំពីការធ្លាក់ចុះនៃប្រជាធិបតេយ្យនៅកម្ពុជានៅចន្លោះឆ្នាំ២០០៦ ដល់ឆ្នាំ២០២១[14] ដែលឈានទៅដល់ការធ្លាក់ចេញពីរបបកូនកាត់ទៅជារបបផ្តាច់ការក្នុងទសវត្សរ៍ចុងក្រោយនេះ។

---

[9] សន្ទស្សន៍សេរីភាពសារព័ត៌មានពិភពលោករបស់អង្គការអ្នកសារព័ត៌មានគ្មានព្រំដែន (RSF) វាយតម្លៃលើស្ថានភាពសម្រាប់អ្នកសារព័ត៌មានជារៀងរាល់ឆ្នាំនៅក្នុងប្រទេស និងដែនដីជាងមួយរយ ដោយផ្តល់ពិន្ទុលើ ១០០ ក្នុងចំណោមបណ្តាប្រទេស និងដែនដីទាំងនោះ ហើយចាត់ថ្នាក់ជាប្រភេទខុសៗគ្នា។ សន្ទស្សន៍សេរីភាពសារព័ត៌មានពិភពលោកឆ្នាំ ២០២២ ចាត់ថ្នាក់ស្ថានភាពសេរីភាពសារព័ត៌មានរបស់ប្រទេសដែលបានវាយតម្លៃជាប្រាំប្រភេទ៖ ល្អ ពេញចិត្ត មានបញ្ហា ពិបាក និងធ្ងន់ធ្ងរ។ សូមមើលសន្ទស្សន៍សេរីភាពសារព័ត៌មានពិភពលោកឆ្នាំ ២០២២ សម្រាប់ព័ត៌មានលម្អិតអំពីប្រទេសកម្ពុជា។

[10] របាយការណ៍ស្តីពីសេរីភាពពិភពលោកចេញផ្សាយដោយហ្វ្រីដឹមហៅស៍ វាយតម្លៃលើសេរីភាពសកលនៃបណ្តាប្រទេស និងដែនដីជុំវិញពិភពលោក ដោយផ្តល់ពិន្ទុលើ ១០០ ក្នុងចំណោមបណ្តាប្រទេស និងដែនដីទាំងនោះ ហើយចាត់ថ្នាក់ជាបីប្រភេទដោយផ្អែកលើពិន្ទុរបស់ខ្លួន៖ ប្រទេសសេរី សេរីខ្លះ ឬប្រទេសមិនសេរី។ សម្រាប់ព័ត៌មានលម្អិត សូមមើលរបាយការណ៍ស្តីពីសេរីភាពឆ្នាំ២០២២ របស់កម្ពុជានៅក្នុងរបាយការណ៍ប្រទេសក្នុងពិភពលោក។

[11] សេរីភាពនៅលើរបាយការណ៍សរុប គឺជាការអង្កេតប្រចាំឆ្នាំ និងការវិភាគអំពីសេរីភាពជុំវិញពិភពលោកតាមប្រព័ន្ធអ៊ីនធឺណិត ធ្វើឡើងដោយហ្វ្រីដឹមហៅស៍។ ប្រទេសដែលបានវាយតម្លៃត្រូវបានផ្តល់ពិន្ទុលើ ១០០ ហើយចាត់ថ្នាក់ជាបីប្រភេទទៅតាមពិន្ទុ៖ សេរី សេរីខ្លះ ឬមិនសេរី។ សម្រាប់ព័ត៌មានលម្អិត សូមមើលរបាយការណ៍ប្រចាំប្រទេសរបស់កម្ពុជាឆ្នាំ ២០២១ ស្តីពីសេរីភាពនៅលើពិភពលោក។

[12] សន្ទស្សន៍ប្រជាធិបតេយ្យបោះពុម្ពដោយអង្គភាពស៊ើបការណ៍សេដ្ឋកិច្ច (EIU) វាយតម្លៃលើស្ថានភាពប្រជាធិបតេយ្យនៅទូទាំងពិភពលោក។ សន្ទស្សន៍នេះផ្តល់ឱ្យប្រទេសដែលបានវាយតម្លៃ នូវមាត្រដ្ឋានពិន្ទុពីសូន្យដល់ដប់ ហើយចាត់ថ្នាក់ជាបួនប្រភេទទៅតាមពិន្ទុ៖ ប្រជាធិបតេយ្យពេញលេញ លទ្ធិប្រជាធិបតេយ្យខ្វះចន្លោះប្រហោង របបកូនកាត់ និងរបបផ្តាច់ការ។ សូមមើលសន្ទស្សន៍ប្រជាធិបតេយ្យរបស់អង្គភាពស៊ើបការណ៍សេដ្ឋកិច្ចឆ្នាំ ២០២១ ទំព័រ ៤០។

[13]សន្ទស្សន៍ប្រជាធិបតេយ្យរបស់អង្គភាពស៊ើបការណ៍សេដ្ឋកិច្ចឆ្នាំ២០២១ ទំព័រ ៣៤ ។

[14] ដូចខាងលើទំព័រ ៣៤ ។



| | | | |
|---|---|---|---|
| **សេរីភាពនៅលើពិភពលោក ឆ្នាំ ២០២២**<br>*ពិន្ទុសេរីភាពជាសកលៈ*<br>២៤/១០០<br>**មិនសេរី** | **សេរីភាពនៅលើបណ្តាញ ឆ្នាំ ២០២២**<br>*ពិន្ទុសេរីភាពតាមអ៊ីនធឺណិតៈ*<br>៤៣/១០០<br>**សេរីដោយផ្នែក** | **សេរីភាពសារព័ត៌មាននៅលើពិភពលោកឆ្នាំ ២០២២**<br>*ពិន្ទុសេរីភាពសារព័ត៌មានៈ*<br>៤៣.៤៨/១០០<br>**ស្ថានភាពពិបាក** | **សន្ទស្សន៍ប្រជាធិបតេយ្យឆ្នាំ ២០២១**<br>*ពិន្ទុប្រជាធិបតេយ្យៈ*<br>២.៩០/១០<br>**របបផ្តាច់ការ** |

## II. សារៈសំខាន់នៃសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាន

សិទ្ធិសេរីភាពខាងការបញ្ចេញមតិគឺជាចង្កោមនៃសិទ្ធិមួយដែលរួមបញ្ចូលទាំងសេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាន។ សិទ្ធិទាំងបីនេះគឺជាប់ពាក់ព័ន្ធ និងអាស្រ័យគ្នាទៅវិញទៅមក មានន័យថាគ្មានសិទ្ធិណាអាចសម្រេចបាននោះទេក្នុងករណីអវត្តមានសិទ្ធិណាមួយនោះ។ ដើម្បីបង្កើតពិភពលោកមួយកាន់តែមានសមធម៌ និងសេរី គឺជាការចាំបាច់ណាស់ដែលបុគ្គលម្នាក់ៗមានលទ្ធភាពក្នុងការបង្ហាញនូវគំនិត ការចែករំលែក និងទទួលព័ត៌មាន។ នៅពេលដែលសង្គមចូលរួមក្នុងសកម្មភាពទាំងនេះ លទ្ធិប្រជាធិបតេយ្យនឹងលូតលាស់ ហើយបទដ្ឋានសង្គម និងមនោគមវិជ្ជាដែលបង្កគ្រោះថ្នាក់នឹងថមថយ។ ការទទួលបានសិទ្ធិទាំងនេះកាន់តែមានសារៈសំខាន់ ដោយសារបច្ចេកវិទ្យាឌីជីថលបានបង្កើនល្បឿនដល់អត្រាមួយដែលធ្វើឱ្យបុគ្គល និងសង្គមមើលឃើញនិងប្រើប្រាស់ព័ត៌មាន ព្រមទាំងបញ្ចេញនូវទស្សនៈរបស់ខ្លួន។ ទោះយ៉ាងណា បច្ចេកវិទ្យាទាំងនេះក៏បានផ្តល់ឱកាសដ៏ច្រើនឱ្យរដ្ឋាភិបាលដើម្បីគាបសង្កត់ និងកាត់បន្ថយសិទ្ធិទាំងនេះដែលហាក់ដូចជាគ្មានកំណត់ទាល់តែសោះ។

### សេរីភាពខាងការបញ្ចេញមតិ

សេរីភាពខាងការបញ្ចេញមតិគ្របដណ្តប់គ្រប់ទម្រង់នៃការបញ្ចេញមតិ រួមទាំងការបញ្ចេញមតិដោយការនិយាយ សំណេរ និងមធ្យោបាយផ្សេងទៀត ដូចជាសៀវភៅ ការបង្ហោះមាតិកា បដា សោតទស្សន៍ អេឡិចត្រូនិក និងទម្រង់នៃការបញ្ចេញមតិដែលមានមូលដ្ឋានលើអ៊ីនធឺណិតជាដើម។ សេរីភាពនេះក៏រួមបញ្ចូលផងដែរនូវសិទ្ធិរបស់បុគ្គលក្នុងការចូលរួមការពិភាក្សាផ្សេងៗ រួមទាំងអំពីនយោបាយ សិទ្ធិមនុស្ស ឬសារព័ត៌មាន។[15] សេរីភាពខាងការបញ្ចេញមតិ គឺជាសសរស្តម្ភស្នូលនៃលទ្ធិប្រជាធិបតេយ្យដែលដំណើរការត្រឹមត្រូវ ប្រកបដោយបរិយាប័ន្ន និងពហុនិយម ដែលអនុញ្ញាតឱ្យបុគ្គលសម្តែងនូវមតិរបស់ខ្លួនចំពោះបញ្ហាសាធារណៈសំខាន់ៗ ព្រមទាំងអាចបដិសេធជាមួយអ្នកកាន់អំណាច និងបង្ហាញអំពើពុករលួយ ឬភាពមិនប្រក្រតី ហើយក៏ធ្វើឱ្យមានតម្លាភាពទាំងក្នុងវិស័យសាធារណៈ និងឯកជន។ នៅពេលដែលសេរីភាពខាងការបញ្ចេញមតិមិនត្រូវបានធានា ប្រជាពលរដ្ឋមិនអាចតបតនឹងរចនាសម្ព័ន្ធអំណាចរបស់រដ្ឋាភិបាល ឬស្ថាប័នសាជីវកម្មបានទេ។ សេរីភាពខាងការបញ្ចេញមតិគឺជាមូលដ្ឋានគ្រឹះសម្រាប់ការពារសិទ្ធិមនុស្សដទៃទៀតផងដែរ[16] ដូចជាសិទ្ធិសេរីភាពខាងគំនិត មនសិការ និងសាសនា សេរីភាពខាងការជួបប្រជុំ និងសេរីភាពខាងសមាគម។

[15] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ, "ពន្យល់ទូទៅលេខ ៣៤ – មាត្រា ១៩៖ សេរីភាពខាងមានមតិ និងសម្តែងមតិ", (CCPR/C/GC/៣៤, ១២ កញ្ញា ២០១១), កថាខណ្ឌទី ២, (គ.ស.ម.អ.ហ, សេចក្តីអធិប្បាយទូទៅលេខ ៣៤)។

[16] ដូចខាងលើ, កថាខណ្ឌទី ១១ និង ១២។

## សេរីភាពសារព័ត៌មាន

សារព័ត៌មានដែលសេរី អនុញ្ញាតឱ្យមានការផ្សព្វផ្សាយចំណេះដឹង ទស្សនៈ និងគំនិតនានាដែលចាំបាច់សម្រាប់បុគ្គលគ្រប់រូបដើម្បីអភិវឌ្ឍទស្សនៈ ការទទួលព័ត៌មានអំពីបញ្ហាផលប្រយោជន៍សាធារណៈ និងការសម្រេចចិត្តរបស់រដ្ឋាភិបាល និងការអនុវត្តសិទ្ធិរបស់ពួកគេ។[17] សេរីភាពសារព័ត៌មានគឺជាកត្តាចាំបាច់ ធានាដល់សេរីភាពខាងការបញ្ចេញមតិ និងការលូតលាស់ទៅនៃលទ្ធិប្រជាធិបតេយ្យ។ ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងចម្រុះ ពឹងផ្អែកលើសមត្ថភាពរបស់អ្នកសារព័ត៌មានក្នុងការស្រាវជ្រាវ ការសរសេរ និងជំនាញស៊ើបអង្កេតដែលអនុញ្ញាតឱ្យពួកគេស្វែងរកការពិត និងផ្សព្វផ្សាយព័ត៌មានសំខាន់ៗដល់សាធារណៈជន។ សកម្មភាពទាំងនេះធានាថាព័ត៌មានដែលពលរដ្ឋបានទទួលគឺអាចទុកចិត្តបាន ឯករាជ្យ និងមិនលម្អៀងដោយកត្តាផលប្រយោជន៍ណាផ្សេងឡើយ។ សារព័ត៌មានដែលសេរី មានន័យថា គ្មានប្រធានបទណាមួយត្រូវបានកម្រិតដោយសារខ្លាចការព្យាបាទឡើយ ហើយអាចផ្តល់ឱ្យប្រជាពលរដ្ឋនូវចំណេះដឹងលើបញ្ហាសង្គម នយោបាយ និងសេដ្ឋកិច្ចដែលពាក់ព័ន្ធ ហើយអនុញ្ញាតឱ្យសង្គមបង្កើតមតិលើបញ្ហាទាំងនេះ និងធ្វើការតស៊ូមតិដើម្បីការផ្លាស់ប្តូរដោយមិនភ័យខ្លាចពីផលប៉ះពាល់។

ជាងនេះទៅទៀត សារព័ត៌មានដើរតួនាទីយ៉ាងសំខាន់ក្នុងនាមជាអ្នកឃ្លាំមើលរដ្ឋាភិបាល ធានានូវតម្លាភាព និងគណនេយ្យភាព ព្រមទាំងបង្ហាញពីការរំលោភអំណាច និងកំហុសឆ្គងរបស់រដ្ឋាភិបាល។[18] បើគ្មានសេរីភាពសារព័ត៌មានទេ នឹងមានលទ្ធភាពតិចតួចសម្រាប់ការត្រួតពិនិត្យលើសកម្មភាពរបស់រដ្ឋាភិបាលដែលអាចនាំឱ្យមានការរីករាលដាលនៃអំពើពុករលួយ ភាពអយុត្តិធម៌ និងភាពជ្រុលហួសរបស់រដ្ឋាភិបាលក្នុងការជ្រៀតជ្រែកចូលក្នុងជីវិតឯកជនរបស់បុគ្គលគ្រប់រូប។ ដូចនេះ ប្រព័ន្ធផ្សព្វផ្សាយត្រូវមានលទ្ធភាពផ្សព្វផ្សាយព័ត៌មាន ឬគំនិត និងបញ្ចេញមតិដោយសេរី ដោយមិនមានការត្រួតពិនិត្យ ឬការដាក់កំហិត។

## សិទ្ធិទទួលព័ត៌មាន

ប្រជាពលរដ្ឋមានសិទ្ធិស្វែងរក និងទទួលព័ត៌មានសាធារណៈ។[19] សិទ្ធិទទួលព័ត៌មានក៏ធានាថា ប្រព័ន្ធផ្សព្វផ្សាយមានសិទ្ធិទទួលព័ត៌មានចំពោះកិច្ចការសាធារណៈឬមានសារៈសំខាន់ជាសាធារណៈ។[20] សិទ្ធិទទួលព័ត៌មានធានានូវតម្លាភាពនៃស្ថាប័នរដ្ឋាភិបាល សម្របសម្រួលការចូលរួមរបស់ប្រជាពលរដ្ឋក្នុងកិច្ចការសាធារណៈ និងបង្កើនកិច្ចសន្ទនា និងការជឿទុកចិត្តរវាងរដ្ឋាភិបាល និងសង្គម។[21] ប្រសិនបើសិទ្ធិនេះត្រូវបាន

---

[17] ក្រសួងការបរទេសន័រវេស "កិច្ចខិតខំប្រឹងប្រែងអន្តរជាតិដើម្បីលើកកម្ពស់សេរីភាពខាងការបញ្ចេញមតិ និងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ" (ក្រសួងការបរទេស, ៣០ វិច្ឆិកា ២០២០)។

[18] អង្គការសហប្រជាជាតិ "សេរីភាពសារព័ត៌មានមានសារៈសំខាន់ជាងពេលណាៗទាំងអស់ ខណៈដែលអង្គការសហប្រជាជាតិថ្កោលទោសឃាតកម្មបុគ្គលិកប្រព័ន្ធផ្សព្វផ្សាយចំនួន ៥៩ នាក់" (សារព័ត៌មានអង្គការសហប្រជាជាតិ, ២៣ ធ្នូ ២០២០)។

[19] ហ្វ្រេង ឡា រុយ (Frank La Rue), "របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីការលើកកម្ពស់ និងការពារសិទ្ធិសេរីភាពខាងមានមតិ និងសម្តែងមតិ", (UN Doc A/68/362, ៤ កញ្ញា ២០១៣), កថាខណ្ឌទី ២ ។

[20] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីពន្យល់អធិប្បាយទូទៅលេខ ៣៤ កថាខណ្ឌទី ១៨ ។

[21] អេនឌ្រូ អេចក្លេស្ទ្រោន (Andrew Ecclestone), "សំណើយុទ្ធសាស្ត្រដើម្បីសេរីភាពព័ត៌មាននៅកម្ពុជា" (កញ្ញា ២០០៨)។

កំហិត តម្លាភាពនិងគណនេយ្យភាពរបស់រដ្ឋាភិបាល ឬមន្ត្រីសាធារណៈគឺមិនមាននោះទេ ហើយការចូលរួមយ៉ាងសកម្មរបស់ប្រជាពលរដ្ឋក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្តក៏ត្រូវបានរារាំង។ លទ្ធិប្រជាធិបតេយ្យត្រូវបាន ចាក់ឫសនៅក្នុងលំហូរនៃសេរីភាពព័ត៌មាន និងគំនិត ដូច្នេះសិទ្ធិទទួលព័ត៌មានជាអ្វីដែលបែងចែករវាងរដ្ឋាភិបាលប្រជាធិបតេយ្យនិងរបបនយោបាយផ្សេងៗទៀត ដែលប្រតិបត្តិការការងាររបស់ខ្លួនដោយគេចវេសពីការទទួលខុសត្រូវ និងដោយលាក់កំបាំង។

## III. ក្របខណ្ឌច្បាប់ស្តីពីសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាន

លិខិតុបករណ៍អន្តរជាតិជាច្រើនដែលកម្ពុជាបានផ្តល់សច្ចាប័ន ធានានូវសិទ្ធិសេរីភាពខាងការបញ្ចេញមតិ និងជាតុផ្សំសំខាន់ពីរនៃសិទ្ធិនេះ។ ខណៈដែលសេរីភាពខាងការបញ្ចេញមតិគឺជាគន្លឹះមួយនៃសង្គមសេរី និងប្រជាធិបតេយ្យក៏ដោយ[22] ក៏សិទ្ធិនេះមិនមានលក្ខណៈដាច់ខាតនោះទេ ហើយអាចត្រូវបានដាក់កម្រិតក្នុងកាលៈទេសៈចង្អៀតមួយចំនួនដែលកំណត់នៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

### ៣.១. ច្បាប់អន្តរជាតិទាក់ទងនឹងសេរីភាពខាងការបញ្ចេញមតិ

| ច្បាប់អន្តរជាតិការពារសេរីភាពខាងការបញ្ចេញមតិ [23] | ច្បាប់រឹតត្បិតចំពោះសេរីភាពខាងការ បញ្ចេញមតិ |
|---|---|
| មាត្រា ១៩ (២) នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស («ស.ស.ស.ម»)៖ មនុស្សគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ រាប់បញ្ចូលទាំងសិទ្ធិស្វែងរក ការទទួល និងផ្សព្វផ្សាយព័ត៌មាន និងគំនិតនានាគ្រប់ទីកន្លែងទោះតាមរយៈមធ្យោបាយសម្តែងមតិណាមួយក៏ដោយ។<br><br>*«បុគ្គលគ្រប់រូបមានសិទ្ធិសេរីភាពខាងការមានមតិ និងការសម្តែងមតិ។ សិទ្ធិនេះរាប់បញ្ចូលទាំងសេរីភាពក្នុងការប្រកាន់មតិដោយគ្មានការជ្រៀតជ្រែក និងសេរីភាពក្នុងការស្វែងរក ការទទួល និងផ្សព្វផ្សាយព័ត៌មាន និងគំនិតនានាដោយគ្មានព្រំដែនទោះតាមរយៈមធ្យោបាយសម្តែងមតិណាមួយក៏ដោយ»។* | មាត្រា ១៩ (៣) នៃ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ អនុញ្ញាតឱ្យមានការរឹតត្បិតលើសេរីភាពខាងការបញ្ចេញមតិ ប្រសិនបើលក្ខខណ្ឌបន្ថែមចំនួនបីត្រូវបានបំពេញ។<br><br>*«ការអនុវត្តន៍ចែងក្នុងកថាខណ្ឌទី ២ [សិទ្ធិសេរីភាពខាងការបញ្ចេញមតិ និងសិទ្ធិទទួលព័ត៌មាន] តម្រូវឱ្យមានករណីយកិច្ច និងការទទួលខុសត្រូវពិសេស។ ដូច្នេះការប្រើប្រាស់សិទ្ធិនេះអាចមានការរឹតត្បិតមួយចំនួន ដែលត្រូវកំណត់ដាច់ខាតដោយច្បាប់ និងដែលចាំបាច់ដើម្បី៖ (ក) គោរពសិទ្ធិ ឬកិត្តិសព្ទរបស់អ្នកដទៃ (ខ) ការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ (សណ្តាប់ធ្នាប់សាធារណៈ) សុខភាព ឬសីលធម៌សាធារណៈ។»*<br><br>ដូច្នេះរាល់ការរឹតត្បិតណាមួយលើសេរីភាពខាងការបញ្ចេញមតិ ត្រូវតែ៖[24] |

[22]គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ, សេចក្តីពន្យល់ទូទៅលេខ ៣៤ កថាខណ្ឌទី១។

[23] បញ្ជីច្បាប់ដែលបានផ្តល់ក្នុងតារាងគឺមិនគ្រប់ដណ្តប់ទាំងស្រុងទេ។

[24] សូមមើលសេចក្តីពន្យល់លេខ ៣៤ របស់គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សូមមើលផងដែរនូវរបាយការណ៍ស្តីពីស្ថានភាពនៃសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាននៅកម្ពុជា ប្រចាំឆ្នាំ ២០២០-២០២១ របស់ ម.ស.ម.ក ទំព័រ ១២-១៤។

មាត្រា ១៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ («ក.អ.ស.ព.ន»)៖ ធានាបុគ្គលគ្រប់រូបមានសិទ្ធិសេរីភាពខាងការមានមតិ និងសម្តែងមតិ រួមទាំងសិទ្ធិក្នុងការស្វែងរក ការទទួល និងផ្សព្វផ្សាយព័ត៌មាន និងគំនិតនានាគ្រប់ទីកន្លែង និងគ្រប់ទម្រង់។

*«ជនគ្រប់រូបមានសិទ្ធិសេរីភាពខាងការបញ្ចេញមតិ។ សិទ្ធិនេះរួមមានសេរីភាពខាងការស្វែងរក ការទទួល និងការផ្សព្វផ្សាយព័ត៌មាន និងគំនិតនានា ដោយគ្មានព្រំដែន ទាំងការនិយាយ ការសរសេរ ឬការបោះពុម្ពផ្សាយ ក្នុងទម្រង់សិល្បៈ ឬតាមរយៈមធ្យោបាយសម្តែងមតិផ្សេងៗតាមជម្រើសរបស់ខ្លួន»។*

➢ ដោយសិទ្ធិសេរីភាពខាងការបញ្ចេញមតិ មានវិសាលភាពទូលំទូលាយ គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ដែលពិនិត្យមើលការអនុវត្ត ក.អ.ស.ព.ន បានអត្ថាធិប្បាយលម្អិតបន្ថែមអំពីអ្វីដែលសិទ្ធិនេះមានចែង នៅក្នុងសេចក្តីពន្យល់ទូទៅលេខ ៣៤ របស់ខ្លួន។[25]

១. **បញ្ញត្តិដោយច្បាប់៖** ច្បាប់ត្រូវតែមានភាពជាក់លាក់ និងច្បាស់លាស់គ្រប់គ្រាន់ នៅពេលកំណត់ថាតើប្រភេទនៃការបញ្ចេញមតិបែបណាត្រូវបានដាក់កម្រិត មិនត្រូវផ្តល់ការសម្រេចចិត្តដោយមិនត្រឹមត្រូវដល់អាជ្ញាធរមានសមត្ថកិច្ច និងផ្តល់ការណែនាំគ្រប់គ្រាន់ដល់អាជ្ញាធរដើម្បីឱ្យពួកគេកំណត់ដឹងថា តើការបញ្ចេញមតិប្រភេទណាត្រូវបានកម្រិត ឬអត់។ ដូច្នេះការហាមប្រាមជាទូទៅត្រូវបានហាមឃាត់។

២. **ត្រូវតែមានគោលបំណងស្របច្បាប់ក្នុងការធានានូវការគោរពសិទ្ធិ ឬកិត្តិសព្ទរបស់អ្នកដទៃ ឬការការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខ ឬសីលធម៌សាធារណៈ៖** វិធានការហាមឃាត់ការជ្រៀតជ្រែកនូវឯកជនភាពរបស់ប្រជាពលរដ្ឋ ឬការបៀតបៀន លើកេរ្តិ៍ឈ្មោះដោយខុសច្បាប់ ដូចជាការបរិហារកេរ្តិ៍ជាដើម។ ច្បាប់អនុញ្ញាត ប្រសិនបើលក្ខខណ្ឌពីរផ្សេងទៀតត្រូវបានបំពេញ។ ទោះជាយ៉ាងណា វិធានការបែបនេះមិនត្រូវគាបសង្កត់សេរីភាពខាងការបញ្ចេញមតិឡើយ។ បទបរិហារកេរ្តិ៍មិនត្រូវដាក់ទោសទណ្ឌឡើយ តាមដែលអាចធ្វើទៅបាន ហើយច្បាប់ហាមឃាត់ការបរិហារកេរ្តិ៍ ការប្រមាថ និងការគំរាមកំហែងចំពោះរាជាធិបតេយ្យ (ការប្រមាថចំពោះអង្គព្រះមហាក្សត្រ) ត្រូវតែលុបចោល។ ការហាមឃាត់ការឃោសនាណាមួយសម្រាប់សង្គ្រាម

[25] សម្រាប់ព័ត៌មានលម្អិត សូមមើលសេចក្តីពន្យល់លេខ ៣៤ របស់គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ។ សូមមើលផងដែរ "ស្ថានភាពនៃសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាននៅកម្ពុជារបស់ម.ស.ម.ក – របាយការណ៍ប្រចាំឆ្នាំចាប់ពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២០ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២១" (ម.ស.ម.ក, មេសា ២០២២), ទំព័រ ១២-១៥ (របាយការណ៍ស្តីពីសេរីភាពខាងការបញ្ចេញមតិប្រចាំឆ្នាំ ២០២០-២០២១ របស់ ម.ស.ម.ក)។

| | |
|---|---|
| **លិខិតុបករណ៍អន្តរជាតិផ្សេងទៀតដូចជា៖**<br>**• មាត្រា ៥ (viii) នៃអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់គ្រប់ទម្រង់នៃការរើសអើងពូជ សាសន៍។**<br>**• មាត្រា ២១ នៃអនុសញ្ញាស្តីពីសិទ្ធិជនពិការ**<br>**• មាត្រា ១៣ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ**<br>**• មាត្រា ១៦ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិជនជាតិដើមភាគតិច។** | ឬការញុះញង់ឱ្យមានការស្អប់ខ្ពើមជាតិសាសន៍ ពូជសាសន៍ ឬសាសនាត្រូវស្របជាមួយនឹងច្បាប់អន្តរជាតិ។<br>៣. **មានភាពចាំបាច់ជាចំខាត និងមានលក្ខណៈសមាមាត្រទៅនឹងគោលបំណងស្របច្បាប់ ដែលត្រូវសម្រេច៖** រដ្ឋត្រូវតែបង្ហាញឱ្យបានគ្រប់គ្រាន់ថាការរឹតត្បិតលើសេរីភាពខាងការបញ្ចេញមតិ ដែលខ្លួនចង់ដាក់គឺជាការចាំបាច់ដើម្បីកំណត់ពីលក្ខណៈជាក់លាក់នៃការគំរាមកំហែង ដោយបង្កើតទំនាក់ទំនងដោយផ្ទាល់ និងភ្លាមៗរវាងការបញ្ចេញមតិ និងការគំរាមកំហែង។ លើសពីនេះការរឹតត្បិតមិនអាចលើសពីអ្វីដែលចាំបាច់ ដើម្បីសម្រេចបាននូវគោលបំណងស្របច្បាប់នោះទេ។ ការរឹតត្បិតហួសហេតុ ឬការហាមឃាត់ជាទូទៅលើការផ្សព្វផ្សាយព័ត៌មាន ផ្អែកលើគំនិតមិនច្បាស់លាស់ និងមិនត្រឹមត្រូវរួមទាំង "ព័ត៌មានមិនពិត" ឬ "ព័ត៌មានលម្អៀង" គឺមិនស្របនឹងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ |

## ៣.២. ច្បាប់កម្ពុជាទាក់ទងនឹងសេរីភាពខាងការបញ្ចេញមតិ

សេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាន ក៏ត្រូវបានធានានៅក្នុងច្បាប់កម្ពុជាផងដែរ។

**ច្បាប់កម្ពុជាការពារសេរីភាពខាងការបញ្ចេញមតិ**

**រដ្ឋធម្មនុញ្ញកម្ពុជា**[26]

- **មាត្រា ៤១៖** ធានាចំពោះប្រជាពលរដ្ឋខ្មែរគ្រប់រូប នូវសិទ្ធិសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងខាងការបោះពុម្ពផ្សាយ។

> *ប្រជាពលរដ្ឋខ្មែរមានសិទ្ធិសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ និងសេរីភាពខាងការជួបប្រជុំ [...]"* ។

- **មាត្រា ៣៥៖** ធានាចំពោះប្រជាពលរដ្ឋខ្មែរទាំងពីរភេទ នូវសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ។
- **មាត្រា ៣១៖** អនុញ្ញាតឱ្យលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័នអាចអនុវត្តដោយផ្ទាល់នៅក្នុងច្បាប់ជាតិរបស់កម្ពុជា។

[26] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

នៅឆ្នាំ២០០៧ ក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជាបានបញ្ជាក់ថា បទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ដែលកម្ពុជាបានទទួលស្គាល់ អាចអនុវត្តដោយផ្ទាល់នៅក្នុងតុលាការកម្ពុជា។[27]

**ច្បាប់ស្តីពីរបបសារព័ត៌មានឆ្នាំ ១៩៩៥** [28]

- **មាត្រា ១៖** ធានាសេរីភាពសារព័ត៌មាន និងសេរីភាពនៃការបោះពុម្ពផ្សាយ ស្របតាមមាត្រា ៣១ និងមាត្រា ៤១ នៃរដ្ឋធម្មនុញ្ញកម្ពុជា។
- **មាត្រា ៣៖** ហាមឃាត់ការត្រួតពិនិត្យមុនពេលបោះពុម្ព។
- **មាត្រា ៥៖** ធានាសិទ្ធិសម្រាប់សារព័ត៌មានក្នុងការទទួលបានព័ត៌មានដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាល
- **មាត្រា ២០៖** មិនទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះការបញ្ចេញមតិ។

ទោះយ៉ាងណា ក្របខណ្ឌច្បាប់កម្ពុជាក៏មានប្បញ្ញត្តិជាច្រើនរារាំងចំពោះសិទ្ធិទាំងនេះ ដោយច្បាប់ដែលមានលក្ខណៈរឹតត្បិតកាន់តែខ្លាំងឡើង ត្រូវបានរដ្ឋាភិបាលអនុម័តក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ។ បញ្ជីច្បាប់ដែលបានរៀបរាប់ខាងក្រោមនេះ មិនគ្រប់ដណ្តប់ទាំងស្រុងនៅឡើយទេ គឺគ្រាន់តែគូសបញ្ជាក់ពីច្បាប់ទាំងឡាយដែលអាចប៉ះពាល់ដល់សេរីភាពខាងការបញ្ចេញមតិដែលប្រព័ន្ធផ្សព្វផ្សាយនិងអ្នកការពារសិទ្ធិមនុស្សអនុវត្ត។

## ច្បាប់កម្ពុជាដែលដាក់កំហិតដោយខុសច្បាប់លើសេរីភាពខាងការបញ្ចេញមតិ

**ច្បាប់ស្តីពីរបបសារព័ត៌មានឆ្នាំ ១៩៩៥**[29]

- ហាមឃាត់ការបោះពុម្ពផ្សាយស្របច្បាប់ជាច្រើន និងប្រើប្រាស់ពាក្យដែលមិនច្បាស់លាស់ ដែលនេះអាចនាំឱ្យមានការបកស្រាយយ៉ាងទូលំទូលាយ និងការចាប់ពិរុទ្ធដោយខុសច្បាប់លើប្រព័ន្ធផ្សព្វផ្សាយ។
- ផ្តល់ឱ្យរាជរដ្ឋាភិបាលកម្ពុជានូវសិទ្ធិក្នុងការរឹបអូសភ្លាមៗ និងផ្អាកការបោះពុម្ពផ្សាយជាបណ្តោះអាសន្ន ដោយគ្មានការត្រួតពិនិត្យតាមប្រព័ន្ធតុលាការ ឬគ្មានបណ្តឹងតវ៉ា ធ្វើឱ្យច្បាប់នេះក្លាយជាឧបករណ៍ដ៏មានសក្តានុពលរបស់អាជ្ញាធរក្នុងគោលដៅនយោបាយរាំងប្រព័ន្ធផ្សព្វផ្សាយ ។

[27] សេចក្តីសម្រេចលេខ ០៩២/០០៣/២០០៧ របស់ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ១០ កក្កដា ២០០៧) ទំព័រ ២៖ "ពាក្យ "ច្បាប់" ដូចយោងខាងលើ មានន័យថា ច្បាប់ជាតិ រួមទាំងរដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូល ច្បាប់ទាំងអស់ដែលនៅជាធរមាន និងច្បាប់អន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាបានទទួលស្គាល់រួចជាស្រាប់"។
[28] ច្បាប់ស្តីពីរបបសារព័ត៌មាន។ នៅឆ្នាំ២០១៩ ក្រសួងព័ត៌មានបានប្រកាសថាបានចាប់ផ្តើមពិនិត្យច្បាប់ស្តីពីរបបសារព័ត៌មានដើម្បីឱ្យមាត្រាមួយចំនួន "ស្របតាមស្ថានភាពបច្ចុប្បន្ន និងតម្រូវការរបស់ប្រទេស"។ ច្បាប់នេះនៅតែស្ថិតក្រោមការកែសម្រួលរហូតមកដល់ពេលនេះ។ សូមមើល វួន ដារ៉ា "រដ្ឋាភិបាលធ្វើវិសោធនកម្មច្បាប់ស្តីពីរបបសារព័ត៌មាន ដើម្បីឱ្យស្របតាមការពិតបច្ចុប្បន្នពិតប្រាកដ", (ភ្នំពេញប៉ុស្តិ៍, ០៦ ឧសភា ២០១៩) និង "ការពិនិត្យមើលច្បាប់ស្តីពីរបបសារព័ត៌មានចាប់ផ្តើម" (ភ្នំពេញប៉ុស្តិ៍, ២៧ សីហា ២០១៩)
[29] សម្រាប់ការវិភាគលម្អិតបន្ថែមទៀតលើច្បាប់សារព័ត៌មាន សូមមើល "កំណត់ចំណាំសង្ខេបស្តីពីបទប្បញ្ញត្តិប្រព័ន្ធផ្សព្វផ្សាយ និងសេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា" របស់ ម.ស.ម.ក (ម.ស.ម.ក, កុម្ភៈ ២០១៤)។

- បង្កើតនីតិវិធីផ្ដល់អាជ្ញាបណ្ណសម្រាប់សារព័ត៌មានដែលគ្រប់គ្រងទាំងស្រុងដោយរាជរដ្ឋាភិបាលកម្ពុជា ហើយដែលផ្ដល់ឱ្យក្រសួងព័ត៌មាន នូវអំណាចគ្មានដែនកំណត់ក្នុងការផ្ដល់ និងដកហូតអាជ្ញាបណ្ណផ្សព្វផ្សាយ ដោយគ្មានយន្តការត្រួតពិនិត្យឯករាជ្យណាមួយឡើយ។
- ផ្ដល់បញ្ជីមិនពេញលេញនៃករណីលើកលែងចំពោះសិទ្ធិទទួលព័ត៌មានដែលមាននៅក្នុងកំណត់ត្រាក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាលដោយមិនមានយន្តបណ្ដឹងសម្រាប់ការស្នើសុំព័ត៌មានដែលត្រូវបានបដិសេធដោយរដ្ឋាភិបាល។

**ច្បាប់ស្ដីពីទូរគមនាគមន៍ឆ្នាំ ២០១៥ និង ប្រកាសស្ដីពីការគ្រប់គ្រងការផ្សព្វផ្សាយតាមគេហទំព័រ និងបណ្ដាញទំនាក់ទំនងសង្គមឆ្នាំ២០១៨[30]**

- ច្បាប់ស្ដីពីទូរគមនាគមន៍ បានរៀបចំឱ្យមានការឃ្លាំមើលការបញ្ចេញមតិតាមប្រព័ន្ធអនឡាញ បង្កើតជាបទល្មើសព្រហ្មទណ្ឌជាបន្តបន្ទាប់ទាក់ទងនឹងការប្រើប្រាស់ឧបករណ៍ទូរគមនាគមន៍ និងត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារ និងការផាកពិន័យជាប្រាក់យ៉ាងធ្ងន់ធ្ងរ ដែលបណ្ដាលឱ្យមានផលប៉ះពាល់យ៉ាងខ្លាំងដល់ការបញ្ចេញមតិតាមរយៈបណ្ដាញទូរគមនាគមន៍។[31]
- ប្រកាសចុះឆ្នាំ២០១៨ ស្ដីពីការគ្រប់គ្រង ការផ្សព្វផ្សាយតាមគេហទំព័រ និងបណ្ដាញទំនាក់ទំនងសង្គមបានពង្រីកយ៉ាងទូលំទូលាយនូវអំណាចលើសលប់ដល់រដ្ឋាភិបាលដើម្បីតាមដានទំនាក់ទំនងទូរគមនាគមន៍ រួមទាំងការប្រើប្រាស់អ៊ីនធឺណេត។ អ្វីដែលគួរឱ្យកត់សម្គាល់គឺថាប្រកាសនេះផ្ដល់សិទ្ធិអំណាចដល់ស្ថាប័ននីតិប្រតិបត្តិ ក្នុងការគ្រប់គ្រងព័ត៌មានដែលផ្សព្វផ្សាយនៅលើអ៊ីនធឺណិត និងបិទទំព័រប្រព័ន្ធផ្សព្វផ្សាយសង្គម ឬគេហទំព័រ ដែលនេះធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សេរីភាពខាងការបញ្ចេញមតិតាមប្រព័ន្ធអនឡាញ។

**ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩[32]**

- បទប្រមាថចំពោះអង្គព្រះមហាក្សត្រ ដែលត្រូវបានបញ្ចូលក្នុងឆ្នាំ ២០១៨ (មាត្រា ៤៣៧-ស្ទួន) ហាមឃាត់បុគ្គលពីការបរិហារកេរ្តិ៍ ប្រមាថ ឬគំរាមកំហែងព្រះមហាក្សត្រ តាមគ្រប់មធ្យោបាយនៃការបញ្ចេញមតិ។[33]
- មាត្រា ៣០៥ និង ៣០៦ ដាក់ទោសចំពោះបទបរិហារកេរ្តិ៍
- មាត្រា ៤៩៤ ដល់ ៤៩៧ ដែលផ្ដន្ទាទោសចំពោះបទញុះញង់ មាត្រា ៥០២ ដែលដាក់ទោសចំពោះបទប្រមាថ ត្រូវបានប្រើជាប្រចាំដើម្បីបំបិទសំឡេងឯករាជ្យនិងរិះគន់នៅក្នុងប្រទេសកម្ពុជា។

---

30 ច្បាប់ស្ដីពីទូរគមនាគមន៍ ប្រកាសលេខ ១៧០ ប្រក/អន្តរ ស្ដីពី 'ការត្រួតពិនិត្យការចុះផ្សាយតាមគេហទំព័រ និងដំណើរការប្រព័ន្ធផ្សព្វផ្សាយសង្គមតាមរយៈអ៊ីនធឺណិតក្នុងព្រះរាជាណាចក្រកម្ពុជា' (២៨ ឧសភា ២០១៨)។

31 សម្រាប់ព័ត៌មានលម្អិត សូមមើល "ការការពារសេរីភាពមូលដ្ឋានរបស់ម.ស.ម.ក៖ ការពិនិត្យមើលទិន្នន័យតាមច្បាប់ក្នុងស្រុក និងការអនុលោមតាមច្បាប់អន្តរជាតិ" (*ម.ស.ម.ក,* ធ្នូ ២០១៩) ទំព័រ ៣៧ សូមមើលផងដែរ "ច្បាប់ស្ដីពីទូរគមនាគមន៍កម្ពុជា៖ ការវិភាគផ្នែកច្បាប់" របស់អង្គការលីកាដូ (លីកាដូ មីនា ២០១៦) ទំព័រ ១-២។

32 ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

33 សម្រាប់ព័ត៌មានលម្អិត សូមមើល "កំណត់ត្រាសង្ខេបរបស់ ម.ស.ម.ក៖ ក្រមព្រហ្មទណ្ឌក្នុងបទបរិហារកេរ្តិ៍ និងសេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា" (ម.ស.ម.ក, ឧសភា ២០១៤)។

**ច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្នឆ្នាំ ២០២០**[34]

- មាត្រា ៥ (១១) រឹតត្បិតសិទ្ធិទទួលព័ត៌មាន ដោយផ្តល់អំណាចដល់រដ្ឋាភិបាល «ហាមឃាត់ ឬរឹតត្បិតការចែករំលែកព័ត៌មាន ឬប្រព័ន្ធផ្សព្វផ្សាយ» ដែលអាចរារាំងការរាយការណ៍ប្រកបដោយតម្លាភាព។ ច្បាប់នេះក៏បានផ្តល់អំណាចបន្ថែមដល់អាជ្ញាធរ ក្នុងការហាមឃាត់ការមានមតិ ឬសម្តែងមតិដែលអាច «ធ្វើឱ្យប្រជាពលរដ្ឋមានការភិតភ័យ ឬចលាចល ឬនាំឱ្យខូចខាតដល់សន្តិសុខជាតិ» ឬអាច «បណ្តាលឱ្យមានការភ័ន្តច្រឡំ» ក្នុងចំណោមសាធារណជន ដោយសារកោរឹតត្បិតនេះគឺមានលក្ខណៈទូលំទូលាយពេក ហើយផ្ទុយនឹងមាត្រា ៤ នៃ ក.អ.ស.ព.ន ។

**អនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ («អនុក្រឹត្យស្តីពីច្រកទ្វារអ៊ីនធឺណិតជាតិ»)**[35]

- អនុក្រឹត្យច្រកទ្វារអ៊ីនធឺណិតជាតិ ដែលគ្រោងនឹងដាក់ឱ្យអនុវត្តក្នុងពេលខាងមុខ នឹងតម្រូវឱ្យបណ្តាញទំនាក់ទំនង និងទិន្នន័យអ៊ីនធឺណិតណាមួយ ឬទាំងអស់ ទាំងក្នុងស្រុកនិងក្រៅស្រុក ដែលត្រូវឆ្លងកាត់ច្រកទ្វារអ៊ីនធឺណិតជាតិជាមុនសិន មុននឹងបញ្ជូនទៅកាន់អ្នកប្រើប្រាស់ចុងក្រោយ។ ច្រកទ្វារអ៊ីនធឺណិតជាតិជាពិសេសមាត្រា ៦ នៃអនុក្រឹត្យនេះមិនបំពេញតាមលក្ខខណ្ឌទាំងបីរបស់មាត្រា ១៩ (៣) នៃ ក.អ.ស.ព.ន ហើយមានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះសេរីភាពខាងការបញ្ចេញមតិ និងសិទ្ធិផ្សេងទៀតនៅក្នុងប្រទេសកម្ពុជា។[36]

---

[34] សម្រាប់ព័ត៌មានលម្អិត សូមមើល " របាយការណ៍ប្រចាំឆ្នាំទីប្រាំសម្រាប់ខែមេសា ដល់ខែធ្នូ ឆ្នាំ ២០២០ ស្តីពីការឃ្លាំមើលសេរីភាពមូលដ្ឋាននៅកម្ពុជា" របស់ *ម.ស.ម.ក,* (ម.ស.ម.ក), ទំព័រ ២០-២១។

[35] អនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ។

[36] សម្រាប់ព័ត៌មានលម្អិត សូមមើល "របាយការណ៍ប្រចាំឆ្នាំទីប្រាំពីខែមេសា ដល់ខែធ្នូ២០២០ ស្តីពីការឃ្លាំមើលសេរីភាពមូលដ្ឋាននៅកម្ពុជា" របស់ម.ស.ម.ក (ម.ស.ម.ក), ទំព័រ ២០–២១ សូមមើលផងដែរនូវរបាយការណ៍ស្តីពីសេរីភាពខាងការបញ្ចេញមតិប្រចាំឆ្នាំ ២០២០-២០២១ របស់ ម.ស.ម.ក។

## IV. ការវិភាគផ្នែកច្បាប់នៅលើការវិវត្តន៍នីតិបញ្ញត្តិចុងក្រោយបង្អស់

*អនុក្រឹត្យស្តីពីការគ្រប់គ្រងនិងការប្រើប្រាស់ឈ្មោះដែនជាតិក្នុងប្រព័ន្ធអ៊ីនធឺណិត* («អនុក្រឹត្យ») ដែលត្រូវបានអនុម័តនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ បង្កការគំរាមកំហែង ដល់សេរីភាពខាងការបញ្ចេញមតិ។

ឈ្មោះឌូមែនគឺជាអាសយដ្ឋានតែមួយគត់នៃគេហទំព័រដែលភ្ជាប់ជាមួយអាសយដ្ឋាន ពិធីការអ៊ីនធឺណិត (IP)។[37] ឈ្មោះឌូមែនជាធម្មតា មានភាពងាយស្រួលចងចាំដែលជួយដល់អ្នកប្រើប្រាស់អ៊ីនធឺណិតក្នុងការស្វែងរកគេហទំព័របានយ៉ាងងាយស្រួល។ ឈ្មោះគេហទំព័រនិងផ្នែកបន្ថែម(ដូចជា .com ឬ .net) ហៅថាដែនកម្រិតកំពូល (TLD)។ TLDs ដែលភ្ជាប់ជាមួយប្រទេសមួយ (ដូចជា .fr សម្រាប់ប្រទេសបារាំង ឬ .kh សម្រាប់ប្រទេសកម្ពុជា) ត្រូវបានគេហៅថាអក្សរសម្គាល់ប្រទេស TLDs (ccTLDs) ឬដែនជាតិ។ រដ្ឋាភិបាលនៃប្រទេសដែល ccTLD តំណាងមិនតម្រូវឱ្យចូលរួមជាផ្លូវការក្នុងការគ្រប់គ្រង ccTLD នោះទេ ប៉ុន្តែអាចធ្វើបាន។[38] អក្សរសម្គាល់ប្រទេសកម្ពុជាគឺ .kh ត្រូវបានគ្រប់គ្រងដោយនិយតករទូរគមនាគមន៍កម្ពុជា («និយតករ»)។[39] ទោះបីជានៅក្នុងគេហទំព័ររបស់និយតករ លើកឡើងថាខ្លួនជា «ស្ថាប័នឯករាជ្យ» ក៏ដោយ ប៉ុន្តែឈ្មោះដែន gov.kh របស់ខ្លួនកំណត់ថាជាស្ថាប័នរដ្ឋាភិបាល។[40] យោងតាមសាជីវកម្មអ៊ីនធឺណិត សម្រាប់ការកំណត់ឈ្មោះ និងលេខការគ្រប់គ្រង ccTLD គឺស្ទើរតែជាបញ្ហាក្នុងស្រុកទាំងស្រុង ស្របតាមគោលការណ៍នៃក្រុមហ៊ុនបុត្រសម្ព័ន្ធ។[41] ទោះយ៉ាងណា រដ្ឋាភិបាលត្រូវតែគោរពតាមកាតព្វកិច្ចសិទ្ធិមនុស្សក្នុងស្រុកនិងអន្តរជាតិរបស់ខ្លួននៅពេលអនុម័តច្បាប់ ឬអនុវត្តការសម្រេចដែលប៉ះពាល់ដល់ការគ្រប់គ្រង ccTLDs ។[42]

អនុក្រឹត្យនេះកំណត់យកក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍(«ក្រសួងប្រៃសណីយ៍») និងនិយតករជាអាជ្ញាធរពីរដែលទទួលបន្ទុកគ្រប់គ្រង និងនិយតកម្មលើការប្រើប្រាស់ឈ្មោះដែនជាតិ។ អនុក្រឹត្យនេះកំណត់ថាតើឈ្មោះដែនជាតិអ្វីអាចត្រូវបានប្រើប្រាស់ និងនិយតកម្មលើការប្រើប្រាស់ឈ្មោះដែនជាតិ ហើយតម្រូវឱ្យអង្គភាពមួយចំនួនចុះបញ្ជីឈ្មោះដែនរបស់ខ្លួន។ វិធានដែលមានចែងក្នុងអនុក្រឹត្យនេះ ហាក់ដូចជារឹតត្បិតលើសេរីភាពខាងការបញ្ចេញមតិ។

---

[37] ឌូម៉ានថាស ជី. (Domantas G.) និងហាស្នា អេ. (Hasna A.), "តើអ្វីជាឈ្មោះដែន? មគ្គុទ្ទេសក៍កម្រិតដំបូង" (Hostinger) ។

[38] សាជីវកម្មអ៊ីនធឺណិតកំណត់ឈ្មោះ និងលេខ (ICANN), "សំណួរដែលសួរញឹកញាប់អំពីដែនកម្រិតកំពូលនៃកូដសម្គាល់ប្រទេស", (ICANN), ទំព័រ ៤ (សំណួរដែលសួរញឹកញាប់របស់ ICANN អំពីដែនកម្រិតកំពូលនៃកូដសម្គាល់ប្រទេស) ICNL, ការវិភាគផ្នែកច្បាប់លើអនុក្រឹត្យស្តីពីឈ្មោះដែនជាតិរបស់កម្ពុជា (២២ មិថុនា ២០២២)។

[39] អាជ្ញាធរកំណត់ក្រុមលេខតាមអ៊ីនធឺណិត "មូលដ្ឋានទិន្នន័យតំបន់ជាឫសគល់", (INANA) ICNL, ការវិភាគផ្លូវច្បាប់នៃអនុក្រឹត្យរបស់កម្ពុជាស្តីពីឈ្មោះដែនជាតិ (២២ មិថុនា ២០២២)។

[40] សូមមើលមាត្រា ៥.គ នៃអនុក្រឹត្យ។ គេហទំព័ររបស់និយតករទូរគមនាគមន៍កម្ពុជា៖ https://trc.gov.kh/en/ ។

[41] សំណួរដែលសួរញឹកញាប់របស់ ICANN អំពីអំពីដែនកម្រិតកំពូលនៃកូដសម្គាល់ប្រទេស ទំព័រ ៥ ។

[42] ICNL, ការវិភាគផ្នែកច្បាប់លើអនុក្រឹត្យរបស់កម្ពុជាស្តីពីឈ្មោះដែនជាតិ (២២ មិថុនា ២០២២)។

| លក្ខខណ្ឌបីនៃមាត្រា ១៩ នៃ ក.អ.ស.ព.ន | | |
|---|---|---|
| ដើម្បីឱ្យមានភាពស្របច្បាប់តាមបទដ្ឋានអន្តរជាតិ ការរឹតត្បិតលើសេរីភាពខាងការបញ្ចេញមតិត្រូវ៖ | | |
| **លក្ខខណ្ឌទី១.** ចែងដោយច្បាប់ (**តម្រូវការនីត្យានុកូល**) | **លក្ខខណ្ឌទី២.** អនុវត្តតាមគោលបំណងច្បាប់កំណត់ (**លក្ខខណ្ឌតម្រូវនៃគោលបំណងស្របច្បាប់**) | **លក្ខខណ្ឌទី៣. ចាំបាច់**ក្នុងសង្គមប្រជាធិបតេយ្យ និងសមាមាត្រនឹងគោលបំណងច្បាប់ (**តម្រូវការចាំបាច់និងសមាមាត្រ**) |

### *កង្វះភាពច្បាស់លាស់ថាតើអង្គភាពណាដែលត្រូវចុះបញ្ជីឈ្មោះដែនជាតិ*

មាត្រា ៧ នៃអនុក្រឹត្យនេះចែងថា *«នីតិបុគ្គលដែលបានចុះបញ្ជីក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវផ្តល់អាសយដ្ឋានអេឡិចត្រូនិកដែលមានឈ្មោះដែនជាតិ [...] តាមការប្រកាសប្រចាំឆ្នាំទាក់ទងនឹងស្ថានភាពរបស់ក្រុមហ៊ុននៅក្រសួងពាណិជ្ជកម្ម»។* មាត្រានេះចង្អុលបង្ហាញថា នីតិបុគ្គលដែលចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម មានន័យថាក្រុមហ៊ុនស្វែងរកប្រាក់ចំណេញ[43] ដែលតម្រូវឱ្យមានឈ្មោះដែនជាតិ និងចុះបញ្ជី។ ទោះយ៉ាងណា លក្ខខណ្ឌតម្រូវនេះដែលអនុវត្តចំពោះអង្គភាពផ្សេងទៀត គឺមិនមានភាពច្បាស់លាស់ទេ។

មាត្រា ៦ ចែងថា *«ក្រសួង និងស្ថាប័នរដ្ឋាភិបាលដែលមានបំណងប្រើប្រាស់ឈ្មោះដែនជាតិ [...] ត្រូវដាក់ពាក្យស្នើសុំមកនិយតករ»* ។ ការប្រើប្រាស់ពាក្យ «មានបំណង» បង្ហាញថា ការមានឈ្មោះដែនជាតិ មិនមែនជាកាតព្វកិច្ចចំពោះក្រសួង និងស្ថាប័នរដ្ឋាភិបាលនោះទេ។ ទោះយ៉ាងណា មាត្រា ២២ ហាក់ដូចជាបង្ហាញផ្ទុយពីនេះ ព្រោះបានតម្រូវឱ្យក្រសួង និងស្ថាប័នរដ្ឋាភិបាលដែលកំពុងប្រើប្រាស់ឈ្មោះដែនផ្សេងទៀត ផ្លាស់ប្តូរឈ្មោះទៅជាឈ្មោះដែនជាតិក្នុងរយៈពេលដប់ពីរខែបន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន។[44]

ចំពោះអង្គភាពនានាក្រៅពីក្រុមហ៊ុនស្វែងរកប្រាក់ចំណេញ ក្រសួងនិងស្ថាប័នរដ្ឋាភិបាល ហាក់ដូចជាត្រូវបានគ្របដណ្តប់ក្រោមមាត្រា ៩ ដែលចែងថា *«បុគ្គលដែលមានបំណងប្រើប្រាស់ឈ្មោះដែនជាតិ អាចដាក់ពាក្យស្នើសុំមកនិយតករ តាមរយៈប្រព័ន្ធស្វ័យប្រវត្តិ ឬជាមួយមន្ត្រីចុះបញ្ជី»។* ជាថ្មីម្តងទៀត ការប្រើប្រាស់ពាក្យ «មានបំណង» ប្រហែលជាកំហុសឆ្គងដូចជាចំពោះក្រសួង និងស្ថាប័នរដ្ឋាភិបាល ចង្អុលបង្ហាញថា ការមានឈ្មោះដែនជាតិមិនមែនជាកាតព្វកិច្ចចំពោះអង្គភាពផ្សេងទៀតទាំងនេះទេ។ ការប្រើប្រាស់ភាសាដែលច្បាស់លាស់ជាងនេះជាការចាំបាច់ ដើម្បីធានាថាអនុក្រឹត្យនេះមិនបើកចំហឱ្យមានការបកស្រាយផ្សេងៗ ហើយមិន

---

[43] បញ្ជីឈ្មោះអង្គការសង្គមស៊ីវិល ("អង្គការសង្គមស៊ីវិល") នៅក្រសួងមហាផ្ទៃ ខណៈប្រភេទនីតិបុគ្គលផ្សេងទៀតចុះបញ្ជីនៅក្រសួងផ្សេងទៀត។

[44] មាត្រា ២២ នៃអនុក្រឹត្យ៖ *"គ្រប់ក្រសួង និងស្ថាប័នរដ្ឋាភិបាល ដែលប្រើប្រាស់ឈ្មោះដែនផ្សេងទៀត និង/ឬកំពុងរក្សាទុកទិន្នន័យនៅក្រៅព្រះរាជាណាចក្រកម្ពុជា ត្រូវប្តូរមកប្រើឈ្មោះដែនជាតិ និងផ្ទេរទិន្នន័យមករក្សាទុកក្នុងព្រះរាជាណាចក្រកម្ពុជាក្នុងរយៈពេល ១២ (ដប់ពីរ) ខែបន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន លើកលែងតែកំណត់ផ្សេងទៀតដោយរដ្ឋាភិបាល"។*

មែនអនុវត្តដោយអាជ្ញាធរតាមតែអំពើចិត្ត ឬដោយមិនស៊ីសង្វាក់គ្នានោះឡើយ។[45] បច្ចុប្បន្ន អនុក្រឹត្យនេះមិនមានភាពច្បាស់លាស់គ្រប់គ្រាន់ អាចឱ្យអង្គភាពក្រៅពីក្រុមហ៊ុនស្វែងរកប្រាក់ចំណេញ ក្រសួង និងស្ថាប័នរដ្ឋាភិបាលយល់ថាតើមានការតម្រូវឱ្យពួកគេចុះបញ្ជីឈ្មោះដែនជាតិដែរឬអត់នោះទេ។

### *អនុក្រឹត្យនេះរឹតត្បិតលើសេរីភាពខាងការបញ្ចេញមតិ ដោយហាមប្រាមមាតិកាគេហទំព័រ*

ការណ៍ដែលក្រុមហ៊ុនស្វែងរកប្រាក់ចំណេញ ក្រសួង និងស្ថាប័នរដ្ឋាភិបាល និងអាចជាអង្គភាពផ្សេងទៀត ដូចជាសមាគម អង្គការ និងសហជីព ត្រូវបានតម្រូវឱ្យចុះបញ្ជីដែនជាតិ មានន័យថា ក្នុងនាមជាមន្ត្រីចុះបញ្ជី ត្រូវមានកាតព្វកិច្ចដូចបានចែងនៅក្នុងអនុក្រឹត្យនេះ។ កាតព្វកិច្ចទាំងនេះរឹតត្បិតលើសមត្ថភាពរបស់ពួកគេក្នុងការចែកចាយព័ត៌មាន ដែលជាធាតុផ្សំសំខាន់នៃសេរីភាពខាងការបញ្ចេញមតិ ហើយហាក់ដូចជាមិនអនុលោមតាមបទដ្ឋានអន្តរជាតិជុំវិញសេរីភាពខាងការបញ្ចេញមតិ។

មាត្រា ១១ នៃអនុក្រឹត្យចែងថា អង្គភាពដែលបានចុះបញ្ជីឈ្មោះដែនមិនអាចប្រើប្រាស់ដើម្បីផ្សព្វផ្សាយព័ត៌មានដែលប៉ះពាល់ដល់ *«វប្បធម៌ សីលធម៌ ប្រពៃណី ទំនៀមទម្លាប់ សិទ្ធិបុគ្គល សិទ្ធិអ្នកប្រើប្រាស់ផលប្រយោជន៍ស្របច្បាប់សាធារណៈ សន្តិសុខជាតិ [និង...] សណ្តាប់ធ្នាប់សង្គម»* ដែលប្រៀបបាននឹងការរឹតត្បិតលើសេរីភាពខាងការបញ្ចេញមតិ។ ពាក្យថា *«វប្បធម៌ សីលធម៌ ប្រពៃណី ទំនៀមទម្លាប់ សិទ្ធិបុគ្គល សិទ្ធិអ្នកប្រើប្រាស់ ផលប្រយោជន៍ស្របច្បាប់សាធារណៈ [និង...] សណ្តាប់ធ្នាប់សង្គម»* មានលក្ខណៈអត្តនោម័តយ៉ាងខ្លាំង ធ្វើឱ្យមន្ត្រីចុះបញ្ជីមានការលំបាកយល់ច្បាស់ថាតើខ្លឹមសារអ្វីនឹងបំពានលើមាត្រា ១១ និង រារាំងពួកគេបន្ថែមទៀតក្នុងការបំពេញកិច្ច ដើម្បីធានាថាស្របទៅតាមកាតព្វកិច្ចរបស់ខ្លួនក្នុងនាមជាមន្ត្រីចុះបញ្ជី។ ចំពោះអំណះអំណាងជាក់លាក់នៃពាក្យ *«សន្តិសុខជាតិ»* ក្រុមប្រឹក្សាសិទ្ធិមនុស្សបានបញ្ជាក់យ៉ាងច្បាស់ថា *«ការបញ្ជាក់មិនច្បាស់លាស់ និងទូលំទូលាយ ដូចជាសេចក្តីយោងដែលមិនជាក់លាក់ចំពោះ «សន្តិសុខជាតិ» មិនមានលក្ខណៈគ្រប់គ្រាន់ជាច្បាប់ច្បាស់លាស់គ្រប់គ្រាន់នោះទេ។*[46] ដូច្នេះ មាត្រា ១១ មិនបានបំពេញតាមលក្ខខណ្ឌតម្រូវទីមួយនៃលក្ខខណ្ឌទាំងបីនៃមាត្រា ១៩ ដែលចែងថាច្បាប់ដែលដាក់ការរឹតត្បិតលើសេរីភាពខាងការបញ្ចេញមតិ ត្រូវបំពេញតាមកម្រិតជាក់លាក់នៃភាពច្បាស់លាស់។ ដោយពិចារណាលើភាពទូលំទូលាយ និងភាពមិនច្បាស់លាស់នៃលក្ខខណ្ឌទាំងនេះ ខ្លឹមសារស្ទើរតែទាំងស្រុង រួមទាំងខ្លឹមសារដែលគ្មានន័យ អាចត្រូវបានចាត់ទុកថាប៉ះពាល់ដល់ *«វប្បធម៌ សីលធម៌ ប្រពៃណី ទំនៀមទម្លាប់ សិទ្ធិបុគ្គល សិទ្ធិអ្នកប្រើប្រាស់ផលប្រយោជន៍ស្របច្បាប់សាធារណៈ សន្តិសុខជាតិ ឬសណ្តាប់ធ្នាប់សង្គម»។* ដូច្នេះ មាត្រា ១១ អនុញ្ញាតឱ្យរដ្ឋាភិបាលតាមរយៈអាជ្ញាធរទូរគមនាគមន៍ ធ្វើការសម្រេចតាមអំពើចិត្ត នៅពេលដែលឈ្មោះដែនជាតិត្រូវបាន

[45] តម្រូវការនូវភាពច្បាស់លាស់ថាតើអង្គភាពណាខ្លះដែលត្រូវចុះបញ្ជីឈ្មោះដែនជាតិ ត្រូវបានបង្ហាញយ៉ាងច្បាស់ថា ទោះបីជាភាសាដែលបានប្រើក្នុងអនុក្រឹត្យកំណត់ថាការចុះបញ្ជិកាមិនមែនជាកាតព្វកិច្ចចំពោះបណ្តាអង្គភាពក្រៅពីសហគ្រាសរកប្រាក់ចំណេញក៏ដោយ ប៉ុន្តែក្រសួង និងស្ថាប័នរដ្ឋាភិបាលដែលបានសម្ភាសដោយ ICNL បង្ហាញថា អង្គការសង្គមស៊ីវិលជាច្រើនត្រូវបានមន្ត្រីប្រាប់ឱ្យមានឈ្មោះដែនជាតិ និងតម្រូវឱ្យចុះបញ្ជីឈ្មោះមួយ។

[46] ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ "សិទ្ធិឯកជនភាពក្នុងយុគសម័យឌីជីថល" (A/HRC/39/39, ៣ សីហា ២០១៨), កថាខណ្ឌទី ៣៥ ។

ប្រើប្រាស់ដោយហេតុផលមិនត្រឹមត្រូវ និងដាក់ទណ្ឌកម្មចំពោះអង្គភាពណាដែលប្រើប្រាស់ឈ្មោះដែនជាតិទាំងនេះ ដោយបំពានលើសេរីភាពខាងការបញ្ចេញមតិ។

មាត្រា ១៥ ដែលមានខ្លឹមសារស្របគ្នានឹងមាត្រា ៤ ចែងថា ការខកខានក្នុងការបំពេញកាតព្វកិច្ចនៃមាត្រា ១១ អាចនាំឱ្យនិយតករលុបចោលឈ្មោះដែនរបស់អង្គភាពនោះចេញពីប្រព័ន្ធគ្រប់គ្រងឈ្មោះដែនជាតិ។ ចំពោះក្រុមហ៊ុនស្វែងរកប្រាក់ចំណេញដែលមាននីតិបុគ្គលិកលក្ខណៈ ដោយការចុះបញ្ជីឈ្មោះដែនជាតិ[47] ទណ្ឌកម្មនេះអាចមានន័យថា ក្រុមហ៊ុនមិនអាចធ្វើអាជីវកម្មដោយស្របច្បាប់នៅកម្ពុជាបានទៀតទេ។ ដោយសារតែផលវិបាកធ្ងន់ធ្ងរជាយថាហេតុ ការពិន័យនេះហាក់ដូចជាច្រើនហួសហេតុ ជាពិសេសការពិចារណាលើលទ្ធភាពអនុវត្តវិធានការដែលមិនសូវធ្ងន់ធ្ងរ ដើម្បីសម្រេចតាមវត្ថុបំណងស្របច្បាប់ណាមួយនៃមាត្រា ១៩ ។ មាត្រា ១៥ នេះរំលោភលើលក្ខខណ្ឌទីបីនៃលក្ខខណ្ឌទាំងទាំងបីនៃមាត្រា ១៩ ដែលតម្រូវឱ្យមានការរឹតត្បិតតាមការចាំបាច់ និងសមាមាត្រទៅនឹងវត្ថុបំណងស្របច្បាប់ដែលត្រូវសម្រេច។

### *អនុក្រឹត្យនេះរឹតត្បិតលើសេរីភាពខាងការបញ្ចេញមតិដោយហាមឃាត់ឈ្មោះដែនមួយចំនួន*

មាត្រា ៨ (ឃ) ចែងថាឈ្មោះដែន *«ប៉ះពាល់ដល់សីលធម៌ ប្រពៃណី សាសនា និងបំពានច្បាប់ និងបទប្បញ្ញត្តិជាធរមាន»* គឺមិនអាចចុះបញ្ជីបានទេ។ ឈ្មោះដែនគឺជាវិធីមួយសម្រាប់អង្គភាពជានាថាគេហទំព័ររបស់ខ្លួនអាចឱ្យអ្នកប្រើប្រាស់គេហទំព័រស្វែងរកបានយ៉ាងងាយស្រួល។ ដូចនេះ ឈ្មោះដែនអាចជាការរួមបញ្ចូលគ្នានូវពាក្យគន្លឹះដើម្បីបង្កើតឈ្មោះប្រកបដោយភាពច្នៃប្រឌិតតែមួយគត់សម្រាប់ប្រាប់ដល់អ្នកប្រើប្រាស់ និងម៉ាស៊ីនស្វែងរកនូវអ្វីដែលមានក្នុងគេហទំព័រនេះ ហើយអាចជាមធ្យោបាយមួយនៃការបញ្ចេញមតិ។ ការហាមឃាត់ឈ្មោះដែនដែលប៉ះពាល់ដល់ *«សីលធម៌ ប្រពៃណី និងសាសនា»* អនុក្រឹត្យនេះអាចរារាំងអង្គភាពនានាក្នុងការជ្រើសរើសឈ្មោះដែនដោយសេរី។ ដូច្នេះ មាត្រា ៨ (ឃ) ហាក់បីដូចជារឹតត្បិតលើសេរីភាពខាងការបញ្ចេញមតិ។ ពាក្យថា *«សីលធម៌»* និង *«ប្រពៃណី»* មិនមានភាពច្បាស់លាស់គ្រប់គ្រាន់ដើម្បីទប់ស្កាត់ការបកស្រាយខ្លឹមសារដោយអត្តនោម័តនោះទេ។ និយតករអាចបកស្រាយលក្ខខណ្ឌទាំងនេះក្នុងន័យទូលាយ ដើម្បីបញ្ជាក់ពីហេតុផលនៃការបដិសេធរបស់ខ្លួនក្នុងការផ្តល់ឱ្យអង្គភាពនូវឈ្មោះដែនដែលខ្លួនបានជ្រើសរើស។ ដោយសារការប្រើប្រាស់ពាក្យមិនច្បាស់លាស់ បទប្បញ្ញត្តិនេះបំពានលើលក្ខខណ្ឌទីមួយនៃលក្ខខណ្ឌទាំងបីនៃមាត្រា ១៩ ដែលចែងថាច្បាប់ដែលដាក់ការរឹតត្បិតលើសេរីភាពខាងការបញ្ចេញមតិត្រូវបំពេញតាមកម្រិតជាក់លាក់នៃភាពច្បាស់លាស់។ ចំពោះសេចក្តីយោងដល់ *«សាសនា»* ហាក់ដូចជាមានបញ្ហាផងដែរ។ គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ធ្លាប់ពន្យល់ថា ការហាមឃាត់ការបញ្ចេញមតិដោយខ្វះការគោរពចំពោះសាសនាគឺមិនស៊ីសង្វាក់គ្នាជាមួយនឹង ក.អ.ស.ព.ន[48] ដែលចែងថាការបញ្ចេញមតិបែបនេះមិនមែនជា *«ការតស៊ូមតិឱ្យមានការស្អប់ខ្ពើមសាសនាដែលបង្កើតជាការញុះញង់ឱ្យមានការរើសអើង អរិភាព ឬហិង្សា»* នោះទេ។[49] ម្យ៉ាងវិញទៀត ការហាម

---

[47] មាត្រា ៧ នៃអនុក្រឹត្យ។

[48] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ, សេចក្តីអធិប្បាយទូទៅលេខ ៣៤ កថាខណ្ឌទី ៤៨។

[49] ក.អ.ស.ព.ន មាត្រា ២០ កថាខណ្ឌទី ២។

ឃាត់ឈ្មោះដែន «ដែលប៉ះពាល់ដល់» សាសនាគឺមានអត្ថន័យទូលាយខ្លាំងពេកនិងមិនអនុលោមតាមបទដ្ឋានអន្តរជាតិស្តីពីសេរីភាពខាងការបញ្ចេញមតិ។

ទាំងនេះគឺជាកង្វល់បន្ថែមដោយហេតុថាការទទួលខុសត្រូវ ក្នុងការកំណត់ឈ្មោះដែនជាតិណាមួយដែលត្រូវបានហាមឃាត់ គឺជាសមត្ថកិច្ចរបស់និយតករ ដែលជាស្ថាប័នរដ្ឋាភិបាល។ ដូច្នេះ អនុក្រឹត្យនេះតម្រូវឱ្យអង្គភាពបង្កើតឈ្មោះដែនខ្ទមែនដែលត្រូវចុះបញ្ជីតាមការកំណត់របស់រដ្ឋាភិបាលតែប៉ុណ្ណោះ។ នេះបណ្តាលឱ្យមានការព្រួយបារម្ភថារដ្ឋាភិបាលអាចបំពានលើការសម្រេចរបស់ខ្លួន ក្នុងការបដិសេធលើឈ្មោះដែនតាមអំពើចិត្តដោយមិនត្រឹមត្រូវ ដោយដាក់កំហិតលើអង្គភាពដែលបញ្ជូនឈ្មោះដែន និងរំលោភលើសេរីភាពខាងការបញ្ចេញមតិរបស់ពួកគេ។

## V. ស្ថានភាពនៃសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាននៅកម្ពុជា

ចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២១ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២ សិទ្ធិសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាន នៅតែបន្តរងការវាយប្រហារនៅក្នុងប្រទេសកម្ពុជា ដោយអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស តែងរងការបង្ក្រាប និងដៅមុខសញ្ញាដោយសារការអនុវត្តសិទ្ធិស្របច្បាប់ក្នុងការរាយការណ៍ និងការតស៊ូមតិសំខាន់ៗ។ តារាងខាងក្រោមនេះ សង្ខេបអំពីស្ថានភាពនៃសិទ្ធិទាំងបីក្នុងអំឡុងពេលនៃការសរសេររបាយការណ៍នេះ៖

| ស្ថានភាពនៃសេរីភាពសារព័ត៌មាន | ស្ថានភាពនៃសេរីភាពខាងការបញ្ចេញមតិរបស់អ្នកការពារសិទ្ធិមនុស្ស | ស្ថានភាពនៃសិទ្ធិទទួលព័ត៌មាន |
|---|---|---|
| • អាជ្ញាបណ្ណផ្សព្វផ្សាយចំនួនបួនត្រូវបានដក ហូត។<br>• អ្នកសារព័ត៌មាន ២០ នាក់ ប្រឈមមុខនឹងចំណាត់ការតាមផ្លូវច្បាប់៖<br>- កោះហៅ ៤ នាក់<br>- សួរចម្លើយ ៩ នាក់<br>- ចាប់ខ្លួន ១៥ នាក់ ហើយម្នាក់មានចេញដីកាបង្គាប់ឱ្យចាប់ខ្លួន<br>- ឃុំខ្លួន ១៤ នាក់<br>- ចោទប្រកាន់ ២ នាក់<br>- ផ្តន្ទាទោស ២ នាក់<br>- តម្កល់សាលក្រម ១ នាក់។ | • អ្នកការពារសិទ្ធិមនុស្ស ចំនួន ១៣ នាក់ ប្រឈម នឹងចំណាត់ការផ្លូវច្បាប់៖<br>- កោះហៅ ៣ នាក់<br>- សួរចម្លើយ ៤ នាក់<br>- ឃាត់ខ្លួន ៤ នាក់<br>- ចោទប្រកាន់ ៤ នាក់<br>- ផ្តន្ទាទោស ៤ នាក់<br>- តុលាការជាន់ខ្ពស់តម្កល់សេចក្តីសម្រេចផ្តន្ទាទោស ៤ នាក់ ។ | • សាលក្រមចំនួន ២០ ត្រូវបានចេញផ្សាយ ប៉ុន្តែនៅតែមានបញ្ហាជាច្រើនចំពោះតម្លាភាពរបស់តុលាការ។<br>• ការពិភាក្សាបានធ្វើឡើងអំពីបណ្ណសាររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា («អ.វ.ត.ក») និងរបៀបរក្សាសិទ្ធិសាធារណជនក្នុងការយល់ដឹងអំពីហេតុការណ៍កន្លងមកទាក់ទងនឹងការប្រព្រឹត្តបទឧក្រិដ្ឋកម្រិតធ្ងន់។<br>• អ្នកសារព័ត៌មានបន្តព្យាយាមដើម្បីទទួលព័ត៌មានពីមន្ត្រីសាធារណៈ។<br>• ការអនុម័តច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានបន្តប្រឈមនឹងការពន្យារពេល។ |

## ៥.១. ស្ថានភាពនៃសេរីភាពសារព័ត៌មាន[50]

ក្នុងអំឡុងពេលនៃការសរសេររបាយការណ៍នេះ ក្រសួងព័ត៌មានបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការលើកកម្ពស់សេរីភាពសារព័ត៌មាន។[51] ទោះជាយ៉ាងនេះក៏ដោយ ការវិវត្តផ្សេងទៀត បានបង្ហាញថាសេរីភាពសារព័ត៌មាននៅតែបន្តរងការប៉ះពាល់នៅទូទាំងប្រទេសកម្ពុជា។ និន្នាការខាងក្រោមនេះបង្ហាញពីការធ្លាក់ចុះនូវសិទ្ធិសេរីភាពនេះ ហើយស្របជាមួយនឹងលទ្ធផលរបស់អង្គការសហប្រជាជាតិដែលរកឃើញថា ប្រព័ន្ធផ្សព្វផ្សាយរបស់ប្រទេសនេះស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់។[52]

នៅក្នុងឆ្នាំ **២០២១** នៅកម្ពុជាមានៈ
- ប្រព័ន្ធផ្សព្វផ្សាយចំនួន **២.០១៧** រួមទាំងគេហទំព័រព័ត៌មានចំនួន **៧០៦** និងគេហទំព័រព័ត៌មានវីដេអូចំនួន ៨១ កាសែតចំនួន ៤៤៧ ទស្សនាវដ្តីចំនួន ១៩៣ ស្ថានីយ៍វិទ្យុចំនួន ២២១ ស្ថានីយទូរទស្សន៍ឌីជីថលចំនួន ៨ ស្ថានីយទូរទស្សន៍នៅតាមខេត្តចំនួន ២១០ ក្រុមហ៊ុនផ្តល់សេវាទូរទស្សន៍ផ្កាយរណបចំនួន ២ និងសមាគមប្រព័ន្ធផ្សព្វផ្សាយចំនួន ៥០។

ការគំរាមកំហែងដែលអ្នកសារព័ត៌មាន ប្រឈមមុខក្នុងពេលបំពេញការងារស៊ើបអង្កេត និងអនុវត្តសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន ត្រូវបានកត់ត្រាទុក។ ការគំរាមកំហែងទាំងនេះរួមមានការដកហូតអាជ្ញាប័ណ្ណផ្សព្វផ្សាយ ការយាយីតាមប្រព័ន្ធតុលាការ ការរារាំងនៅពេលរាយការណ៍អំពីបញ្ហារសើបដែលនាំទៅដល់ការដាក់កំហិតខ្លួនឯង ការគំរាមកំហែងសន្តិសុខផ្លូវកាយ ក៏ដូចជាការរើសអើង និងការយាយីមកលើអ្នកសារព័ត៌មានជាស្ត្រី។

អង្គការអ្នកសារព័ត៌មានគ្មានព្រំដែនបានដាក់ចំណាត់ថ្នាក់ប្រទេសកម្ពុជានៅលេខរៀងទី ១៤២ ក្នុងចំណោម ១៨០ ប្រទេសដែលបានវាយតម្លៃនៅក្នុងសន្ទស្សន៍សេរីភាពសារព័ត៌មានពិភពលោកឆ្នាំ២០២២ របស់ខ្លួន[53] បង្ហាញថា សេរីភាពសារព័ត៌មានដែលជាធាតុផ្សំដ៏សំខាន់មួយនៃលទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ កំពុងស្ថិតក្រោមការគំរាមកំហែងនៅក្នុងប្រទេស។

### *ផលប៉ះពាល់នៃច្រកទ្វារអ៊ីនធឺណិតជាតិមកលើសេរីភាពសារព័ត៌មាន*

អនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ ត្រូវបានអនុម័តនៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២១។[54] អនុក្រឹត្យនេះបង្កើតនូវច្រកទ្វារអ៊ីនធឺណិតជាតិ («អនុក្រឹត្យច្រកទ្វារអ៊ីនធឺណិតជាតិ») ដែលតម្រូវឱ្យរាល់ការ

---

[50] សំ សុពេជ្រ "ការរីកលូតលាស់នៃបណ្តាញព័ត៌មានអនឡាញទាមទារឱ្យមានប្រព័ន្ធផ្សព្វផ្សាយកាន់តែឯករាជ្យ និងមានគុណភាពថែមទៀត" (*ខេមបូឌានេស* ១១ មករា ២០២២) ឱម ប៊ុនធឿន "ព្រះរាជាណាចក្រកម្ពុជាមានកន្លែងបោះពុម្ពផ្សាយជាង ២.០០០ កន្លែងទាំងតាមអនឡាញ និងបណ្តាញទូរទស្សន៍" (*ភ្នំពេញប៉ុស្តិ៍*, ៦ មករា ២០២២)។

[51] "កម្ពុជាបញ្ជាក់ជាថ្មីពីការប្តេជ្ញាចិត្តលើកកម្ពស់សេរីភាពសារព័ត៌មាន" (*ខ្មែរថាមស៍*, ២៩ មេសា ២០២២)។

[52] ការិយាល័យឧត្តមស្នងការ" ស្ថានភាពនៃសេរីភាពខាងការបញ្ចេញមតិក្នុងប្រទេសកម្ពុជា" (ការិយាល័យឧត្តមស្នងការ ខែសីហា ឆ្នាំ ២០២២)ទំព័រទី២៧។

[53] អ្នកសារព័ត៌មានគ្មានព្រំដែន, សន្ទស្សន៍សេរីភាពសារព័ត៌មានពិភពលោកឆ្នាំ ២០២២។

[54]សម្រាប់ការវិភាគពេញលេញលើផលប៉ះពាល់នៃអនុក្រឹត្យលើសេរីភាពមូលដ្ឋាន រួមទាំងសេរីភាពខាងការបញ្ចេញមតិ សូមមើលរបាយការណ៍ប្រចាំឆ្នាំលើកទីប្រាំមួយស្តីពីការឃ្លាំមើលសេរីភាពមូលដ្ឋាននៅកម្ពុជារបស់មជ្ឈមណ្ឌលសាមគ្គីភាព និងសមាគមអាដហុករបស់ ម.ស.ម.ក (មេសា ២០២២) ទំព័រ ១៣-១៥ ។

ទំនាក់ទំនង និងទិន្នន័យអ៊ីនធឺណិតទាំងអស់ ទាំងក្នុងស្រុក និងក្រៅស្រុក ត្រូវឆ្លងកាត់តាមច្រកទ្វារអ៊ិនធឺណិតជាតិជាមុនសិន មុនពេល ត្រូវបានបញ្ជូនទៅអ្នកប្រើប្រាស់ចុងក្រោយ។ អង្គការសង្គមស៊ីវិល បានថ្កោលទោសចំពោះសំណើច្រកទ្វារអ៊ិនធឺណិតជាតិនេះ ដែលជាការគំរាមកំហែងដល់ការអនុវត្តសេរីភាពមូលដ្ឋាន រួមទាំងសេរីភាពខាងការបញ្ចេញមតិផងដែរ។[55] ការអនុវត្តអនុក្រឹត្យនេះ ដែលគ្រោងធ្វើឡើងនៅអំឡុងខែកុម្ភៈ ឆ្នាំ២០២២ ត្រូវបានពន្យារពេលដោយសារ «បញ្ហាបច្ចេកទេស» នេះបើយោងតាមក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។[56] គិតរហូតត្រឹមខែកញ្ញា ឆ្នាំ២០២២ អនុក្រឹត្យច្រកទ្វារអ៊ិនធឺណិតជាតិមិនទាន់ចូលជាធរមាននៅឡើយទេ។ ទោះបីជាពន្យារពេលអនុវត្តក៏ដោយ ក៏ផលប៉ះពាល់នៃអនុក្រឹត្យច្រកទ្វារអ៊ិនធឺណិតជាតិត្រូវបានដឹងរួចជាស្រេច។ អ្នកសារព័ត៌មានម្នាក់ដែលបានសម្ភាសដោយវិទ្យុវីអូអេ បានសម្តែងនូវការព្រួយបារម្ភចំពោះសុវត្ថិភាពផ្ទាល់ខ្លួន និងហានិភ័យបន្ថែមទៀតនៃការឃ្លាំមើល។ លោកបានបន្ថែមថា អនុក្រឹត្យនេះបានជះឥទ្ធិពលដោយផ្ទាល់ដល់ការងាររបស់គាត់ ដោយបង្ខំឱ្យគាត់ប្រកាន់យកនូវវិធីសាស្ត្រប្រុងប្រយ័ត្នជាងមុន និងធ្វើឱ្យគាត់ពិបាកក្នុងការរាយការណ៍។[57]

## *ការដកហូតអាជ្ញាបណ្ណផ្សព្វផ្សាយ*

ប៉ុន្មានថ្ងៃបន្ទាប់ពីមន្ត្រីជាន់ខ្ពស់នៃក្រសួងព័ត៌មាន បានបដិសេធចំពោះការរិះគន់ជុំវិញសេរីភាពសារព័ត៌មាននៅកម្ពុជា និងបានសាទរចំពោះភាពប្រសើរឡើងនៃវិស័យសារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ[58] ក្រសួងព័ត៌មានបានប្រកាសដកអាជ្ញាបណ្ណប្រព័ន្ធផ្សព្វផ្សាយចំនួនបី គឺទូរទស្សន៍អនឡាញ *ខ្មែរខាវើរធីវី (Khmer Cover TV "KCTV"), ខេមបូឌាធូដេ (Cambodia Today) និងបាយ៉ុងថាមស៍ (Bayong Times)* ដែលបណ្តាញសារព័ត៌មានទាំងអស់ត្រូវបានដកហូតអាជ្ញាបណ្ណពីបទបំពានលើក្រមសីលធម៌វិជ្ជាជីវៈអ្នកសារព័ត៌មាន និងកិច្ចសន្យា។[59] យោងតាមអង្គការអ្នកសារព័ត៌មានគ្មានព្រំដែន ក្រសួងព័ត៌មានប្រាប់ដល់ចាងហ្វាងនៃប្រព័ន្ធផ្សព្វផ្សាយចំនួនបីថា ពួកគេអាចស្នើសុំអាជ្ញាបណ្ណវិញបានប្រសិនជាខ្លួនកែតម្រូវ ឬលុបមាតិកាព័ត៌មានដាក់លាក់នោះចោល។[60] ទាំងចាងហ្វាងកាសែត*បាយ៉ុងថាមស៍* និងនិពន្ធនាយកកាសែត*ខេមបូឌាធូដេ* បានឱ្យដឹងថាការដកហូតនេះធ្វើឡើងបន្ទាប់ពីពួកគេបានរាយការណ៍អំពីអំពើពុករលួយ។ លោក ទូច យុទ្ធា មកពីកាសែត*ខេមបូឌាធូដេ* បានបញ្ជាក់ថា លោកសង្ស័យថាអាជ្ញាបណ្ណរបស់ខ្លួនត្រូវបានលុបចោល ជាការឆ្លើយតប

---

[55] ម.ស.ម.ក និងស្ថាប័នផ្សេងទៀត "សេចក្តីថ្លែងការណ៍រួម៖ ច្រានចោលអនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ ដែលប៉ះពាល់ដល់សិទ្ធិមនុស្សតាមប្រព័ន្ធអ៊ីនធឺណិតនៅកម្ពុជា" (១៨ កុម្ភៈ ២០២១)។

[56] សេង ថៃ "រដ្ឋាភិបាលព្យួរច្រកទ្វារអ៊ីនធឺណិតដែលមានភាពចម្រូងចម្រាសជាបណ្តោះអាសន្ន" (*វីអូឌី,* ១៥ កុម្ភៈ ២០២២)។

[57] សាយ មុនី "ច្រកទ្វារអ៊ីនធឺណិតរបស់ប្រទេសកម្ពុជា នាំមកនូវភាពស្ងៀមស្ងាត់ នេះបើតាមប្រព័ន្ធផ្សព្វផ្សាយ"(*វីអូអេ,* ១៩ តុលា ២០២១)

[58] វួន ដារ៉ា "បដិសេធជាផ្លូវការនូវរបាយការណ៍ស្តីពីសេរីភាពសារព័ត៌មាន" (*ភ្នំពេញប៉ុស្តិ៍,* ១៤ មីនា ២០២២)។

[59] ង៉ែ ណៃ "ប្រព័ន្ធផ្សព្វផ្សាយអនឡាញចំនួនបីត្រូវបានដកហូតអាជ្ញាបណ្ណ" (*សារព័ត៌មានខេមបូចា,* ២៥ មីនា ២០២២)។

[60] អ្នកសារព័ត៌មានគ្មានព្រំដែន, "គេហទំព័រព័ត៌មានកម្ពុជាចំនួនបីត្រូវបានដកហូតអជ្ញាបណ្ណផ្សព្វផ្សាយ" (RSF, ២៨ មីនា ២០២២)។

ចំពោះការចុះផ្សាយអត្ថបទមួយកាលពីដើមខែកុម្ភៈ ឆ្នាំ២០២២ អំពីការក្លែងបន្លំលទ្ធកម្ម និងអំពើពុករលួយនៅក្រសួងការងារ។[61]

ការដកហូតទាំងនេះមិនត្រឹមតែជាការរំលោភសិទ្ធិសេរីភាពសារព័ត៌មានយ៉ាងធ្ងន់ធ្ងរនោះទេ[62] ប៉ុន្តែក៏អាចនាំឱ្យមានការដាក់កំហិតខ្លួនឯងក្នុងចំណោមអ្នកសារព័ត៌មានផងដែរ។ លោក តិល សាមុត មកពីកាសែត *បាយ៉ុងថាមស៍* បានសម្តែងនូវការព្រួយបារម្ភជុំវិញបញ្ហានេះនៅពេលដែលលោកបាននិយាយថា ការដកហូតទាំងនេះអាច «បំភ័យដល់ប្រព័ន្ធផ្សព្វផ្សាយជាច្រើនទៀតឱ្យឈប់រាយការណ៍ពីការពិត»។[63]

ប្រព័ន្ធផ្សព្វផ្សាយមួយទៀតឈ្មោះ *អេសប៊ីធី ញូស៍ (SBT News)* ត្រូវបានដកហូតអាជ្ញាបណ្ណផ្សព្វផ្សាយកាលពីខែសីហា ឆ្នាំ២០២២ បន្ទាប់ពីលោក សាន្ត ប៊ុនធឿន ដែលជាចាងហ្វាងកាសែត *SBT News* បានធ្វើការផ្សាយផ្ទាល់ ក្នុងស្ថានភាពដូចជាស្រវឹង ដោយបានវាយចាន និងជេរប្រមាថ។[64] អាជ្ញាបណ្ណរបស់លោកត្រូវបានលុបចោលដោយការ *«ប្រព្រឹត្តអំពើអសីលធម៌ ការជេរប្រមាថ និងប៉ះពាល់ដល់សីលធម៌សង្គម កិត្តិសព្ទ និងសេចក្តីថ្លៃថ្នូររបស់អ្នកសារព័ត៌មានអាជីព»* និងការល្មើសកិច្ចសន្យាដែលលោកបានចុះជាមួយក្រសួងព័ត៌មាន។ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ថ្លែងជុំវិញករណីនេះថា *«ជនគ្រប់រូបមានសិទ្ធិនិយាយ ប៉ុន្តែមិនរាប់បញ្ចូលសិទ្ធិស្បថស្បែទេ»* និងបានអំពាវនាវឱ្យក្រសួងព័ត៌មានដកហូតអាជ្ញាបណ្ណអ្នកសារព័ត៌មានណាដែលប្រើពាក្យមិនសមរម្យ។[65]

## *ការយាយីតាមប្រព័ន្ធតុលាការលើអ្នកសារព័ត៌មាន*

ប៉ុន្មានឆ្នាំចុងក្រោយនេះ អាជ្ញាធរបានបង្ក្រាបលើប្រព័ន្ធផ្សព្វផ្សាយ ក្នុងគោលបំណងទប់ស្កាត់ ឬដាក់ទណ្ឌកម្មលើការរាយការណ៍មិនល្អ។ ជាពិសេស ចំណាត់ការផ្លូវច្បាប់ត្រូវបាន និងបន្តពឹងផ្អែកលើអាជ្ញាធរក្នុងការបំភិតបំភ័យអ្នកសារព័ត៌មាន និងរឹតត្បិតលើសិទ្ធិនិងសេរីភាពក្នុងការរាយការណ៍។ ក្នុងចំណោមអ្នកសារព័ត៌មាន ១៨ នាក់ ដែលបានផ្តល់សម្ភាសសម្រាប់របាយការណ៍នេះ មានដប់នាក់បានលើកឡើងពីការគំរាមកំហែងចាត់វិធានការផ្លូវច្បាប់ ដែលជាការគំរាមកំហែងដ៏ធំបំផុតមួយ ចំពោះសេរីភាពសារព័ត៌មាននៅកម្ពុជានាពេលបច្ចុប្បន្ន។

ចន្លោះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២១ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២ រដ្ឋាភិបាល បានចាត់វិធានការផ្លូវច្បាប់មកលើអ្នកសារព័ត៌មានយ៉ាងហោចណាស់២០ នាក់ ដែលមានការកើនឡើងយ៉ាងខ្លាំង ពីចំនួនអ្នកសារ

---

[61] ណាត សុភាព "ក្រសួងព័ត៌មានដកហូតអាជ្ញាបណ្ណបោះពុម្ពផ្សាយឌីជីថលចំនួនបី" (*វីអូឌី,* ១៦ មីនា ២០២២)។

[62] ហ៊ុល រស្មី "អង្គការឃ្លាំមើលអន្តរជាតិ Watchdog ថ្កោលទោសកម្ពុជាចំពោះការដកហូតអាជ្ញាបណ្ណប្រព័ន្ធផ្សព្វផ្សាយ" (*វីអូអេ,* ៤មេសា ២០២២)។

[63] អ្នកសារព័ត៌មានគ្មានព្រំដែន, "គេហទំព័រព័ត៌មានកម្ពុជាចំនួនបីត្រូវបានដកហូតអាជ្ញាបណ្ណបោះពុម្ពផ្សាយ" (*អ្នកសារព័ត៌មានគ្មានព្រំដែន,* ២៨ មិនា ២០២២)។

[64] ម៉ិច ដារ៉ា "អង្គរក្សនាយករដ្ឋមន្ត្រីត្រូវបានបណ្តេញចេញជុំវិញការរិះគន់អំពីគ្នំតាម៉ៅ" (*វីអូឌី,* ២២ សីហា ២០២២)។

[65] ឌិម ប៊ុនធឿន "មាតិកាតាមអ៊ីនធឺណិតដែលមានលក្ខណៈបំពាន មិនអាចអត់ឱនបានឡើយ នេះបើតាមការព្រមានរបស់លោក ហ៊ុន សែន" (*ភ្នំពេញប៉ុស្តិ៍,* ២៤ សីហា ២០២២)។

ព័ត៌មាន (ប្រាំបួន) ដែលប្រឈមមុខនឹងវិធានការផ្លូវច្បាប់ក្នុងរយៈពេលដូចគ្នានៃរបាយការណ៍មុន។ ក្នុងចំណោមអ្នកសារព័ត៌មានទាំងនេះ៖

- កោះហៅចំនួន ៤ នាក់
- សួរចម្លើយចំនួន ៩ នាក់
- ឃុំខ្លួនចំនួន ១៤ នាក់
- បង្ខំឱ្យចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្យាថាខ្លួននឹង «បញ្ឈប់» ការថតសកម្មភាពរបស់អាជ្ញាធរជាសាធារណៈចំនួន ១ នាក់ ។
- ដីកាបង្គាប់ឱ្យចាប់ខ្លួនចំនួន ១ នាក់
- ចាប់ខ្លួនចំនួន ១៤ នាក់
- រងការចោទប្រកាន់ចំនួន ២ នាក់ (ម្នាក់ពីបទញុះញង់ឱ្យមានការរើសអើង តាមមាត្រា ៤៩៤ និង ៤៩៦ បទបរិហារកេរ្តិ៍ជាសាធារណៈ តាមមាត្រា ៣០៥ នៃក្រមព្រហ្មទណ្ឌ) និងម្នាក់ទៀតពីបទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ (មាត្រា ៤៩៤ និង ៤៩៥ នៃក្រមព្រហ្មទណ្ឌ) ។
- កាត់ទោសចំនួន ២ នាក់។
- តម្កល់សេចក្ដីសម្រេចដោយតុលាការជាន់ខ្ពស់ចំនួន ១ នាក់។

***អ្នកសារព័ត៌មានពីរនាក់ត្រូវបានកាត់ទោសពីការរាយការណ៍ព័ត៌មានចន្លោះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២១ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២***

**យួន ឈីវ៖** កាលពីថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ២០២១ សាលាដំបូងខេត្តកោះកុង បានកាត់ទោសលោក ឈីវ ដែលជាចាងហ្វាងសារព័ត៌មាន *កោះកុងព័ត៌មានទាន់ហេតុការណ៍ (Koh Kong Hot News)* ពីបទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋតាមមាត្រា៤៩៤ និង ៤៩៥ នៃក្រមព្រហ្មទណ្ឌ និងផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល ១ ឆ្នាំ និងពិន័យជាប្រាក់ពីរលានរៀល[66] ចំពោះការបង្ហោះតាមហ្វេសប៊ុកដោយលោករិះគន់អាជ្ញាធរថាបានបណ្ដេញប្រជាពលរដ្ឋ និងបំផ្លាញផលដំណាំ (រួមទាំងរបស់លោកផងដែរ) ក្នុងឧទ្យានជាតិបទុមសាគរ។

**កៅ ពិសិទ្ធ** - អ្នកសារព័ត៌មាន *សៀមរាប ទាន់ហេតុការណ៍ (The Siem Reap Tanhetkar)* ម្នាក់ត្រូវបានចាប់ខ្លួនកាលពីខែកក្កដា ឆ្នាំ២០២១ នៅខេត្តបាត់ដំបង បន្ទាប់ពីគាត់បានបង្ហោះសារលើបណ្ដាញសង្គមចំនួនបីដោយបានរិះគន់រាជរដ្ឋាភិបាលកម្ពុជា និងប្រសិទ្ធភាពនៃវ៉ាក់សាំងបង្ការជំងឺរាតត្បាតសកលកូវីដ-១៩ ដែលផលិតដោយប្រទេសចិន។ នៅខែធ្នូ ឆ្នាំ២០២១ គាត់ត្រូវបានផ្តន្ទាទោសពីបទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋតាមមាត្រា ៤៩៤ និង ៤៩៥ នៃក្រមព្រហ្មទណ្ឌ ក៏និងបទរារាំងការអនុវត្តវិធានការបង្ការនៃជំងឺកូវីដ-១៩ តាមមាត្រា ១១ នៃ *ច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ និងជំងឺ*

[66] យួន ណារីម និង ជា សុខនី "ចាងហ្វាងសារព័ត៌មានឌីជីថលត្រូវបានផ្តន្ទាទោស ដោយកាត់ទោសឲ្យជាប់ពន្ធនាគារទាក់ទងនឹងជម្លោះនៅខេត្តកោះកុង" (*សារព័ត៌មានខេមបូចា,* ៣០ កញ្ញា ២០២១)។

*ឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត។* សាលាឧទ្ធរណ៍ខេត្តបាត់ដំបងបានតម្កល់ទោសនៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២២។[67]

ករណីទាំងនេះបង្ហាញពីបញ្ហាប្រឈម ដែលអ្នកសារព័ត៌មានត្រូវដោះស្រាយក្នុងការបំពេញការងាររបស់ខ្លួន។ ពួកគេជាច្រើនប្រឈមនឹងការឃុំខ្លួន និងសួរចម្លើយដោយបំពានពេលកំពុងបំពេញភារកិច្ច ប៉ុន្តែក៏មានការចោទប្រកាន់ និងផ្តន្ទាទោសព្រហ្មទណ្ឌដោយមិនត្រឹមត្រូវផងដែរ ដោយសារអាជ្ញាធរហាក់ដូចជាបានកំណត់ថានឹងប្រើប្រាស់ច្បាប់ព្រហ្មទណ្ឌចំពោះពួកគេជាជាងបទប្បញ្ញត្តិ *ច្បាប់ស្តីពីរបបសារព័ត៌មាន*។

អ្នកសារព័ត៌មានចំនួនប្រាំនាក់ដែលបានផ្តល់សម្ភាសន៍សម្រាប់របាយការណ៍នេះបានលើកឡើងពីការគំរាមកំហែងជាក់លាក់ដោយការដាក់ពន្ធនាគារថាជាហានិភ័យចម្បងចំពោះសេរីភាពសារព័ត៌មាននៅកម្ពុជា។ នេះអាចបណ្តាលមកពីមានករណីជាច្រើនដែលអ្នកសារព័ត៌មាន ត្រូវបានចាប់ដាក់ពន្ធនាគារក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះពីបទចោទប្រកាន់ខុសច្បាប់ចំពោះសកម្មភាពរាយការណ៍ស្របច្បាប់របស់ខ្លួន។[68] ករណីនេះបង្ហាញពីរបៀបដែលការដាក់ទោសជាប់ពន្ធនាគារតាមអំពើចិត្ត ត្រូវបានប្រើប្រាស់ជាឧបករណ៍មួយដើម្បីបំភិតបំភ័យអ្នកសារព័ត៌មាន និងដើម្បីបំបាក់ទឹកចិត្តពួកគេមិនឱ្យរាយការណ៍អំពីបញ្ហាដែលមានលក្ខណៈរសើប ឬពាក់ព័ន្ធនឹងមន្ត្រីមានអំណាច។

### *បញ្ហាប្រឈមនៅពេលរាយការណ៍អំពីបញ្ហាដែលចាត់ទុកថាមានលក្ខណៈរសើប ដែលនាំទៅដល់ការដាក់កំហិតខ្លួនឯង*

នៅឆ្នាំនេះ មានហេតុការណ៍ជាច្រើនត្រូវបានកត់ត្រា ដោយអាជ្ញាធរដាក់កំហិត ឬដាក់សម្ពាធលើអ្នកសារព័ត៌មានមិនឱ្យរាយការណ៍អំពីប្រធានបទជាក់លាក់។ បញ្ហាចម្បងដែលអ្នកសារព័ត៌មានត្រូវបានរារាំង រួមមាន៖

***វិវាទដីធ្លី៖*** បញ្ហាដីធ្លី ដូចជាវិវាទដីធ្លី ឬការបំផ្លិចបំផ្លាញបរិស្ថាន គឺជាបញ្ហាកើតមានក្នុងប្រទេសកម្ពុជាតាំងពីយូរយារណាស់មកហើយ។ យោងតាមទិន្នន័យដែលប្រមូលបានក្នុងអំឡុងពេលនៃការសរសេររបាយការណ៍បង្ហាញថាការរាយការណ៍អំពីបញ្ហាបែបនេះគឺជាបញ្ហាប្រឈមមួយ។ នៅក្នុងឧប្បត្តិហេតុចំនួនប្រាំបីដាច់ដោយឡែកពីគ្នា អ្នកសារព័ត៌មានប្រឈមនឹងការជ្រៀតជ្រែកក្នុងការប្រមូលព័ត៌មាន ឬសរសេរអំពីបញ្ហាដីធ្លី។

[67] ង៉ែ ណៃ "សាលាឧទ្ធរណ៍តម្កល់ទោសអ្នកសារព័ត៌មានដែលរិះគន់វ៉ាក់សាំង" ( *សារព័ត៌មានខេមបូចា,* ៥ កក្កដា ២០២២ )។
[68] ជាឧទាហរណ៍ សូមមើល "ការឃាឃីតាមប្រព័ន្ធតុលាការរយៈពេលបួនឆ្នាំចំពោះអតីតអ្នកសារព័ត៌មានវិទ្យុអាស៊ីសេរី" របស់ ម.ស.ម.ក ( *ម.ស.ម.ក,* វិច្ឆិកា ២០២១ ) លោក ស៊ុន ណារិន "ការកាត់ទោសអ្នកសារព័ត៌មានកម្ពុជាជុំវិញការបញ្ចេញមតិអំពីការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ ដែលជាការគំរាមកំហែងដល់សេរីភាព នេះបើតាមក្រុមប្រព័ន្ធផ្សព្វផ្សាយ" ( *វីអូអេ,* ៩ តុលា ២០២០ )។

***អ្នកសារព័ត៌មានដែលរាយការណ៍អំពីបញ្ហាដីធ្លី ប្រឈមនឹងការកើតឡើងជាច្រើនចន្លោះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២១ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២***

**<u>ការយាយី៖</u>** កាលពីថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២១ លោក **ពក ខឺយ** ដែលជាអ្នកយកព័ត៌មានវីអូឌី ត្រូវបានអាជ្ញាធរវាយខាន ខណៈដែលរាយការណ៍អំពីជម្លោះដីធ្លីជាមួយអ្នកភូមិ និងក្រុមហ៊ុនទទួលបន្ទុកសាងសង់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញថ្មី។ លោក ប៉ុក ឃើយ បានបន្តទៀតថា ខណៈគាត់កំពុងសម្ភាសអ្នកភូមិនៅកន្លែងដែលមានវិវាទដីធ្លីនោះ អាជ្ញាធរស្លៀកពាក់ស៊ីវិលបានដើរសំដៅមកគាត់ ហើយបានថតរូបគាត់ និងម៉ូតូ។ ខណៈគាត់កំពុងតែបើកម៉ូតូត្រឡប់មកភ្នំពេញវិញ លោក ឃើយ បានឃើញមនុស្សពីរនាក់តាមពីក្រោយគាត់។ មួយសន្ទុះក្រោយមក មន្ត្រីនគរបាលស្លៀកឯកសណ្ឋានចំនួនប្រាំនាក់បានព្យាយាមទាញគាត់ឱ្យចុះពីលើម៉ូតូ ប៉ុន្តែគាត់នៅតែបន្តបើកគេចខ្លួន។[69]

**<u>ការគំរាមកំហែង និងការបំភិតបំភ័យ</u>** - នៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២១ លោក **លួស សេង** ដែលជាម្ចាស់ស្ថានីយព័ត៌មានអនឡាញ *អិលអេសអិន ញូស៍ធីវី (LSN News TV)* គ្រោងនឹងរាយការណ៍អំពីវិវាទដីធ្លីដែលកំពុងកើតមានចំពោះអ្នកភូមិ និងគម្រោងអភិវឌ្ឍន៍អាកាសយានដ្ឋានអន្តរជាតិភ្នំពេញថ្មី។ លោក លួស សេង បានទទួលទូរសព្ទពីតំណាងអ្នកភូមិម្នាក់ ដោយព្រមានគាត់ថា មានអាជ្ញាធរជាច្រើនត្រូវបានដាក់ពង្រាយនៅនឹងទីតាំង ហើយប្រសិនបើគាត់ព្យាយាមនិយាយអំពីវិវាទ គាត់នឹងត្រូវចាប់ខ្លួន។ តាមការរាយការណ៍ លោក លួស សេង ធ្លាប់ត្រូវបានអាជ្ញាធរព្រមាន និងគំរាមកំហែងពីមុន បន្ទាប់ពីគាត់បានផ្សាយបន្តផ្ទាល់អំពីការតវ៉ាដែលធ្វើឡើងដោយសហគមន៍នេះ។[70]

មានអ្នកសារព័ត៌មាន ៥ នាក់ រួមមានឈ្មោះ **អ៊ុក ម៉ៅ** (មកពី *សារព័ត៌មានមហាហង្ស - Mohahong News*), **ឡា ម៉ិច** (មកពី *សារព័ត៌មានមរតកក្មេងវត្ត - Morodok Kmeng Wat News*), **ហែន សុផាត ហែន តុលា** និង **លឹម** (មកពី *សារព័ត៌មានកោះឯករាជ្យ - Koh Ekareach News*) ត្រូវបានរារាំងមិនឱ្យចូលព្រៃឡង់ ដើម្បីរាយការណ៍ពីសកម្មភាពកាប់ឈើខុសច្បាប់កាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០២២។ មន្ត្រីបរិស្ថានមកពីខេត្តស្ទឹងត្រែងបានបដិសេធឱ្យពួកគេចូល ដោយអះអាងថាត្រូវមានការអនុញ្ញាតពីមន្ទីរបរិស្ថានខេត្ត។ មន្ត្រីបានគំរាមដាក់ខ្នោះដៃ និងចាប់ខ្លួនអ្នកសារព័ត៌មានទាំងនោះប្រសិនបើពួកគេព្យាយាមចូលក្នុងព្រៃឡង់។[71]

នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២២ អ្នកកាសែតពលរដ្ឋឈ្មោះ តុប សុវណ្ណ បានថតរូប និងថតវីដេអូឈ្មួញឈើខុសច្បាប់ម្នាក់ដែលកំពុងដឹកជញ្ជូនឈើចូលក្នុងទូករបស់គេក្នុងខេត្តស្ទឹងត្រែង។ ពេលឈ្មួញឈើរូបនោះឃើញសុវណ្ណ កំពុងថត គេបានឆក់យកទូរស័ព្ទរបស់ សុវណ្ណ បោះចូលទឹកទន្លេ រួមជាមួយនឹងកាតអ្នកកាសែត និងសំបុត្របេសកកម្ម។[72]

---

[69] ស៊ន សារ៉ាត់ "អ្នកសារព័ត៌មានដែលផ្សព្វផ្សាយជុំវិញគម្រោងអាកាសយានដ្ឋានដ៏ធំប្រឈមមុខនឹងការគំរាមកំហែង និងការយាយី" (*សារព័ត៌មានខេមបូចា*, ០៩ កញ្ញា២០២១)។

[70] ស៊ន សារ៉ាត់ "អ្នកសារព័ត៌មានដែលផ្សព្វផ្សាយជុំវិញគម្រោងអាកាសយានដ្ឋានដ៏ធំប្រឈមមុខនឹងការគំរាមកំហែង និងការយាយី" (*សារព័ត៌មានខេមបូចា*, ៩ កញ្ញា ២០២១)។

[71] ការរាយការណ៍ហេតុការណ៍ (២៩ មករា ២០២២)។

[72] ការរាយការណ៍ហេតុការណ៍ (២៨ កក្កដា ២០២២)។

**<u>ចំណាត់ការផ្លូវច្បាប់៖</u>** លោក **ពក ខឺយ** ដែលជាអ្នកសារព័ត៌មានវីអូឌី ត្រូវបានកោះហៅទៅសាកសួរនៅនាយកដ្ឋានសន្តិសុខក្រសួងមហាផ្ទៃ កាលពីថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២១ បន្ទាប់ពី*សារព័ត៌មានខេមបូឌា* បានចេញសេចក្តីថ្លែងការណ៍លម្អិតជុំវិញការឃាឃីដែលលោកបានជួបប្រទះខណៈ ដែលគាត់ព្យាយាមនិយាយ អំពីជម្លោះដីធ្លីជុំវិញការសាងសង់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញថ្មី។[73]

កាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២១ រដ្ឋមន្ត្រីក្រសួងការពារជាតិ បានបញ្ជាឱ្យអាជ្ញាធរមូលដ្ឋានចាត់វិធានការផ្លូវច្បាប់ចំពោះលោក **យួន ឈីវ** ដែលជាចាងហ្វាងសារព័ត៌មានអនឡាញ និងជាអ្នកសារព័ត៌មានគេហទំព័រ *កោះកុងព័ត៌មានទាន់ហេតុការណ៍* ចំពោះការបង្ហោះហ្វេសប៊ុកចោទប្រកាន់អាជ្ញាធរថាបានបណ្តេញប្រជាពលរដ្ឋនៅខេត្តកោះកុង។ គាត់ត្រូវបានចោទប្រកាន់ថាបានបរិហារកេរ្តិ៍អភិបាលរងខេត្តកោះកុង និងបង្ខំឱ្យសរសេរលិខិតសុំទោស។ បួនថ្ងៃក្រោយមក លោក យួន ឈីវ ត្រូវបានចោទប្រកាន់ និងកាត់ទោសពីបទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ។ គាត់ត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល ១ ឆ្នាំ និងពិន័យជាប្រាក់ ២ លានរៀល។[74]

**សួស ចំរើន** ដែលជាអ្នកសារព័ត៌មានអនឡាញ និងជាប្រធាន *ទូរទស្សន៍អនឡាញ CHR* ក៏ដូចជាអ្នកសារព័ត៌មានផ្សេងទៀត ត្រូវបានកោះហៅឱ្យចូលខ្លួនបំភ្លឺនៅចំពោះមុខក្រសួងព័ត៌មាន នៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០២១។ ការកោះហៅនេះបានធ្វើឡើងក្រោយពេលដែលសារព័ត៌មាននេះបានចុះផ្សាយកម្រងអត្ថបទជុំវិញអំពើពុករលួយ និងបានចោទប្រកាន់មន្ត្រីយោធានៅខេត្តព្រះវិហារ ថាបានលក់ដីយោធា។ ក្រសួងបានលើកឡើងថា ជនដែលត្រូវកោះហៅបានធ្វើឱ្យខូចសេចក្តីថ្លៃថ្នូរ និងកិត្តិយសរបស់កងយោធពលខេមរភូមិន្ទ។ លោក សួស ចំរើន មានប្រសាសន៍ថា គាត់ចាត់ទុកការកោះហៅនេះជាគោលបំណងបំភិតបំភ័យ និងបំបាក់ទឹកចិត្តអ្នកសារព័ត៌មានមិនឱ្យផ្សាយការពិត។[75]

នៅខែមេសា ឆ្នាំ២០២២ មានការចេញដីកាបង្គាប់ឱ្យចាប់ខ្លួនលោក **ទ្រី សុផល** ជាអ្នកសារព័ត៌មានប្រចាំកាសែត *Everyday*។ លោកបានអះអាងថា លោកត្រូវបានចោទប្រកាន់ដោយមិនត្រឹមត្រូវពីបទចោរកម្ម និងគំរាមកំហែង ហើយដីកានោះមានគោលបំណងដាក់ទោសលោកដោយសារតែការថតសកម្មភាព និងរាយការណ៍អំពីការឈូសឆាយដីមួយកន្លែងនៅខេត្តព្រះវិហារកាលពីចុងឆ្នាំ២០២១ ។[76]

កាលពីថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២២ អ្នកសារព័ត៌មានវីអូឌី ៥ នាក់ រួមមានឈ្មោះ **ម៉ម មុន្នីរ័ត្ន, ហ៊ាន រង្សី, គៀត សុវិទ្ធធារី, ហ៊ី ឆាយ និង ដេនីញៀល ឃីតុន-អុលសែន** (Danielle Keeton-Olsen) ត្រូវបាន កង

---

[73] ការរាយការណ៍ហេតុការណ៍ (២១ កញ្ញា ២០២១)។

[74] យួន ណារីម និងជា សុខនី "ចាងហ្វាងសារព័ត៌មានឌីជីថលត្រូវបានផ្តន្ទាទោស ដោយកាត់ទោសឲ្យជាប់ពន្ធនាគារជុំវិញជម្លោះនៅខេត្តកោះកុង" (*សារព័ត៌មានខេមបូឌា*, ៣០ កញ្ញា ២០២១)។

[75] យុត សុគន្ធ "ក្រសួងព័ត៌មានកោះហៅម្ចាស់ប្រព័ន្ធផ្សព្វផ្សាយមកសាកសួរបន្ទាប់ពីផ្សព្វផ្សាយអំពើពុករលួយរបស់មន្ត្រីយោធា"(*វីអូឌី ខ្មែរ*, ៦ វិច្ឆិកា ២០២១)។

[76] ញឹម សុខន "អ្នកសារព័ត៌មានប្រឈមនឹងដីកាបង្គាប់ឱ្យចាប់ខ្លួន ក្រោយពេលថតសកម្មភាពឈូសឆាយដី"(*វីអូឌី*, ១៣ មេសា ២០២២)

កម្លាំងមកពីអង្គភាពអង្គរក្សរបស់លោកនាយករដ្ឋមន្ត្រីចាប់ខ្លួន ខណៈពួកគេកំពុងយកព័ត៌មានអំពីការដាំដើមឈើឡើងវិញនៅភ្នំតាម៉ៅ បន្ទាប់ពីមានការកាប់ឆ្ការមួយសប្តាហ៍មុន។ អាជ្ញាធរបានចោទប្រកាន់ពួកគេថាបានចូលទៅក្នុងតំបន់ដែលត្រូវបានរឹតត្បិតទោះបីជាមិនមានការបង្ហាញព័ត៌មានអំពីការរឹតត្បិតនេះជាសាធារណៈនៅពេលចាប់ខ្លួនក៏ដោយ។ អ្នកសារព័ត៌មានទាំងនោះត្រូវបានគេបញ្ជូនខ្លួនទៅទីបញ្ជាការយោធាមុននឹងត្រូវឃុំខ្លួនរយៈពេលប្រាំពីរម៉ោងនៅអធិការដ្ឋាននគរបាលស្រុកនិងសួរចម្លើយរួចរាល់។ អាជ្ញាធរបានរឹបអូសសម្ភាររបស់ពួកគេ ប៉ុន្តែបានប្រគល់ឱ្យវិញនៅពេលពួកគេត្រូវបានដោះលែង។[77]

**អំពើហិង្សាលើរាងកាយ៖** ក្នុងឧប្បត្តិហេតុពាក់ព័ន្ធនឹងអ្នកសារព័ត៌មានវីអូឌីចំនួន ៥ នាក់ កាលពីថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២២ អ្នកសារព័ត៌មានម្នាក់ត្រូវបានកងកម្លាំងអង្គភាពអង្គរក្សនាយករដ្ឋមន្ត្រីទះកំផ្លៀង។[78]

បន្ថែមពីលើករណីទាំងនេះ មានអ្នកសារព័ត៌មានម្នាក់ដែលបានផ្តល់សម្ភាសសម្រាប់របាយការណ៍នេះបានបង្ហាញថា ពួកគេធ្លាប់ត្រូវបានកោះហៅមកសាកសួរបន្ទាប់ពីរាយការណ៍អំពីការកាប់បំផ្លាញព្រៃឈើ និងការជួញដូរឈើ។ នៅក្នុងឧប្បត្តិហេតុដាច់ដោយឡែកមួយ អ្នកសារព័ត៌មានដដែលនោះបានទទួលការហៅទូរសព្ទដោយព្រមានពួកគេថាពួកគេនឹង «ប្រឈមនឹងបញ្ហា» ប្រសិនបើពួកគេរាយការណ៍អំពីបញ្ហាដីធ្លីពាក់ព័ន្ធនឹងដីរដ្ឋ។ អ្នកសារព័ត៌មានមិនដែលបញ្ចេញរឿងនេះទេ ហើយក៏មិនបានប្តឹងដែរ ព្រោះខ្លាចមានការតបត។

ដោយពិចារណាថាតើប្រធានបទអំពីបញ្ហាដីធ្លីមានភាពរសើបយ៉ាងណា នៅក្នុងប្រទេសកម្ពុជា ករណីទាំងអស់នេះហាក់ដូចជាបង្ហាញពីការប៉ុនប៉ងរបស់អាជ្ញាធរ ក្នុងការទប់ស្កាត់ការមិនចង់ឱ្យមានការចាប់អារម្មណ៍ចំពោះវិវាទដីធ្លីនិងរារាំងការរាយការណ៍មិនល្អរបស់អ្នកសារព័ត៌មាន។ នេះប្រហែលជាឧទាហរណ៍ដ៏ល្អបំផុតតាមរយៈយោបល់របស់ប្រធានអង្គភាពអង្គរក្ស ដែលបានចាប់ខ្លួនអ្នកសារព័ត៌មានវីអូឌីចំនួនប្រាំនាក់កាលពីខែសីហា ឆ្នាំ២០២២ ដោយនៅថ្ងៃបន្ទាប់ពីនោះ លោកថាតំបន់នេះបើកចំហសម្រាប់ភ្ញៀវចូលទស្សនា ដែលផ្ទុយនឹងការអះអាងពីមុនរបស់អាជ្ញាធរដែលថាអ្នកសារព័ត៌មានបានចូលក្នុងតំបន់ដោយបំពាន ប៉ុន្តែពួកគេត្រូវប្រើប្រកចូលខាងមុខ ដើម្បីមើលសកម្មភាពដាំដើមឈើឡើងវិញរបស់អាជ្ញាធរ។ លោកបានបន្តថា រូបភាពនៃតំបន់ដែលបានឈូសឆាយអាច *«បង្កបញ្ហា»* ហើយបានបន្ថែមទៀតថា *«យើងចង់ឱ្យថតនូវអ្វីដែលយើងបានដាំរួចហើយ។ កន្លែងក្បែរជើងភ្នំមិនទាន់បានធ្វើរួចរាល់នៅឡើយ មើលទៅមិនល្អនៅពេលដែលពួកគេថត»*។[79]

---

[77] គាត សុវិទ្ធារី, ដេនៀល ឃីតុន-អុលសេន (Danielle Keeton-Olsen) និងប៉ា សុខេង, "អង្គភាពអង្គរក្សរាប់រយនាក់ចូលកាន់កាប់តំបន់ដាំដើមឈើភ្នំតាម៉ៅឡើងវិញ" (*វីអូឌី,* ១៧ សីហា ២០២២)។

[78] យួន ណារីម & សុវណ្ណ ស្រីពេជ្រ "អ្នកសារព័ត៌មាន និងសកម្មជនបរិស្ថាន ត្រូវបានឃាត់ខ្លួន វាយដំ" (*សារព័ត៌មានខេមបូចា,* ១៦ សីហា ២០២២)។

[79] គាត សុវិទ្ធារី, ដេនៀល ឃីតុន-អុលសេន (Danielle Keeton-Olsen) និងប៉ា សុខេង, "អង្គភាពអង្គរក្សរាប់រយនាក់ចូលកាន់កាប់តំបន់ដាំដើមឈើភ្នំតាម៉ៅ" (*វីអូឌី,* ១៧ សីហា ២០២២)។

នៅពេលសួរថាតើមានប្រធានបទជាក់លាក់ណាខ្លះ ដែលពួកគេមិនហ៊ានរាយការណ៍នោះ អ្នកសារព័ត៌មានបីនាក់ដែលបានផ្តល់សម្ភាសសម្រាប់របាយការណ៍នេះ បានឆ្លើយថាគឺ «បញ្ហាដីធ្លី»។ ពួកគេពីរនាក់បានពណ៌នាបញ្ហាដីធ្លីនិងព្រៃឈើថាជា *«ប្រធានបទក្តៅ»* ហើយបាននិយាយថាពួកគេមិនរាយការណ៍ច្រើនអំពីបញ្ហាបែបនេះទេ។ អ្នកទីបីបាននិយាយថា ពួកគេបដិសេធក្នុងការសរសេរអំពីការកាប់បំផ្លាញព្រៃឈើជាក់លាក់ណាមួយដោយសារ *«បុគ្គលដែលមានអំណាច»* នៅពីក្រោយការកាប់ឆ្ការព្រៃ។

*កូដកម្មណាហ្គាវើលដ៍៖* យ៉ាងហោចណាស់មានករណីចំនួន ១២ ដែលអ្នកសារព័ត៌មានប្រឈមនឹងការរឹតត្បិតចំពោះការប៉ុនប៉ងនិយាយអំពីកូដកម្មនៅណាហ្គាវើលដ៍។[80] ក្នុងអំឡុងពេលធ្វើកូដកម្មជាច្រើនខែរហូតដល់ពេលសរសេររបាយការណ៍នេះ អាជ្ញាធរបានរងការរិះគន់ជារឿយៗចំពោះការប្រើអំពើហិង្សាហួសហេតុទៅលើកូដករ។ ការណ៍ដែលថាអាជ្ញាធររារាំងអ្នកសារព័ត៌មាន ខណៈដែលពួកគេកំពុងឃ្លាំមើលការតវ៉ាដែលធ្វើឡើងជាផ្នែកមួយនៃកូដកម្ម បង្ហាញពីការប៉ុនប៉ងជាមុនរបស់អាជ្ញាធរ ដើម្បីបញ្ចៀសការផ្សាយព័ត៌មានអំពីអំពើខុសឆ្គងរបស់ពួកគេ។

***អាជ្ញាធរបានជ្រៀតជ្រែកលើអ្នកសារព័ត៌មានជាញឹកញាប់ ខណៈពួកគេកំពុងរាយការណ៍អំពីកូដកម្មណាហ្គាវើលដ៍***

ការជ្រៀតជ្រែកដែលត្រូវបានកត់ត្រារួមមានជាអាទិ៍៖ អាជ្ញាធរគំរាមចាត់វិធានការផ្លូវច្បាប់លើអ្នកសារព័ត៌មាន លុះត្រាតែគាត់មិនបង្ហាញខ្លួន ហើយចាកចេញពីតំបន់នោះ៖[81] ការហាមឃាត់អ្នកសារព័ត៌មានក្នុងការចូលរួមសន្និសីទសារព័ត៌មានអំពីកូដកម្មដោយនគរបាល[82] ការយាយីអ្នកសារព័ត៌មាន និងបង្ខំឱ្យពួកគេលុបរូបភាព និងវីដេអូ[83] ការរារាំងពួកគេមិនឱ្យចូលទៅកាន់កន្លែងធ្វើកូដកម្ម[84] និងគំរាមរឹបអូសសម្ភាររបស់ពួកគេប្រសិនបើពួកគេថតរូប។[85]

---

[80] នៅអំឡុងខែមេសា ឆ្នាំ ២០២១ កាស៊ីណូណាហ្គាវើលដ៍បានបញ្ឈប់បុគ្គលិកជាង ១.៣០០ នាក់ ដោយលើកឡើងពីការធ្លាក់ចុះប្រាក់ចំណូលដែលបណ្តាលមកពីការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ ។ កម្មករនិយោជិតជាច្រើនដែលត្រូវបានបញ្ចប់ការងារគឺជាសមាជិកនិងមេដឹកនាំសហជីព។ បន្ទាប់ពីបានព្យាយាមចរចាបរាជ័យជាច្រើនលើកជាមួយកាស៊ីណូ និងការដាក់ពាក្យបណ្តឹងមិនបានសម្រេចទៅអាជ្ញាធរពាក់ព័ន្ធ សហជីពគាំទ្រសិទ្ធិការងារកម្មករនិយោជិតខ្មែរប្រចាំណាហ្គាវើល ("LRSU") បានជូនដំណឹងដល់អាជ្ញាធរអំពីគម្រោងចាប់ផ្តើមធ្វើកូដកម្មដោយសន្តិវិធីនៅខែធ្នូ ឆ្នាំ ២០២១។ នាពេលសរសេររបាយការណ៍នេះ (ចុងខែកញ្ញា ឆ្នាំ ២០២២) កូដកម្មនៅតែបន្ត។

[81] ត្រាន់ តិកសេង (Tran Techseng) និងម៉ៃឃើល ឌីកឃីសាន់ (Michael Dickison), "អ្នកចូលរួមធ្វើកូដកម្មនៅណាហ្គាវើលដ៍ត្រូវបានណែនាំឲ្យស្នាក់នៅផ្ទះរយៈពេល ៧ ថ្ងៃ" (*វីអូឌី,* ៥ កុម្ភៈ ២០២២)។

[82] ម៉ិច ដារ៉ា "អ្នកសារព័ត៌មានមួយចំនួនត្រូវបានរាំងមិនឱ្យចូលរួមសន្និសីទសារព័ត៌មាននគរបាលស្តីពីការចាប់ខ្លួននៅណាហ្គាវើល" (*វីអូឌី,* ៤ មករា ២០២២)។

[83] ប៉ា សុខេង "អាជ្ញាធរថាមិនបានបង្ខំអ្នកសារព័ត៌មានឱ្យលុបរូបថតកូដករនៅណាហ្គាវើលទេ" (*វីអូឌីខ្មែរ,* ១៤ មីនា ២០២២)។

[84] ខៃ សូណាង "អាជ្ញាធរបង្ខំឲ្យក្រុមកូដករនៅណាហ្គាវើលចាកចេញ" (*វិទ្យុអាស៊ីសេរី,* ២៧ មីនា ២០២២)។

[85] របាយការណ៍ឧប្បត្តិហេតុ (២៤ កុម្ភៈ ២០២២)។

*អំពើពុករលួយ៖* ក្នុងអំឡុងពេលនៃការសរសេររបាយការណ៍ អ្នកសារព័ត៌មានត្រូវបានជៀតជ្រែកជាច្រើនលើកច្រើនសាក្នុងការរាយការណ៍អំពើពុករលួយ។ ឧប្បត្តិហេតុដូចពិពណ៌នាខាងក្រោមហាក់ដូចជាបង្ហាញពីការប៉ុនប៉ងរបស់អាជ្ញាធរក្នុងការបំបាក់ទឹកចិត្តអ្នកសារព័ត៌មានមិនឱ្យធ្វើការរាយការណ៍អំពីបញ្ហាអវិជ្ជមានរបស់អាជ្ញាធរ។

**សួស ចំរើន៖** អ្នកសារព័ត៌មានអនឡាញ និងជាប្រធាន*ទូរទស្សន៍អនឡាញ CHR* ត្រូវបានកោះហៅ រួមជាមួយនឹងអ្នកសារព័ត៌មានផ្សេងទៀត ឱ្យចូលខ្លួនបំភ្លឺនៅចំពោះមុខក្រសួងព័ត៌មាន កាលពីថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២១ បន្ទាប់ពីអង្គភាពសារព័ត៌មាននេះបានចុះផ្សាយកម្រងអត្ថបទរៀបរាប់អំពីអំពើពុករលួយរបស់មន្ត្រីយោធា និងចោទប្រកាន់មន្ត្រីយោធាក្នុងខេត្តព្រះវិហារថាបានលក់ដីយោធា។ លោក សួស ចំរើន មានប្រសាសន៍ថា លោកចាត់ទុកការកោះហៅនេះថាមានគោលបំណងបំភិតបំភ័យអ្នកសារព័ត៌មាន និងបំបាក់ទឹកចិត្តពួកគេមិនឱ្យរាយការណ៍អំពីការពិត។[86]

***កាសែតបាយ៉ុងថាមស៍ (BAYONG TIMES)*** **និង** ***ខេមបូឌាធូដេ (CAMBODIA TODAY)៖*** កាលពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២ ក្រសួងព័ត៌មានបានប្រកាសដកហូតអាជ្ញាបណ្ណរបស់សារព័ត៌មាន *បាយ៉ុង ថាមស៍* និង *ខេមបូឌាធូដេ* ដោយចោទប្រកាន់ពួកគេថាបានបំពានក្រមសីលធម៌វិជ្ជាជីវៈអ្នកសារព័ត៌មាន និងកិច្ចសន្យា។ លោក តិល សាមុត ដែលជាចាងហ្វាង *ទូរទស្សន៍បាយ៉ុងថាមស៍* មានប្រសាសន៍ថា លោកជឿថា ការដកហូតនេះគឺជាការឆ្លើយតបទៅនឹងអត្ថបទមុនៗដែលចុះផ្សាយដោយ *បាយ៉ុងថាមស៍* ចោទប្រកាន់មន្ត្រីរដ្ឋាភិបាលអំពីអំពើពុករលួយ។[87] ស្រដៀងគ្នានេះដែរ និពន្ធនាយកកាសែត *ខេមបូឌាធូដេ* មានប្រសាសន៍ថា គាត់គិតថាអត្ថបទរិះគន់មួយដែលបានបោះពុម្ពផ្សាយកាលពីមួយខែមុន អំពីអំពើពុករលួយនៅក្នុងដំណើរការដេញថ្លៃនៅក្រសួងការងារ ដែលគាត់មិនព្រមដកអត្ថបទចេញបន្ទាប់ពីមន្ត្រីក្រសួងព័ត៌មានបានស្នើគាត់នោះ អាចជាមូលហេតុនៃការដកហូតអាជ្ញាបណ្ណប្រព័ន្ធផ្សព្វផ្សាយរបស់គាត់។[88]

**សួន វុត្ថា៖** មន្ត្រីនគរបាលចរាចរណ៍បានគំរាមចាប់ខ្លួនលោក សួន វុត្ថា ដែលជាអ្នកសារព័ត៌មាន និងចាត់វិធានការតាមផ្លូវច្បាប់កាលពីថ្ងៃទី១០ ខែមេសា ឆ្នាំ២០២២ បន្ទាប់ពីគាត់បានថតសកម្មភាពមន្ត្រីទទួលសំណូក ដោយធ្វើជាមើលមិនឃើញការបំពានច្បាប់ចរាចរណ៍នៅប៉ុស្តិ៍ត្រួតពិនិត្យក្នុងខេត្តកណ្តាល។ លោក សួន វុត្ថា ត្រូវបានឃាត់ខ្លួនសាកសួរអស់រយៈពេលជាងមួយម៉ោង។ អាជ្ញាធរក៏បានបញ្ជាឱ្យគាត់លុបវីដេអូដែលគាត់បានថត ហើយចុះហត្ថលេខាលើកិច្ចព្រមព្រៀងដោយនិយាយថាគាត់នឹង«បញ្ឈប់» ការថតសកម្មភាពរបស់អាជ្ញាធរ។ លោកអភិបាលស្រុកបានការពារសកម្មភាពរបស់នគរបាល និងស្តីបន្ទោសអ្នកសារព័ត៌មានថាមិនបានស្នើសុំ «ការសហការ» ពីអាជ្ញាធរនិងថាបាន *«លួចថត»* មន្ត្រី *«ដែលមិនបានដឹង*

[86] យុត សុគន្ធ "ក្រសួងព័ត៌មានកោះហៅម្ចាស់ប្រព័ន្ធផ្សព្វផ្សាយមកសាកសួរបន្ទាប់ពីបានផ្សព្វផ្សាយអំពើពុករលួយរបស់មន្ត្រីយោធា" (*វីអូឌីខ្មែរ*, ៦ វិច្ឆិកា ២០២១)។

[87] ណាត សុភាព "ក្រសួងព័ត៌មានដកហូតអាជ្ញាបណ្ណបោះពុម្ពផ្សាយឌីជីថលចំនួនបី" (*វីអូឌី*, ១៦ មីនា ២០២២)។

[88] ង៉ែ វណ្ណៃ "ប្រព័ន្ធផ្សព្វផ្សាយអនឡាញចំនួនបីត្រូវបានដកហូតអាជ្ញាបណ្ណ" (*សារព័ត៌មានខេមបូចា*, ២៥ មីនា ២០២២)។

*ខ្លួន*»។ ក្រោយមក អ្នកនាំពាក្យក្រសួងព័ត៌មានបានជំទាស់នឹងការលើកឡើងរបស់អភិបាលស្រុក ដោយលើកឡើងថា ជនណាម្នាក់អាចថតរូប ឬវីដេអូជាសាធារណៈ ហើយអាជ្ញាធរបានមើលរំលង និងរំលោភលើការងាររបស់អ្នកសារព័ត៌មាន។[89]

**ថៃ ប៊ុនរិទ្ធ៖** ផលិតករទូរទស្សន៍ TCN ត្រូវបានតុលាការខេត្តកណ្ដាល ចោទប្រកាន់ពីបទញុះញង់ឱ្យមានការរើសអើង និងបរិហារកេរ្តិ៍ជាសាធារណៈកាលពីថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២២ បន្ទាប់ពីគាត់បានផ្សាយផ្ទាល់តាមទំព័រហ្វេសប៊ុករបស់បណ្ដាញទូរទស្សន៍ TCN ដោយលើកឡើងថាអាជ្ញាធរខេត្តបានទទួលសំណូកមិនអើពើសកម្មភាពល្បែងស៊ីសងខុសច្បាប់។[90]

## *ការដាក់កំហិតខ្លួនឯង*

យោងតាមហេតុការណ៍ដូចបានគូសបញ្ជាក់នៅក្នុងផ្នែកនេះទាំងមូលបង្ហាញថា អ្នកសារព័ត៌មានគឺមិនមានសេរីភាពទៀតទេក្នុងការប្រមូលព័ត៌មាន និងរាយការណ៍អំពីបញ្ហាដែលរដ្ឋាភិបាលកំណត់ថាមានលក្ខណៈរសើប។ ជាលទ្ធផលនៃការបំភិតបំភ័យ ការគំរាមកំហែង និងការដាក់ទណ្ឌកម្មព្រហ្មទណ្ឌ ដែលអ្នកសារព័ត៌មានត្រូវទទួលរងដោយគ្រាន់តែបំពេញការងាររបស់ខ្លួន អ្នកជំនាញប្រព័ន្ធផ្សព្វផ្សាយជាច្រើនបានដាក់កំហិតខ្លួនឯង និងជៀសវាងការផ្សាយព័ត៌មានដែលអាចធ្វើឱ្យក្រុមឥស្សរជនកំពុងកាន់អំណាចខឹងសម្បារ។ ក្នុងចំណោមអ្នកសារព័ត៌មាន ១៨ នាក់ដែលបានផ្ដល់សម្ភាសសម្រាប់របាយការណ៍នេះ មាន ៧ នាក់រាយការណ៍ថា បានដាក់កំហិតខ្លួនឯង។

អ្នកសារព័ត៌មានទទួលការសម្ភាសន៍បាននិយាយថាខ្លួនបានបដិសេធក្នុងការសរសេរប្រធានបទទាំងឡាយដែលទាក់ទងនឹងនាយករដ្ឋមន្ត្រី និងក្រុមគ្រួសាររបស់លោក បញ្ហាដីធ្លី និង/ឬព្រៃឈើ ការរិះគន់អាជ្ញាធរ ការជួញដូរគ្រឿងញៀន និងបញ្ហានយោបាយដោយសារតែខ្លាចប៉ះពាល់ដល់អ្នកមានអំណាច។

## *ការវាយប្រហារ និងការគំរាមកំហែងប្រើអំពើហិង្សាលើរាងកាយលើអ្នកសារព័ត៌មាន*

ដោយមានតួនាទីជាអ្នកឃ្លាំមើល និងរាយការណ៍ អ្នកសារព័ត៌មានទូទាំងពិភពលោកតែងប្រឈមនឹងការវាយប្រហារ និងការគំរាមកំហែងដល់សុវត្ថិភាពរាងកាយ។ អ្នកសារព័ត៌មានចំនួនប្រាំពីរនាក់ដែលបានផ្ដល់សម្ភាសសម្រាប់របាយការណ៍នេះបានលើកឡើងថា ពួកគេមានការព្រួយបារម្ភអំពីសុវត្ថិភាពផ្ទាល់ខ្លួន និង/ឬក្រុមគ្រួសារ ដោយសារតែបំពេញការងាររបស់ខ្លួន។ អ្នកសារព័ត៌មានម្នាក់ទៀតបានលើកឡើងជាពិសេសថាគឺ *«ការគំរាមកំហែងដល់អាយុជីវិតអ្នកសារព័ត៌មាន»* ដែលជាការគំរាមកំហែងដ៏ធំបំផុតចំពោះសេរីភាពសារព័ត៌មាននៅកម្ពុជា។

89 ប៉ា សុខេង "អ្នកសារព័ត៌មានចោទថាត្រូវបានគេគំរាមកំហែងចំពោះការថតនគរបាលចរាចរណ៍យកលុយ" (*វីអូឌី,* ១៤ មេសា ២០២២)។

90 ប៊ុត រស្មីគង្គា "ផលិតករទូរទស្សន៍ត្រូវបានចោទប្រកាន់ពីបទបរិហារកេរ្តិ៍" (*ខ្មែរថាមស៍,* ៣០ ឧសភា ២០២២)។

ក្នុងអំឡុងពេលនៃការសរសេររបាយការណ៍ អ្នកសារព័ត៌មានម្នាក់ត្រូវបានទះកំផ្លៀង ខណៈដែលគាត់ត្រូវបានកងកម្លាំងអង្គភាពអង្គរក្សរបស់លោកនាយករដ្ឋមន្ត្រី ចាប់ខ្លួនដោយបង្ខំពីបទដឹកនាំការងារស៊ើបអង្កេត។[91] អ្នកសារព័ត៌មានម្នាក់ទៀតបានទទួលការគំរាមសម្លាប់ពីជនម្នាក់ បន្ទាប់ពីគាត់បានសរសេរអត្ថបទអំពីជម្លោះពាក់ព័ន្ធនឹងជននោះ។[92] អ្នកសារព័ត៌មានម្នាក់ក្នុងចំណោមអ្នកសារព័ត៌មានដែលបានសម្ភាស បានបង្ហើបប្រាប់ថា ពួកគាត់គឺជាជនរងគ្រោះនៃការវាយប្រហារជាច្រើនលើក រួមទាំងត្រូវបានម៉ូតូបុកក្នុងឧបទ្ទវហេតុចំនួនបីផ្សេងគ្នាជួបប្រទះអំពើហិង្សាពេលរាយការណ៍អំពីកូដកម្មនៅណាហ្គាវើលដ៍ ហើយមានមនុស្សលួចចូលផ្ទះរបស់ពួកគេជាដើម។ ការរឹតត្បិតមួយចំនួនដែលពួកគេបានជួបប្រទះដោយសារតែការបំពេញការងារសារព័ត៌មានរបស់ខ្លួន។

## *បញ្ហាប្រឈមរបស់អ្នកសារព័ត៌មានជាស្ត្រី*

ក្នុងចំណោមអ្នកសារព័ត៌មានជាស្ត្រីចំនួនប្រាំបីនាក់ដែលត្រូវបានសម្ភាសន៍សម្រាប់របាយការណ៍នេះ មាន៦ នាក់ប្រឈមនឹងការលំបាកក្នុងការអនុវត្តការងារជាអ្នកសារព័ត៌មានដោយសារតែយេនឌ័ររបស់ខ្លួន។ ការលំបាកទាំងនេះមានទម្រង់ជាច្រើន រាប់ចាប់ពីការបញ្ចេញមតិមិនសមរម្យពីអាជ្ញាធរ រហូតដល់ការបៀតបៀនផ្លូវភេទ និងបញ្ហាប្រឈមក្នុងការប្រមូលព័ត៌មាន។

អ្នកផ្តល់សម្ភាសម្នាក់បាននិយាយថា មន្ត្រីនគរបាលម្នាក់បានសួរនាងថា ហេតុអ្វីបានជាខ្លួនមកធ្វើជាអ្នកសារព័ត៌មាន បែរជាមិនធ្វើជាកម្មការិនីកាត់ដេរ ដែលជាអាជីពសម្រាប់ស្ត្រីភាគច្រើនទៅវិញ ? ម្នាក់ទៀតបានលើកឡើងអំពីករណីបៀតបៀនផ្លូវភេទពីសំណាក់ អ្នកសារព័ត៌មានជាបុរស ហើយបាននិយាយថា អ្នកសារព័ត៌មានជាបុរសតែងមើលងាយសមត្ថភាពអ្នកសារព័ត៌មានជាស្ត្រី។ អ្នកសារព័ត៌មានម្នាក់បានរាយការណ៍ថា មន្ត្រីរដ្ឋាភិបាលទំនងជាឆ្លើយសំណួររបស់អ្នកសារព័ត៌មានជាបុរសច្រើនជាងអ្នកសារព័ត៌មានជាស្ត្រី។ គាត់ក៏បានបន្ថែមថា អ្នកសារព័ត៌មានជាស្ត្រីប្រឈមនឹងបញ្ហានានា «ពេលធ្វើដំណើរតែម្នាក់ឯង» ដូចបានលើកឡើងស្រដៀងគ្នានេះដោយអ្នកសារព័ត៌មានម្នាក់ទៀតដែលបានសម្ភាស។ អ្នកផ្តល់សម្ភាសពីរនាក់ផ្សេងទៀតបានសម្តែងនូវអារម្មណ៍ស្រដៀងគ្នានេះ ដោយបានពោលថាអ្នកសារព័ត៌មានជាស្ត្រីជួបការលំបាកច្រើនជាងអ្នកសារព័ត៌មានជាបុរសក្នុងការប្រមូលព័ត៌មាននៅកន្លែងដែលនៅ«ឆ្ងាយពីផ្ទះ» ឬ «នៅពេលយប់ព្រលប់»។

តាមរយៈឧទាហរណ៍ទាំងនេះ ហាក់ដូចជាបង្ហាញឱ្យឃើញថា ផ្នត់គំនិតយេនឌ័រនៅតែបន្តឈរលើវិថីមួយដែលត្រូវមានការទទួលស្គាល់អ្នកសារព័ត៌មានជាស្ត្រីថាមានភាពស្មើគ្នានឹងអ្នកសារព័ត៌មានជាបុរស។ ចំពោះការគំរាមកំហែងប្រើអំពើហិង្សាលើយេនឌ័រ ទោះបីជាមិនមានភាពជាក់ច្បាស់ចំពោះវិស័យសារព័ត៌មានក៏ដោយ ក៏ហាក់ដូចជារារាំងអ្នកសារព័ត៌មានជាស្ត្រីក្នុងការបំពេញកិច្ចការស៊ើបអង្កេត និងប្រមូលព័ត៌មាន ដែលជាធាតុផ្សំដ៏សំខាន់មួយនៃការងាររបស់ខ្លួន។

---

[91] 2022). ឃួន ណារីម និងសុវណ្ណ ស្រីពេជ្យ "អ្នកសារព័ត៌មាន និងសកម្មជនបរិស្ថានត្រូវបានឃុំ វាយដំ" (*CamboJA News*, ១៦ សីហា ២០២២)។

[92] លាង យុន "ប្រយ័ត្ន! បើដើរឆ្លងកាត់ផ្ទះនោះ ហើយបើហ៊ានវាយផ្តេ ម្ចាស់ផ្ទៃនឹងសម្លាប់អ្នក" (*CEN*, ១៨ មករា ២០២២)។

### ៥.២. ស្ថានភាពនៃសេរីភាពខាងការបញ្ចេញមតិសម្រាប់អ្នកការពារសិទ្ធិមនុស្ស

*ការយាយីតាមប្រព័ន្ធតុលាការចំពោះអ្នកការពារសិទ្ធិមនុស្ស សម្រាប់ការអនុវត្តសិទ្ធិសេរីភាពខាងការបញ្ចេញមតិ*

ក្រៅពីអ្នកសារព័ត៌មាន ក្រុមអ្នកការពារសិទ្ធិមនុស្សនៅតែបន្តទទួលរងនូវការមិនអត់ឱនពីសំណាក់រដ្ឋាភិបាលចំពោះការរិះគន់ និងការមានទស្សនៈផ្ទុយគ្នានៅចន្លោះខែកញ្ញា ឆ្នាំ២០២១ ដល់ខែសីហា ឆ្នាំ២០២២ ហើយត្រូវបានដៅមុខសញ្ញាសម្រាប់ការអនុវត្តសិទ្ធិសេរីភាពខាងការបញ្ចេញមតិ ដើម្បីធ្វើការងារសិទ្ធិមនុស្សស្របច្បាប់។ ការយាយីតាមប្រព័ន្ធតុលាការពីសំណាក់តុលាការមិនឯករាជ្យ នៅតែជាការគំរាមកំហែងដ៏ធំបំផុតចំពោះសេរីភាពខាងការបញ្ចេញមតិរបស់ក្រុមអ្នកការពារសិទ្ធិមនុស្សនៅក្នុងប្រទេស នេះបើតាមការដកស្រង់សម្ដីរបស់អ្នកការពារសិទ្ធិមនុស្សដែលបានសម្ភាសន៍សម្រាប់របាយការណ៍នេះ គួបផ្សំជាមួយនឹងការឃ្លាំមើលពីសំណាក់រដ្ឋាភិបាល ដែលបង្កើតនូវបរិយាកាសដ៏គ្រោះថ្នាក់មួយក្នុងការអនុវត្តសេរីភាពខាងការបញ្ចេញមតិ។

ការបង្ក្រាបមកលើអ្នកការពារសិទ្ធិមនុស្ស កាន់តែមានសភាពខ្លាំងក្លាឡើងនៅចុងខែកក្កដា ឆ្នាំ២០២០ បន្ទាប់ពីមានការចាប់ខ្លួនលោក រ៉ុង ឈុន ដែលជាមេដឹកនាំសហជីពដ៏លេចធ្លោមួយពីបទបញ្ចេញមតិទាក់ទងនឹងបញ្ហាព្រំដែន កម្ពុជា-វៀតណាម តាមវិទ្យុ ដែលបញ្ហានេះនៅតែបន្តកើតមានក្នុងអំឡុងពេលនៃការសរសេររបាយការណ៍។ សកម្មជនបរិស្ថានមាតាធម្មជាតិកម្ពុជាមួយចំនួន ត្រូវបានផ្ដន្ទាទោសក្នុងអំឡុងពេលនៃការធ្វើរបាយការណ៍មុនដោយសារតែបានលើកឡើងពីក្ដីបារម្ភចំពោះបញ្ហាបរិស្ថាន និងការរំលោភលើធនធានធម្មជាតិនៅក្នុងប្រទេស ដែលនៅតែបន្តរងការយាយីតាមប្រព័ន្ធតុលាការ ហើយត្រូវបានតម្កល់ទោសដោយតុលាការជាន់ខ្ពស់។

យោងតាមទិន្នន័យដែលប្រមូលបានតាមរយៈការឃ្លាំមើលប្រព័ន្ធផ្សព្វផ្សាយបានបង្ហាញថា ការយាយីឥតឈប់ឈរ តាមប្រព័ន្ធតុលាការរបស់រដ្ឋាភិបាលទៅលើអ្នកការពារសិទ្ធិមនុស្ស នាំទៅដល់ការចាត់វិធានការផ្លូវច្បាប់លើអ្នកការពារសិទ្ធិមនុស្ស ១៣ នាក់ក្នុងនោះមានស្ត្រី ៤ នាក់ ដោយសារតែការអនុវត្តសេរីភាពខាងការបញ្ចេញមតិ នៅចន្លោះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២១ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២ មានដូចខាងក្រោម៖

- កោះហៅចំនួន ០៣ នាក់ ។
- សួរចម្លើយចំនួន ០៤ នាក់។
- ចាប់ខ្លួនចំនួន ០៤ នាក់។
- ឃាត់ខ្លួនចំនួន ០៤ នាក់។
- ចោទប្រកាន់ចំនួន ០៤ នាក់ ពីបទញុះញង់ ប្រកាសសេចក្ដីថ្លែងព័ត៌មានមិនពិត ឬបង្ករការខូចខាតទ្រព្យសម្បត្តិដោយចេតនា។
- កាត់ទោសចំនួន ០៤ នាក់ ពីបទញុះញង់ ប្រកាសព័ត៌មានមិនពិត បទបរិហារកេរ្តិ៍ដោយចេតនាមិនល្អ និងបទបរិហារកេរ្តិ៍ ឬការរំលោភបំពាន និង
- កាត់ទោសចំនួន ០៦ នាក់ ពីបទញុះញង់ដែលត្រូវបានតម្កល់ទោសដោយតុលាការជាន់ខ្ពស់។

ក្នុងអំឡុងពេលនៃការសរសេររបាយការណ៍ អ្នកការពារសិទ្ធិមនុស្សដែលដៅមុខសញ្ញា គឺសកម្មជនដីធ្លី ឬបរិស្ថានដែលឆ្លុះបញ្ចាំងពីការបង្រ្កាបកាន់តែខ្លាំងឡើងចំពោះអ្នកដែលនិយាយអំពីវិវាទដីធ្លី និងការបំផ្លិចបំផ្លាញបរិស្ថាននៅក្នុងព្រះរាជាណាចក្រ ដែលបញ្ហាពីរត្រូវបានចាត់ទុកថាជាបញ្ហារសើប ជាពិសេសដោយអាជ្ញាធរកម្ពុជា។

***អ្នកការពារសិទ្ធិមនុស្ស ០៤ នាក់ត្រូវបានកាត់ទោស ហើយអ្នកការពារសិទ្ធិមនុស្ស ០៦ នាក់ ត្រូវបានតុលាការជាន់ខ្ពស់តម្កល់ទោសចន្លោះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២១ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២ ដោយសារតែការអនុវត្តសេរីភាពខាងការបញ្ចេញមតិ៖***

**ចាន់ ធឿន** - កាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១ ចាន់ ធឿន ដែលជាសកម្មជននៃបណ្តាញសហគមន៍ព្រៃឡង់ ត្រូវបានសាលាដំបូងខេត្តកំពង់ធំ កាត់ទោសកំបាំងមុខ ដោយចោទប្រកាន់ពីបទប៉ុនប៉ងឃាតកម្មលើអ្នករកស៊ីម្នាក់ឈ្មោះ ប៉ាក់ យ៉ាងគួ ដែលបានប្តឹងគាត់ក្នុងឆ្នាំ២០២០។ បុរសរូបនោះបានចោទប្រកាន់ថា ធឿន ប៉ុនប៉ងចាក់គាត់កាលពីខែកក្កដា ឆ្នាំ២០២០ ក្នុងអំឡុងពេលមានជម្លោះ។ ការចោទប្រកាន់ទាំងនេះត្រូវបានមេធាវីការពារក្តីរបស់ ធឿន ចាត់ទុកថាជារឿងប្រឌិត ដោយបញ្ជាក់ថា ធឿន គ្រាន់តែព្យាយាមការពារខ្លួនពីការប៉ុនប៉ងវាយប្រហារពី យ៉ាងគួ ប៉ុណ្ណោះ។ ធឿន អះអាងថា ឈ្មោះយ៉ាងគួ បានយកកាំបិតគំរាមគាត់ បន្ទាប់ពីឃើញ ធឿន ថតរូបខ្លួនដឹកឈើក្នុងព្រៃការពារក្នុងស្រុកសណ្តាន់ ខេត្តកំពង់ធំ។ ចាន់ ធឿន ជឿជាក់ថា យ៉ាងគួ គឺជាឈ្មួញឈើ ហើយបានប្តឹងគាត់ជាការឆ្លើយតបនឹងការប៉ះទង្គិចគ្នាកាលពីខែកក្កដា ឆ្នាំ២០២០ និងការប៉ុនប៉ងរាយការណ៍ពីសកម្មភាពដឹកជញ្ជូនឈើខុសច្បាប់របស់ខ្លួន។ ចាន់ ធឿន បានបញ្ជាក់ថា គាត់ត្រូវគេចខ្លួនចេញពីផ្ទះនៅខែតុលា ឆ្នាំ២០២១ នៅពេលដែលកងរាជអាវុធហត្ថមកចាប់ខ្លួនមួយថ្ងៃក្រោយពេលដែលពីគាត់បានបង្ហោះរូបភាពនៅលើបណ្តាញហ្វេសប៊ុកអំពីការដឹកជញ្ជូនឈើ។[93] កាលពីថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១ សាលាដំបូងខេត្តកំពង់ធំ បានផ្តន្ទាទោស ចាន់ ធឿន ពីបទវាយប្រហារបន្ទាប់ពីទម្លាក់បទចោទពីប៉ុនប៉ងមនុស្សឃាត ទៅជាបទហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសហើយកាត់ទោសដាក់ពន្ធនាគាររយៈពេលពីរឆ្នាំ។ បើតាមមេធាវីរបស់ ធឿន តុលាការក៏បានព្យួរទោសផងដែរ។ ចាន់ ធឿន មិនបានបង្ហាញខ្លួនទេ ខណៈដែលគាត់កំពុងលាក់ខ្លួន ហើយបាននិយាយថា សេចក្តីសម្រេចនេះមានភាពអយុត្តិធម៌ ដោយសារគាត់ជាជនរងគ្រោះ មិនមែនជាអ្នកបំពាន ហើយឈ្មួញឈើបែរជាមិនត្រូវបានកាត់ទោសពីបទឧក្រិដ្ឋទៅវិញ។[94]

***សកម្មជនមាតាធម្មជាតិ៖* ឡុង គន្ធា, ភួន កែវរស្មី, ថុន រដ្ឋា, អេឡិចសាន់ដ្រូ ហ្គុនហ្សាឡេស-ដេវីដសុន** - កាលពីថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២១ សាលាឧទ្ធរណ៍ ភ្នំពេញបានតម្កល់ការផ្តន្ទាទោសឈ្មោះ ឡុង

[93] ឃួន ណារីម "សកម្មជនព្រៃឡង់ត្រូវបានកាត់ទោសពីបទ "ប៉ុនប៉ងឃាតកម្ម" បន្ទាប់ពីរាយការណ៍ពីបទល្មើសព្រៃឈើ (*សារព័ត៌មានខេមបូចា,* ១៦ កញ្ញា ២០២១)។
[94] ខាន់ លក្ខិណា "សកម្មជនព្រៃឡង់ ត្រូវបានសម្រេចព្យួរទោសរយៈពេលពីរឆ្នាំ" (*វីអូឌី,* ១២ តុលា ២០២១)។

គន្ធា, ថុន រដ្ឋា និង ភួន កែវរស្មី ប៉ុន្តែបានព្យួរទោសពន្ធនាគារដែលនៅសល់។[95] អ្នកទាំងបីត្រូវបានដោះលែងពីពន្ធនាគារនៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១ ប៉ុន្តែត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការរយៈពេល ៣ឆ្នាំ។[96] នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១ សាលាឧទ្ធរណ៍ក៏បានតម្កល់ការផ្តន្ទាទោស **អេឡិចសាន់ដ្រូ ហ្គុនហ្សាឡេស-ដេវីដសុន** ដែលជាសហស្ថាបនិកអង្គការមាតាធម្មជាតិកម្ពុជាផងដែរ។[97] នៅថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២២ តុលាការកំពូលបានតម្កល់សាលដីការបស់តុលាការជាន់ទាបដែលកាត់ទោសឈ្មោះ **អេឡិចសាន់ដ្រូ** ហ្គុនហ្សាឡេសដេវីដសុន កំបាំងមុខពីបទញុះញង់ និងផ្តន្ទាទោសគាត់ឱ្យជាប់ពន្ធនាគាររយៈពេល ២០ ខែ និងពិន័យជាប្រាក់ចំនួនបួនលានរៀល។[98] លោក ហ្គុនហ្សាឡេស-ដេវីដសុន មិនបានបង្ហាញខ្លួនក្នុងសវនាការទេ ដោយសារគាត់ត្រូវបានបដិសេធក្នុងការចូលប្រទេសកម្ពុជាជាបន្តបន្ទាប់ ចាប់តាំងពីការនិរទេសខ្លួនក្នុងអំឡុងឆ្នាំ២០១៥។ សកម្មជនទាំង ៤ រូបត្រូវបានកាត់ទោសពីបទញុះញង់កាលពីខែឧសភា ឆ្នាំ២០២១ ដោយសារការបង្ហោះព័ត៌មានតាមហ្វេសប៊ុកអំពីគម្រោងរៀបចំក្បួនដង្ហែដោយស្ត្រីម្នាក់ទៅកាន់គេហដ្ឋាននាយករដ្ឋមន្ត្រីក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងអំពីផលប៉ះពាល់បរិស្ថាននៃការចាក់បំពេញ ដីបឹងតាមោក។[99]



**រ៉ុង ឈុន** - នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២១ សាលាឧទ្ធរណ៍បានតម្កល់ការផ្តន្ទាទោសលោក រ៉ុង ឈុន ដែលជាមេដឹកនាំសហជីពដ៏លេចធ្លោ ប៉ុន្តែបានព្យួរទោសពន្ធនាគារដែលនៅសេសសល់ ជាហេតុធ្វើឱ្យគាត់ចេញពីពន្ធនាគារនៅថ្ងៃដដែល។ ទោះជាយ៉ាងណា លោក រ៉ុង ឈុន ត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការរយៈពេលបីឆ្នាំបន្ទាប់។[100] លោក រ៉ុង ឈុន ត្រូវបានចាប់ខ្លួនកាលពីខែកក្កដា ឆ្នាំ២០២០ ហើយត្រូវបានសាលាដំបូងរាជធានីភ្នំពេញ កាត់ទោសពីបទញុះញង់កាលពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២១ និងផ្តន្ទាទោសទោសឱ្យជាប់ពន្ធនាគាររយៈពេល ២ ឆ្នាំ ជុំវិញការលើកឡើងតាមវិទ្យុអំពីបញ្ហាព្រំដែនរវាងកម្ពុជា និងវៀតណាម។[101] ការចាប់ខ្លួនគាត់បានជំរុញឱ្យមានការចាប់ខ្លួនសកម្មជនដទៃទៀតពាក់ព័ន្ធការប្រមូលផ្តុំមទាមទារឱ្យមានការដោះលែង

---

95 ប៊ុត រស្មីគង្គា "ការកាត់ទោសសកម្មជនមាតាធម្មជាតិ ត្រូវបានតម្កល់ សម្រាលទោស" ( *ខ្មែរថាមស៍,* ថ្ងៃទី ៥ ខែវិច្ឆិកា ឆ្នាំ ២១)។

96 មេច. ដារ៉ា & អូ. សូនី, "សកម្មជនមាតាធម្មជាតិចំនួន ១៨ នាក់ រួមទាំងលោក លោក រ៉ុង ឈុន ត្រូវបានដោះលែងតាម សាលក្រមមិនច្បាស់លាស់ បានជួបជុំគ្នា" ( *វីអូឌី,* ១២ វិច្ឆិកា ២០២១)។

97 ប៊ុត រស្មីគង្គា "ការកាត់ទោសលើអាឡិកសាន់ដ្រូ ហ្គុងហ្សាឡេស-ដេវីដសាន់ (Alexandro Gonzalez-Davidson) ត្រូវបានតម្កល់ដោយសាលាឧទ្ធរណ៍" ( *ខ្មែរថាមស៍* ,១៣ វិច្ឆិកា ២០២១)។

98 វីអូឌី, "ព័ត៌មានសង្ខេប៖ មេបញ្ជាការកងទ័ពដឹកនាំសកម្មភាពក្នុងព្រឹត្តិការណ៍សេរីភាពសារព័ត៌មានមាតាធម្មជាតិនៅតុលាការកំពូល" ( *វីអូឌី,* ០៣ ឧសភា ២០២២)។

99 ឃួន ណារីម "សកម្មជនមាតាធម្មជាតិ ត្រូវបានរកឃើញថាមានពិរុទ្ធដោយកាត់ឱ្យជាប់ពន្ធនាគារពីបទរៀបចំគម្រោងដើរដង្ហែស្ត្រីមួយ", ( *សារព័ត៌មានខេមបូចា,* ៥ ឧសភា ២០២១) វិទ្យុអាស៊ីសេរី "សកម្មជនបរិស្ថានកម្ពុជាត្រូវបានចាប់ខ្លួនមុនការតវ៉ាជុំវិញការអភិវឌ្ឍបឹង" ( *វិទ្យុអាស៊ីសេរី,* ថ្ងៃទី ០៣ កញ្ញា ២០២០)។

100 វិទ្យុអាស៊ីសេរី "អាជ្ញាធរកម្ពុជាដោះលែងសហជីពកម្មករដែលជារឿងមួយគួរឱ្យភ្ញាក់ផ្អើល" ( *វិទ្យុអាស៊ីសេរី,* ១២ វិច្ឆិកា ២០២១)។

101 អ៊ុច សូនី "ព័ត៌មានបច្ចុប្បន្នភាព៖ លោក រ៉ុង ឈុន ត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគាររយៈពេលពីរឆ្នាំពីបទអត្ថាធិប្បាយអំពីប្រទេសវៀតណាម" ( *វីអូឌី,* ១៨ សីហា ២០២១)។

រូបលោកពីពន្ធនាគារ[102] ដែលគូសបញ្ជាក់ពីការបង្ក្រាបកាន់តែខ្លាំងឡើងពីសំណាក់រដ្ឋាភិបាលមកលើក្រុមអ្នកការពារសិទ្ធិមនុស្ស ដោយសារតែការអនុវត្តសេរីភាពមូលដ្ឋាន។[103]

**រឿន វាសនា៖** កាលពីថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២២ សាលាដំបូងរាជធានីភ្នំពេញបានកាត់ទោសលោក រឿន វាសនា ដែលជាសកម្មជនព្រៃឡង់ និងជាអតីតសមាជិកគណបក្សសង្គ្រោះជាតិ ឱ្យជាប់ពន្ធនាគាររយៈពេល ២ ឆ្នាំ និងពិន័យជាប្រាក់ចំនួនពីរលានរៀល (៥០០ ដុល្លារ)។[104] ការផ្តន្ទាទោសលើរូបគាត់ដោយសារគាត់បានបង្ហោះកំណាព្យនៅលើទំព័រហ្វេសប៊ុករបស់នាយករដ្ឋមន្ត្រី ដោយបានរិះគន់មេដឹកនាំប្រទេសថាបានអនុញ្ញាតឱ្យមានការកាប់បំផ្លាញព្រៃឈើរបស់កម្ពុជា។[105] វាសនា បានស្នាក់នៅក្នុងប្រទេសថៃ ប៉ុន្តែត្រូវបានអាជ្ញាធរថៃចាប់ខ្លួន និងនិរទេសមកកម្ពុជាវិញកាលពីខែវិច្ឆិកា ឆ្នាំ២០២១ បន្ទាប់ពីនាយករដ្ឋមន្ត្រីកម្ពុជាហៅ កំណាព្យនោះថាមានភាពជ្រុលនិយម ហើយបញ្ជាឱ្យចាប់ខ្លួន។[106] វាសនា ហាក់ដូចជាមិនមានមេធាវីតំណាងខ្លួនទេ ដោយសារតុលាការមិនបានជូនដំណឹងអំពីសវនាការដល់មេធាវីរបស់ខ្លួន។[107] ការផ្តន្ទាទោសលើរូបគាត់ត្រូវបានសាលាឧទ្ធរណ៍ក្រុងភ្នំពេញតម្កល់ទោសនៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២។[108]

**ដេត ហួរ៖** កាលពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២២ អ្នកស្រី ដេត ហួរ ដែលជាតំណាងសហគមន៍ឃុំជីខលើ ស្រុកស្រែអំបិល ខេត្តកោះកុង ត្រូវបានផ្តន្ទាទោសពីបទបង្ខូចកេរ្តិ៍ និងបរិហារកេរ្តិ៍ដោយចេតនាមិនល្អ ហើយត្រូវបានតុលាការខេត្តកោះកុង ផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល ១ ឆ្នាំ និងពិន័យជាប្រាក់ចំនួន ២លានរៀល (៥០០ ដុល្លារ)។ ទោះជាយ៉ាងណា គាត់មិនត្រូវបានឃុំខ្លួនទេ ដោយសារតុលាការមិនបានចេញដីកាបង្គាប់ឱ្យចាប់ខ្លួន។ ពាក្យបណ្តឹងដែលឈានដល់ការផ្តន្ទាទោសអ្នកស្រី ហួរ បានធ្វើឡើងដោយឧកញ៉ា ហេង ហ៊ុយ។ អ្នកស្រី ហួរ បានរាយការណ៍ថា ពាក្យបណ្តឹងបរិហារកេរ្តិ៍នេះធ្វើឡើងបន្ទាប់ពីអ្នកស្រី ហួរ បានបង្ហោះរូបថតលោកឧកញ៉ា និងសាររិះគន់ចំពោះការទន្ទ្រានយកដីសហគមន៍របស់អ្នកស្រី។ លោក ហេង ហ៊ុយ ត្រូវបានគេរាយការណ៍ថា បានដាក់ពាក្យបណ្តឹងលើសមាជិកសហគមន៍ផ្សេងទៀតដែលបានធ្វើការតវ៉ាប្រឆាំងនឹងក្រុមហ៊ុនរបស់គាត់ថាបានទន្ទ្រានយកដីរបស់ពួកគេ។ ប្រជាពលរដ្ឋរាប់រយគ្រួសារមកពីឃុំជីខលើ និងឃុំជីខក្រោម មានជម្លោះដីធ្លីជាមួយឈ្មោះហេង ហ៊ុយ តាំងពីឆ្នាំ ២០០៧ មកម្ល៉េះ។ គ្រួសាររងគ្រោះបានធ្វើដំណើរមករាជធានីភ្នំពេញ ដើម្បីប្តឹងតវ៉ានិងស្វែងរកកិច្ចអន្តរាគមន៍ពីក្រសួងដែនដីជាច្រើនដងនាពេល

102 ម.ស.ម.ក, "ការកំណត់ពេលវេលាសម្រាប់សកម្មជនដែលត្រូវបានចាប់ខ្លួនពីបទធ្វើការតវ៉ាទាមទារឱ្យមានការដោះលែងលោក រ៉ុង ឈុន," (*ម.ស.ម.ក,* កក្កដា ២០២១)។

103 របាយការណ៍ប្រចាំឆ្នាំស្តីពីសេរីភាពខាងការបញ្ចេញមតិរបស់ ម.ស.ម.ក ឆ្នាំ ២០២០-២០២១។

104 ខាន់ លក្ខិណា "អ្នករិះគន់រដ្ឋាភិបាលត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគាររយៈពេលពីរឆ្នាំ" (*វីអូឌី,* ០៣ កុម្ភៈ ២០២១)។

105 វិទ្យុអាស៊ីសេរី, "ហ៊ុន សែននៅកម្ពុជាបញ្ជាឱ្យចាប់ខ្លួនសកម្មជននិរទេសខ្លួនពីបទតែងកំណាព្យ" (*វិទ្យុអាស៊ីសេរី,* ១៣ តុលា ២០២១)។

106 ត្រាន់ តិកសេង (Tran Techseng), "សកម្មជនបក្សប្រឆាំងពីរនាក់ត្រូវបានធ្វើបត្យាប័នពីប្រទេសថៃ" (*វីអូឌី,* ១១ វិច្ឆិកា ២០២១)។

107 ខាន់ លក្ខិណា "អ្នករិះគន់រដ្ឋាភិបាលត្រូវបានផ្តន្ទាទោសឱ្យជាប់ពន្ធនាគាររយៈពេលពីរឆ្នាំ" (វីអូឌី, ៣ កុម្ភៈ ២០២២)។.

108 ប៊ុត រស្មីគង្គា "សាលាឧទ្ធរណ៍តម្កល់សាលក្រមលើសំណុំរឿងសកម្មជនព្រៃឡង់" (*ខ្មែរថាមស៍,* ១៦ ឧសភា ២០២២)។

កន្លងមក។ ប៉ុន្តែនៅឆ្នាំ២០១៩ ក្រសួងដែនដីបានច្រានចោលពាក្យបណ្ដឹងតវ៉ារបស់សហគមន៍ ហើយបានអំពាវនាវឱ្យចាត់វិធានការផ្លូវច្បាប់ចំពោះតំណាងសហគមន៍ពីបទញុះញង់ឱ្យតវ៉ា។[109]

**ចេន ប៉ារ៉ុង៖** - នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២២ ចេន ប៉ារ៉ុង ដែលជាអ្នកជួយសង្គ្រោះការជួញដូរមនុស្សមកពីអង្គការសប្បុរសធម៌កម្ពុជា-ចិន ត្រូវបានផ្តន្ទាទោសពីបទញុះញង់ឱ្យមានការរើសអើង និងផ្តល់សេចក្តីប្រកាសមិនពិត ហើយត្រូវបានតុលាការខេត្តព្រះសីហនុកាត់ទោសឱ្យជាប់ពន្ធនាគាររយៈពេលពីរឆ្នាំ។ គាត់ក៏ត្រូវបានបង្គាប់ឱ្យបង់ប្រាក់ពិន័យចំនួន ៤ លានរៀល (១.០០០ ដុល្លារ) ផងដែរ។[110] ចេន ត្រូវបានចាប់ខ្លួន និងចោទប្រកាន់កាលពីខែមីនា ឆ្នាំ២០២២ រួមជាមួយនឹងជំនួយការរបស់គាត់ វេជ្ជបណ្ឌិត និងជនរងគ្រោះពីការជួញដូរម្នាក់ បន្ទាប់ពីគាត់បានប្រាប់ប្រព័ន្ធផ្សព្វផ្សាយថា ពួកគេត្រូវបានបង្ខំឱ្យបូមឈាមបន្ទាប់ពីខ្លួនបានបដិសេធធ្វើការនៅក្នុងទីតាំងធ្វើសកម្មភាពឆបោកមួយក្នុងខេត្តព្រះសីហនុ ជារឿងមួយដែលទាក់ទាញចំណាប់អារម្មណ៍របស់ប្រព័ន្ធផ្សព្វផ្សាយបរទេស ប៉ុន្តែអាជ្ញាធរកម្ពុជាបែរចាត់ទុកថាជារឿងប្រឌិតទៅវិញ។[111]

អ្នកការពារសិទ្ធិមនុស្សចំនួនបីនាក់ក្នុងចំណោមប្រាំនាក់ ដែលបានផ្តល់សម្ភាសសម្រាប់របាយការណ៍នេះ បានរាយការណ៍ថាបានជួបប្រទះការរឹតត្បិត ឬរំលោភលើសេរីភាពខាងការបញ្ចេញមតិពីសំណាក់អាជ្ញាធរខណៈដែលអនុវត្តការងារតស៊ូមតិ។ ទោះបីជាយ៉ាងណា មិនមានអ្នកណាម្នាក់ដាក់ពាក្យបណ្ដឹងទៅស្ថាប័នពាក់ព័ន្ធ ឬតុលាការទេ។ ម្នាក់ក្នុងចំណោមអ្នកដែលបានធ្វើសម្ភាសបានពន្យល់ថា គាត់ត្រូវបានអាជ្ញាធរចោទប្រកាន់ថាបានញុះញង់ប្រជាពលរដ្ឋ បន្ទាប់ពីគាត់បានជួបជាមួយសហគមន៍ដីធ្លីដែលជាផ្នែកនៃការងាររបស់ខ្លួនដើម្បីពិភាក្សាអំពីវិវាទដីធ្លីដែលរងការប៉ះពាល់។ គាត់ត្រូវបានគេគំរាមចាប់ខ្លួន ហើយត្រូវទៅលាក់ខ្លួនមួយរយៈដើម្បីសុវត្ថិភាពផ្ទាល់ខ្លួន។ គាត់បានលើកឡើងថា បានរាយការណ៍ពីស្ថានភាពរបស់ខ្លួនទៅការិយាល័យឧត្តមស្នងការរបស់អង្គការសហប្រជាជាតិប្រចាំកម្ពុជា។ អ្នកផ្តល់សម្ភាសម្នាក់ទៀតបានរាយការណ៍ថា នៅឆ្នាំ២០១៩ ខណៈ ដែលគាត់កំពុងបើកវគ្គបណ្តុះបណ្តាលនៅខេត្តសៀមរាប អាជ្ញាធរបានបង្ហាញខ្លួន និងបិទវគ្គបណ្តុះបណ្តាល។ គាត់ក៏បាននិយាយដែរថា មិត្តភក្តិរបស់ខ្លួនដែលជាមន្ត្រីរដ្ឋាភិបាលបានប្រាប់គាត់ថាគាត់ស្ថិតនៅក្នុងមុខសញ្ញារបស់រដ្ឋាភិបាល និងមានឈ្មោះក្នុងបញ្ជីខ្មៅ ដែលជាគោលដៅរបស់រដ្ឋាភិបាល។ អ្នកសម្ភាសន៍ទីបីបាននិយាយថា ពួកគេបានជួបប្រទះការរឹតត្បិតលើសេរីភាពខាងការបញ្ចេញមតិ ជាពិសេសការកោះហៅ និងការសាកសួរពីសំណាក់អាជ្ញាធរមូលដ្ឋាន ពេលខ្លះបន្ទាប់ពីបញ្ចេញមតិ។ អ្នកការពារសិទ្ធិមនុស្សទីបួនដែលបាន

---

109 យុត សុគន្ធ "អ្នកតវ៉ាប្រឆាំងរឿងដីធ្លីនៅខេត្តកោះកុងត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគារ ប៉ុន្តែមិនបានឃុំខ្លួន" (*វីអូឌី*, ២០ កក្កដា ២០២២)។

110 ម៉ិច ដារ៉ា "ប្រពន្ធនិយាយថាអ្នកសង្គ្រោះការជួញដូរត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគាររយៈពេលពីរឆ្នាំ" (*វីអូឌី*, ៣០ សីហា ២០២២)។ តេង យ៉ាលីវ៉ូហ្សី "មនុស្សបួននាក់ត្រូវបានចោទប្រកាន់ពាក់ព័ន្ធនឹងការបោកបញ្ឆោតជួញដូរឈាម" (Cambodianess, ៤ មីនា ២០២២)

111 ម៉ិច ដារ៉ា "អ្នកជួយសង្គ្រោះពីការជួញដូរមនុស្សត្រូវបានចោទប្រកាន់បណ្តោះអាសន្នពីបទញុះញង់" (*វីអូឌី*, ០៣ មីនា ២០២២)។

សម្ភាស បាននិយាយថាពួកគេមិនជួបប្រទះការរឹតត្បិត ឬការរំលោភលើសេរីភាពខាងការបញ្ចេញមតិពីសំណាក់អាជ្ញាធរទេ ប៉ុន្តែបានទទួលការគំរាមកំហែងពីប្រជាពលរដ្ឋផ្សេងទៀត ចំពោះការសម្តែងមតិផ្ទាល់ខ្លួនអំពីសិទ្ធិរបស់អ្នកស្រឡាញ់ភេទដូចគ្នា ដែលពួកគេបានប្តឹង។ ទោះបីជាអ្នកសម្ភាសន៍ចុងក្រោយមិនបានរាយការណ៍ថាបានជួបប្រទះការរឹតត្បិត ឬរំលោភលើសេរីភាពបញ្ចេញមតិពីសំណាក់អាជ្ញាធររដ្ឋមកទល់ពេលនេះក៏ដោយ ប៉ុន្តែបាននិយាយថា មន្ត្រីរដ្ឋាភិបាលដែលខ្លួនស្គាល់ បានណែនាំកុំឱ្យចូលរួមជាមួយអង្គការដែលខ្លួនកំពុងបម្រើការព្រោះពួកគេអាចនឹងប្រឈមមុខនឹងបញ្ហា ហើយនឹងត្រូវគេចោទថាជាអ្នកប្រឆាំង។

### *ការវាយប្រហារលើរូបរាងកាយលើអ្នកការពារសិទ្ធិមនុស្ស*

បន្ថែមពីលើការយាយីតាមប្រព័ន្ធតុលាការ ដែលពួកគាត់ប្រឈមមុខជាប្រចាំ ក្រុមអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា ធ្វើប្រតិបត្តិការក្នុងបរិយាកាសមួយដែលមានគ្រោះថ្នាក់ និងគ្មានសុវត្ថិភាព។ ក្នុងអំឡុងពេលនៃរបាយការណ៍នេះ មានការកត់ត្រានូវការវាយប្រហារលើរាងកាយចំនួនពីរលើកមកលើអ្នកការពារសិទ្ធិមនុស្សដែលសុទ្ធសឹងជាស្ត្រី ដូចបានរៀបរាប់ខាងក្រោម៖

**ទូច ស្រីនិច** - កាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២១ កញ្ញា ទូច ស្រីនិច ដែលជាសកម្មជនខ្មែរថាវរៈ ត្រូវបានជនមិនស្គាល់មុខជាច្រើននាក់វាយប្រហារ ខណៈដែលគាត់កំពុងបើកម៉ូតូតាមផ្លូវ ក្នុងសង្កាត់បឹងត្របែក រាជធានីភ្នំពេញ។ ជនសង្ស័យបានជិះម៉ូតូទៅបុកម៉ូតូគាត់ បណ្តាលឱ្យធ្លាក់ពីលើម៉ូតូ។ គាត់បានរងរបួសធ្ងន់ត្រង់ក្បាល ដៃ និងជើង ប៉ុន្តែមិនអាចទៅព្យាបាលនៅមន្ទីរពេទ្យបានទេ ដោយសារគាត់មិនមានលទ្ធភាពបង់ថ្លៃថែទាំ។ ក្រោយមក ស្រីនិច រាយការណ៍ថា ខ្លួនបានកត់សម្គាល់ឃើញមានគេតាមដានសកម្មភាពរបស់ខ្លួន មុនពេលគាត់ត្រូវបានគេវាយប្រហារបួនថ្ងៃ។ ការវាយប្រហារនេះបានកើតឡើងបន្ទាប់ពីគាត់បានផ្តល់បទសម្ភាសន៍ជាមួយវិទ្យុអាស៊ីសេរី កាលពីថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២១ ដោយគាត់ បានធ្វើអត្ថាធិប្បាយអំពីការរឹតត្បិត និងការធ្វើទុក្ខបុកម្នេញលើសកម្មជនយុវជននៅកម្ពុជា។ ថ្វីត្បិតតែរងការវាយប្រហារលើរាងកាយក៏ដោយ ទូច ស្រីនិច បានលើកឡើងថា ខ្លួននៅតែប្តេជ្ញាបន្តការពារផលប្រយោជន៍សង្គម។[112]

**អេង ម៉ាឡៃ៖** កាលពីថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២ យុវជនសកម្មកញ្ញា អេង ម៉ាឡៃ បានរងរបួសធ្ងន់ត្រង់ក្បាល កដៃ និងស្មាខាងឆ្វេង បន្ទាប់ពីជនមិនស្គាល់មុខជិះម៉ូតូបុកនាងពីក្រោយ នៅចំណុចរង្វង់មូលក្នុងរាជធានីភ្នំពេញ។ គាត់បានប្រាប់ថាគេសើចដាក់ខ្លួនមុនពេលបើកគេចពីកន្លែងកើតហេតុ។ គាត់ត្រូវបានព្យាបាល និងពិនិត្យជំងឺដោយវេជ្ជបណ្ឌិតរបស់អង្គការសិទ្ធិមនុស្សក្នុងស្រុក។ អេង ម៉ាឡៃ បានចាត់ទុកការវាយប្រហារនេះថាជាការធ្វើទុក្ខបុកម្នេញលើការបន្តសកម្មភាពរបស់ខ្លួន។ ការវាយប្រហារនេះបានកើតឡើងប៉ុន្មានខែបន្ទាប់ពីខ្លួនត្រូវបានដោះលែងពីពន្ធនាគារក្នុងខែវិច្ឆិកា ឆ្នាំ២០២១ បន្ទាប់ពីជាប់ពន្ធនាគារជាងមួយឆ្នាំដោយសារតែចូលរួមក្នុងការជួបប្រជុំដោយសន្តិវិធីក្នុងឆ្នាំ២០២០ ដើម្បីទាមទារឱ្យមានការដោះលែង

[112] វិទ្ធី "សកម្មជនយុវជនខ្មែរថាវរៈ ត្រូវជនមិនស្គាល់មុខបើកម៉ូតូបុកបណ្តាលឲ្យរងរបួសធ្ងន់" (*វិទ្យុអាស៊ីសេរី,* ២៧ កញ្ញា ២០២១)។

លោក វ៉ុង ឈុន ពីពន្ធនាគារ។ អេង ម៉ាឡៃ ត្រូវបានគេស្គាល់ថាជាសកម្មជនដែលនិយាយឥតសំចៃ។ ក្រោយពីចេញពីពន្ធនាគារភ្លាម គាត់បានប្រាប់ប្រព័ន្ធផ្សព្វផ្សាយថា ខ្លួននៅតែមិនរួញរា និងមិនភ័យខ្លាចឡើយ។ គាត់បានបន្ថែមទៀតថា[113] *«ខ្ញុំត្រូវតែហ៊ាននិយាយពីការពិតដែរ ហើយហ៊ានស្វែងរកអ្វីដែលអាក្រក់ ហើយផ្លាស់ប្តូរទៅជាល្អ [...] បើយើងមិនហ៊ាននិយាយ អ្នកផ្សេងក៏មិនហ៊ាននិយាយដែរ»*។ គាត់បញ្ជាក់ជាថ្មីពីការប្តេជ្ញាចិត្តក្នុងការបន្តសកម្មភាពរបស់ខ្លួន បើទោះបីជាខ្លួនរងការវាយប្រហារក៏ដោយ។[114]

ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២ គឺជាការប្រារព្ធខួបលើកទី ១០ នៃឃាតកម្មលើលោក ឈុត វុទ្ធី សកម្មជនបរិស្ថានដែលត្រូវបានបាញ់សម្លាប់ខណៈដែលលោកនៅជាមួយនឹងអ្នកសារព័ត៌មានពីរនាក់ដែលស៊ើបអង្កេតបទល្មើសព្រៃឈើនៅជិតតំបន់ការពារក្នុងខេត្តកោះកុង។ លោក វុទ្ធី ដែលធ្លាប់ជាប្រធានអង្គការក្រុមអ្នកការពារធនធានធម្មជាតិ គឺជាជនល្បីល្បាញក្នុងការចូលរួមការពារព្រៃឈើ និងធនធានធម្មជាតិរបស់កម្ពុជា ព្រមទាំងបង្ហាញពីបទល្មើសបរិស្ថាននានា ដែលពាក់ព័ន្ធនឹងអាជ្ញាធរកម្ពុជាផងដែរ។ សំណុំរឿងរបស់គាត់ត្រូវបានតុលាការខេត្តកោះកុងប្រកាសបិទបញ្ចប់ភ្លាមៗកាលពីខែតុលា ឆ្នាំ២០១២ ដោយមិនមានការស៊ើបអង្កេតប្រកបដោយ តម្លាភាព និងឯករាជ្យណាមួយធ្វើឡើងដោយអាជ្ញាធរឡើយធ្វើឱ្យលោក វុទ្ធី និងក្រុមគ្រួសារ មិនទទួលបានយុត្តិធម៌។[115] ដប់ឆ្នាំក្រោយមក ក្រុមសង្គមស៊ីវិលកម្ពុជាបានបន្តអំពាវនាវជាថ្មីដល់ស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធ ធ្វើការស៊ើបអង្កេតដ៏គួរឱ្យទុកចិត្ត និងហ្មត់ចត់ ដើម្បីនាំជនដៃដល់ក្នុងអំពើឃាតកម្មរបស់គាត់មកកាត់ទោស។[116]

ដូចគ្នានេះដែរ ខែកក្កដា ឆ្នាំ២០២២ គឺជាខួប ៦ ឆ្នាំ នៃការសម្លាប់លោក កែម ឡី ដែលជាអ្នកអត្ថាធិប្បាយនយោបាយដ៏លេចធ្លោ និងជាអ្នកការពារសិទ្ធិមនុស្ស។ សកម្មជនដែលគេស្គាល់ថានិយាយអ្វីដែលអ្នកដទៃមិនហ៊ាននិយាយនោះ ត្រូវបានគេបាញ់សម្លាប់នៅក្នុងស្ថានីយប្រេងឥន្ធនៈមួយកន្លែងក្នុងរាជធានីភ្នំពេញកាលពីខែកក្កដា ឆ្នាំ២០១៦ ដោយមិនមានការស៊ើបអង្កេតហ្មត់ចត់ និងឯករាជ្យ ហើយឃាតករដែលសម្លាប់គាត់មិនទាន់ត្រូវបានគេនាំខ្លួនមកកាត់ទោសនៅឡើយទេ។[117] ករណីមិនទាន់ដោះស្រាយ ឬមិនទាន់ដោះស្រាយគួរជាទីពេញចិត្តទាំងពីរនេះ គឺជាការរំឭកដ៏ឈឺចាប់នៃគ្រោះថ្នាក់ដែលអ្នកការពារសិទ្ធិមនុស្ស បន្តទទួលរងដោយសារការបំពេញការងារស្របច្បាប់និងអនុវត្តសេរីភាពមូលដ្ឋានរបស់ខ្លួន ហើយអំពើនិទណ្ឌភាពដែលបន្តញាំញីកម្ពុជា ព្រមទាំងធ្វើឱ្យមានការបន្តវាយប្រហារមកលើអ្នកការពារសិទ្ធិមនុស្ស។

---

113 អ៊ុច សុនី "សកម្មជនម្នាក់ទៀតដែលត្រូវបានដោះលែង៖ "បើយើងមិនហ៊ាននិយាយទេ អ្នកផ្សេងក៏មិនហ៊ាននិយាយដែរ" (*វីអូឌី,* ៨ វិច្ឆិកា ២០២១)។

114 ទីន "ជនមិនស្គាល់អត្តសញ្ញាណប៉ុនប៉ងសម្លាប់អ្នកជិះម៉ូតូនៅភ្នំពេញ បណ្តាលឱ្យរបួសធ្ងន់" (*វិទ្យុអាស៊ីសេរី,* ១៩ មេសា ២០២២)។

115 ម.ស.ម.ក "សេចក្តីប្រកាសព័ត៌មាន៖ ពីរឆ្នាំទៀត ម.ស.ម.ក កាន់ទុក្ខលោក ឈុត វុទ្ធី ដែលជាសកម្មជនបរិស្ថាន និងថ្កោលទោសចំពោះការបន្តវប្បធម៌នៃអំពើហិង្សា និងនិទណ្ឌភាពនៅកម្ពុជា" (*ម.ស.ម.ក,* ២៦ មេសា ២០១៤)។

116 អង្គការសង្គមស៊ីវិល "លិខិតចំហដើម្បីប្រារព្ធខួប ១០ឆ្នាំនៃឃាតកម្មលើលោក ឈុត វុទ្ធី" (*ម.ស.ម.ក,* ២៦ មេសា ២០២២)។

117 ម.ស.ម.ក, ក្រាហ្វិកព័ត៌មាន "និទណ្ឌភាពនៅកម្ពុជា", (*ម.ស.ម.ក,* កក្កដា ២០២១)។

ជាលទ្ធផល អ្នកការពារសិទ្ធិមនុស្សជាច្រើន មិនមានអារម្មណ៍សេរីក្នុងការអនុវត្តការងាររបស់ខ្លួនដោយសេរី និងខ្លាចរងការប៉ះពាល់។ អ្នកការពារសិទ្ធិមនុស្សចំនួន ០៤ នាក់ក្នុងចំណោម ០៥ នាក់ដែលបានសម្ភាសបានរាយការណ៍ថាកំពុងប្រឈមមុខនឹងការព្រួយបារម្ភចំពោះសុវត្ថិភាពរាងកាយ នៅពេលធ្វើការងារសិទ្ធិមនុស្ស និងមានការប្រុងប្រយ័ត្នជាពិសេសចំពោះអ្វីដែលខ្លួនសរសេរ ឬអ្វីដែលខ្លួននិយាយទៅកាន់អ្នកសារព័ត៌មានជាពិសេសទាក់ទងនឹងរឿងនយោបាយ។ មានម្នាក់បានលើកឡើងថាឃាតកម្មជាកង្វល់មួយចំពោះពួកគេ។ ទោះយ៉ាងណា អ្នកការពារសិទ្ធិមនុស្សទីប្រាំដែលបានសម្ភាសន៍បាននិយាយថា ពួកគេមិនភ័យខ្លាចចំពោះការអនុវត្តសេរីភាពខាងការបញ្ចេញមតិទេ ដោយសារតែបានការយល់ដឹងច្រើនអំពីសិទ្ធិមនុស្ស និងមានបណ្ដាញគាំទ្រដែលបានបង្កើតឡើង។ ពួកគេបានបង្ហាញថាអាចឆ្លើយសំណួរសម្ភាសន៍របស់អ្នកសារព័ត៌មានដោយមិនខ្លាចមានប្រតិកម្មតបតឡើយ។

បរិយាកាសដែលមិនមានសុវត្ថិភាពនេះ បានធ្វើឱ្យអ្នកការពារសិទ្ធិមនុស្សជាច្រើនសម្របខ្លួនដើម្បីអាចបន្តអនុវត្តការងារដ៏មានសារៈសំខាន់តាមវិធីដែលមានសុវត្ថិភាពបំផុត។ អ្នកដែលបានផ្ដល់សម្ភាសម្នាក់បានរាយការណ៍ថា មិនដែលសរសេរព័ត៌មានបង្ហោះអំពីបញ្ហានយោបាយនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គមរបស់ខ្លួន ឬមានការប្រុងប្រយ័ត្ននៅពេលថតរូបជាមួយសមាជិកគណបក្សប្រឆាំង ខណៈដែលគាត់ចង់រក្សាភាពអព្យាក្រឹត។ អ្នកផ្ដល់សម្ភាសម្នាក់ទៀតបាននិយាយថា ត្រូវមានការប្រុងប្រយ័ត្នជាពិសេសនៅពេលធ្វើការលើករណីពាក់ព័ន្ធនឹងសកម្មជនគណបក្សប្រឆាំង ដែលជាប់ពន្ធនាគារ។ ការសម្របខ្លួនផ្សេងទៀតដែលអ្នកការពារសិទ្ធិមនុស្ស ផ្ដល់សម្ភាសដល់ ម.ស.ម.ក ត្រូវធ្វើ រួមមានដូចជាការប្រុងប្រយ័ត្នចំពោះការប្រើពាក្យសម្ដី ការយល់ដឹងអំពីសិទ្ធិរបស់ខ្លួនកាន់តែប្រសើរឡើង ដើម្បីធានាសុវត្ថិភាពផ្ទាល់ខ្លួន និងត្រូវអនុវត្តការងាររបស់ខ្លួនស្របតាមច្បាប់ និងគោរពតាមគោលនយោបាយរបស់អង្គការ បង្ហាញពីភាពគួរសម ភាពបើកចំហ និងភាពបត់បែនជាមួយអាជ្ញាធរ ដោយមិនធ្វើឱ្យខូចគុណតម្លៃ និងគោលការណ៍របស់ខ្លួនក្នុងនាមជាអ្នកការពារសិទ្ធិមនុស្ស ឬត្រូវចេះបន្ទាបខ្លួន និងមានអ្នកទៅជាមួយនៅពេលអនុវត្តសកម្មភាពរបស់ខ្លួន។ ទោះបីជាមានការលំបាកទាំងនេះក៏ដោយ ក៏គ្មានអ្នកសម្ភាសន៍ណាម្នាក់បានរាយការណ៍ពីការបដិសេធក្នុងការតស៊ូមតិលើបញ្ហាសិទ្ធិមនុស្សដែលមានលក្ខណៈរសើបខ្លាំងពេកនោះទេ។

### *សេរីភាពខាងការបញ្ចេញមតិរបស់អ្នកការពារសិទ្ធិមនុស្សជាអ្នកស្រឡាញ់ភេទដូចគ្នា និងអ្នកការពារសិទ្ធិមនុស្សជាស្ត្រី*

នៅក្នុងបរិយាកាសដែលមានអរិភាពចំពោះសំឡេងរិះគន់ អ្នកការពារសិទ្ធិមនុស្សជាអ្នកស្រឡាញ់ភេទដូចគ្នា និងអ្នកការពារសិទ្ធិមនុស្សជាស្ត្រី ជៀសមិនផុតពីបញ្ហាប្រឈមជាច្រើនដែលសកម្មជននៅកម្ពុជាជួបប្រទះនោះទេ។ ក្នុងចំណោម ១៣ នាក់នៃអ្នកការពារសិទ្ធិមនុស្សដែលប្រឈមមុខនឹង ចំណាត់ការផ្លូវច្បាប់ដោយសារការអនុវត្តសេរីភាពខាងការបញ្ចេញមតិ ក្នុងអំឡុងពេលនៃការសរសេររបាយការណ៍នោះ មានបួននាក់ជាស្ត្រី។

ស្ត្រីពីរនាក់គឺ ឡុង គន្ធា និង ភួន កែវរស្មី ដែលជាសកម្មជនអង្គការមាតាធម្មជាតិកម្ពុជា ត្រូវបានសាលាឧទ្ធរណ៍សម្រេចតម្កល់ការផ្តន្ទាទោស ពីបទញុះញង់កាលពីខែវិច្ឆិកា ឆ្នាំ២០២១។ ពួកគេត្រូវបានដោះលែងតាមសាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាប់ពីទទួលបានការសម្រាលទោស។ ទោះយ៉ាងណា ពួកគេក៏ត្រូវបានដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការរយៈពេលបីឆ្នាំបន្ទាប់។ លើសពីនេះ អ្នកទាំងពីរក៏ត្រូវបានចោទប្រកាន់ពីបទឃុបឃិត និងប្រមាថអង្គព្រះមហាក្សត្រក្នុងខែមិថុនា ឆ្នាំ២០២១ ហើយប្រឈមមុខនឹងការជាប់ពន្ធនាគាររហូតដល់ដប់ឆ្នាំ។ គិតត្រឹមខែកញ្ញា ឆ្នាំ២០២២ ដែលមានរយៈពេលមួយឆ្នាំបន្ទាប់ពីការចោទប្រកាន់បន្ថែមទាំងនេះ មិនទាន់មានកាលបរិច្ឆេទសវនាការណាមួយត្រូវបានកំណត់ទេ ដោយធ្វើឱ្យពួកគេស្ថិតក្នុងស្ថានភាពមិនច្បាស់លាស់អំពីអនាគតរបស់ខ្លួន។ ដេត ហួរ ដែលជាតំណាងសហគមន៍ដីធ្លីមកពីឃុំជីខលើ ខេត្តកោះកុងក៏ត្រូវបានតុលាការខេត្តកោះកុង កាត់ទោសពីបទបង្ខូចកេរ្តិ៍ និងបរិហារកេរ្តិ៍ដោយចេតនាមិនល្អផងដែរ ហើយបានផ្តន្ទាទោសដាក់ពន្ធនាគារដោយសារការប្រើប្រាស់សេរីភាពខាងការបញ្ចេញមតិតាមប្រព័ន្ធអ៊ីនធឺណែតដើម្បីរាយការណ៍ពីសកម្មភាពទន្ទ្រានយកដីសហគមន៍របស់ខ្លួនពីសំណាក់ឧកញ៉ា។ ដូចគ្នាដែរ អ៊ុំ សុភី ដែលជាសកម្មជនដីធ្លីមកពីសហគមន៍ឡពាង ត្រូវបានចាប់ខ្លួន ឃាត់ខ្លួន និងចោទប្រកាន់ពីបទបង្ករការខូចខាតដោយចេតនា ដែលតាមការអះអាងថាបទចោទប្រកាន់នេះកើតចេញពីការបង្ហោះទិដ្ឋភាពនៃជម្លោះដីធ្លីសហគមន៍របស់អ្នកស្រី ដែលត្រូវបានដឹងឮសុះសាយពេញបណ្តាញសង្គម។ ជាចុងក្រោយ ដូចបានគូសបញ្ជាក់ខាងដើមនៅក្នុងរបាយការណ៍នេះ អ្នកការពារសិទ្ធិមនុស្សជាស្ត្រីចំនួនពីររូបគឺ ទូច ស្រីនិច និង អេង ម៉ាឡៃ បានរងការវាយប្រហារលើរាងកាយ ដែលត្រូវបានគេជឿថាបណ្តាលមកពីសកម្មភាពរបស់ខ្លួន។

**អ៊ុំ សុភី៖** កាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០២២ អ្នកស្រី អ៊ុំ សុភី ដែលជាតំណាងសហគមន៍ឡពាង ត្រូវបាននគរបាលខេត្តកំពង់ឆ្នាំងចាប់ខ្លួន និងឃុំខ្លួនជាមួយស្វាមីអ្នកស្រីឈ្មោះ សួន ញឿន ដែលជាតំណាងសហគមន៍ សមាជិកសហគមន៍មួយរូបឈ្មោះ ទួន សេង និងចៅប្រុសអាយុ ១ ឆ្នាំផងដែរ។ រួចបញ្ជូនខ្លួនទៅសាលាដំបូងខេត្តដើម្បីសាកសួរ។[118] នគរបាលបានសួរចម្លើយពួកគេក្រោមការចោទប្រកាន់ថាបានបំផ្លាញទ្រព្យសម្បត្តិអ្នកដទៃ។ ទោះជាយ៉ាងណាក៏ដោយការចាប់ខ្លួនពួកគេធ្វើឡើង បន្ទាប់ពីអ្នកស្រី សុភី និងស្វាមីរបស់គាត់ បានផ្សាយផ្ទាល់អំពីជម្លោះអាជ្ញាធរជាមួយនឹងងអ្នកភូមិដែលមានជម្លោះដីធ្លី។[119] អ្នកស្រី សុភី និងលោក ញឿន ត្រូវបានដោះលែងនៅក្រៅឃុំបណ្តោះអាសន្ននៅពេលបន្ទាប់មក ចំណែកអ្នកស្រី សេង ត្រូវបានបញ្ជូនទៅឃុំខ្លួន។[120]



*អ៊ុំ សុភី អ្នកការពារសិទ្ធិមនុស្សជាស្ត្រី - រូបថត៖ ម.ស.ម.ក*

[118] ណាត សុភាព & ខាន់ លក្ខិណា "សកម្មជនដីធ្លីត្រូវបានចាប់ខ្លួននៅខេត្តកំពង់ឆ្នាំង" (*វីអូឌី*, ៣១ មករា ២០២២)។ យួន ណារីម "សកម្មជនដីធ្លីខេត្តកំពង់ឆ្នាំងត្រូវបានចោទប្រកាន់បន្ទាប់ពីផ្សាយផ្ទាល់ពីជម្លោះដីធ្លី" (*CamboJA News*, ៣១ មករា ២០២២)។
[119] ដូចខាងលើ
[120] គាង សុខមាន "សកម្មជនដីធ្លីខេត្តកំពង់ឆ្នាំងនៅក្រៅឃុំ ផ្ទៃរឿងលម្អិតសំណុំរឿងនៅមានភាពស្រពិចស្រពិលនៅឡើយ"។ (*វីអូឌី*, ២៨ មិថុនា ២០២២)។

អ្នកទាំងបីត្រូវបានចោទប្រកាន់ពីបទបង្កការខូចខាតទ្រព្យសម្បត្តិដោយចេតនា។[121] ទោះបីជាយ៉ាងណា របាយការណ៍អំពីករណីនេះមានភាពខុសប្លែកគ្នា ហើយប្រភពមួយរាយការណ៍ថា ពីរនាក់ត្រូវបានចោទប្រកាន់ពីបទលួចទ្រព្យសម្បត្តិរបស់ដើមបណ្តឹង ដោយម្នាក់ទៀតអាចត្រូវបានចោទប្រកាន់ពីបទគំរាមសម្លាប់ ប៉ុន្តែគេមិនទាន់ដឹងច្បាស់ថាអ្នកណាអាចរងការចោទប្រកាន់នេះទេ។[122] គាត់ត្រូវបានតុលាការកំពូលសម្រេចឱ្យនៅក្រៅឃុំនៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២២ ហើយបានចេញពីពន្ធនាគារប៉ុន្មានថ្ងៃក្រោយមក គឺនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២។[123]

ក្រុមអ្នកការពារសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា និងអ្នកការពារសិទ្ធិមនុស្សជាស្ត្រីនៅកម្ពុជា ក៏ជួបប្រទះនឹងបញ្ហាប្រឈមជាច្រើនដែលមានឫសគល់ចេញពីបទដ្ឋានសង្គមធ្វើឱ្យផលប៉ះពាល់យ៉ាងខ្លាំងដល់សេរីភាពខាងការបញ្ចេញមតិ។ ម្នាក់ក្នុងចំណោមអ្នកការពារសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា ពីរនាក់ដែលបានសម្ភាសន៍បានរាយការណ៍ថាជួបប្រទះការរើសអើងក្នុងការអនុវត្តសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន។ ពួកគេបាននិយាយថា មានការលំបាកក្នុងការតស៊ូមតិ នៅពេលដែលខ្លួនត្រូវគេមើលឃើញថាជាមនុស្សខុសប្រក្រតីដោយសារមិនទាន់បានកំណត់ថា ជាភេទណាមួយនៅឡើយ។ ពួកគេបាននិយាយថាពេលខ្លះត្រូវបានគេសើចចំអក ហើយមតិរបស់ពួកគេមិនត្រូវបានគេផ្តល់តម្លៃដោយសារតែខ្លួនជាអ្នកស្រឡាញ់ភេទដូចគ្នា។

*«ខ្ញុំធ្លាប់និយាយពីមុនថា ទោះបីខ្ញុំត្រូវគេបាញ់សម្លាប់ដោយគ្រាប់កាំភ្លើងតែមួយគ្រាប់ក៏ដោយ ក៏ខ្ញុំត្រូវតែហ៊ាននិយាយការពិតដែរ ហើយហ៊ានស្វែងរកអ្វីដែលអាក្រក់ ហើយផ្លាស់ប្តូរទៅជាល្អ។ [...] បើយើងមិនហ៊ាននិយាយ អ្នកផ្សេងក៏មិនហ៊ាននិយាយដែរ»។ - អេង ម៉ាឡៃ យុវនារីខ្មែរថាវរៈ*

## ៥.៣. ស្ថានភាពនៃសិទ្ធិទទួលព័ត៌មាន

### *ការចេញផ្សាយសាលក្រមតុលាការ*

សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ មានន័យថាសាលក្រមដែលបានចេញក្នុងដំណើរការនីតិវិធីរដ្ឋប្បវេណីនិងព្រហ្មទណ្ឌត្រូវតែបង្ហាញជាសាធារណៈ។ គណៈកម្មាធិការសិទ្ធិមនុស្សបានយល់ឃើញថា លើកលែងតែករណីមួយចំនួន *«សាលក្រម រួមទាំងសំអាងហេតុ ភស្តុតាង និងមូលហេតុផ្លូវច្បាប់សំខាន់ៗត្រូវតែ*

121 "សកម្មជនសហគមន៍ឡពាង ត្រូវបានដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្នបន្ទាប់ពីផ្សាយផ្ទាល់ជម្លោះដីធ្លី" (CamboJA News, ០៤ កុម្ភៈ ២០២២).

122 ឃួម ណារីម "សកម្មជនដីធ្លីខេត្តកំពង់ឆ្នាំង រងការចោទប្រកាន់ បន្ទាប់ពីផ្សាយផ្ទាល់អំពីរឿងវិវាទ (*សារព័ត៌មានខេមបូចា*, ៣១ មករា ២០២២)។

123 គាង សុខមាន "សកម្មជនដីធ្លីខេត្តកំពង់ឆ្នាំងនៅក្រៅឃុំ ផ្ទៃរឿងលម្អិតសំណុំរឿងនៅមានភាពស្រពិចស្រពិលនៅឡើយ"។ (*វីអូឌី*, ២៨ មិថុនា ២០២២)។

*បង្ហាញជាសាធារណៈ»*[124] ទោះបីជាក្នុងករណីដែលសាធារណជនត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងការជំនុំជម្រះក្តីក៏ដោយ។ តម្លាភាពនៃនីតិវិធីតុលាការភាគច្រើនជាបញ្ហានៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ព្រោះជាបញ្ហានៃការទទួលព័ត៌មាន៖ សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈគឺជាគន្លឹះមួយដើម្បីធានានូវតម្លាភាព និងគណនេយ្យភាព ព្រោះវាកំណត់ពីសមត្ថភាពរបស់ចៅក្រមក្នុងការធ្វើសកម្មភាពតាមអំពើចិត្ត ប៉ុន្តែក៏មានសារៈសំខាន់ផងដែរនៅក្នុងលក្ខខណ្ឌនៃការទទួលព័ត៌មានផ្លូវច្បាប់ ព្រោះអនុញ្ញាតឱ្យសាធារណជនបានដឹងពីប្រភេទនៃការប្រព្រឹត្ត ដែលត្រូវបានហាមឃាត់តាមច្បាប់។ ដូច្នេះ អង្គការតម្លាភាពអន្តរជាតិចាត់ទុកថា ទោះជាស្ថិតក្រោមការលើកលែងក៏ដោយ ក៏សិទ្ធិទទួលបានឯកសារតុលាការគឺជាការបង្ហាញពីសិទ្ធិទទួលព័ត៌មាន។[125]

តម្លាភាពនៃប្រព័ន្ធតុលាការនៅតែជាបញ្ហាដែលត្រូវដោះស្រាយនៅកម្ពុជា។ ទោះបីជាក្រុមប្រឹក្សាធម្មនុញ្ញបានចេញផ្សាយសេចក្តីសម្រេចរបស់ខ្លួនជាទៀងទាត់[126] ហើយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា («អ.វ.ត.ក»)បានចេញផ្សាយយ៉ាងទូលំទូលាយនូវសាលក្រមរបស់ខ្លួនក៏ដោយ ប៉ុន្តែសេចក្តីសម្រេចរបស់តុលាការផ្សេងទៀតគឺមិនអាចចូលទៅរកមើលបាននោះទេ។ ការដោះស្រាយចំណុចខ្វះខាតនេះ គឺជាគោលដៅមួយក្នុងចំណោមគោលដៅនានានៃគម្រោងអភិវឌ្ឍន៍ផ្នែកច្បាប់ និងយុត្តិធម៌ដំណាក់កាលទី៥ របស់ក្រសួងយុត្តិធម៌ និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុនចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៧ ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២។ គម្រោងនេះបានព្យាយាមបង្កើនគុណភាពនៃសេចក្តីសម្រេចរបស់តុលាការស៊ីវិល ដោយបង្កើតដំណើរការបង្ហាញសេចក្តីសម្រេចទាំងនេះ។[127] បន្ទាប់ពីការចេញផ្សាយសាលក្រមចំនួន ៨៤ លើសំណុំរឿងបណ្តឹងរដ្ឋប្បវេណីនៅ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០[128] សាលក្រមចំនួន ២០ បន្ថែមទៀត ត្រូវបានចេញផ្សាយនៅលើគេហទំព័ររបស់ក្រសួងយុត្តិធម៌នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០២២។ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន បានលើកឡើងក្នុងសេចក្តីប្រកាសព័ត៌មានមួយថា ការចេញផ្សាយសាលក្រមទាំងនេះមានគោលបំណង *«បង្កើនតម្លាភាពសេវាសាធារណៈរបស់តុលាការ និងអភិវឌ្ឍគណនេយ្យភាពសាធារណៈរបស់ចៅក្រម ព្រមទាំងប្រព័ន្ធតុលាការទាំងមូល»។*[129]

ទោះបីនេះពិតជាការបោះជំហានមួយក្នុងទិសដៅដ៏ត្រឹមត្រូវក៏ដោយ សាលក្រមដែលបានចេញផ្សាយមានចំនួនតិចតួចខ្លាំងណាស់។ ចាំបាច់ត្រូវធ្វើអ្វីបន្ថែមទៀត ដើម្បីធានាថារាល់សាលក្រមទាំងក្នុងសំណុំរឿង

---

124 គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីអធិប្បាយទូទៅលេខ ៣២ មាត្រា ១៤៖ សិទ្ធិទទួលបានភាពស្មើគ្នានៅចំពោះមុខតុលាការ និងសាលាជម្រះក្តី និងការជំនុំជម្រះដោយយុត្តិធម៌។ U.N. Doc. CCPR/C/GC/32 (២០០៧)។

125 អង្គការតម្លាភាពអន្តរជាតិ "តម្លាភាពនៃដំណើរការនីតិវិធីរបស់តុលាការ" (៣០ កញ្ញា ២០១៩), ទំព័រទី ១។

126 គេហទំព័រក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជា។

127 JICA, គម្រោងផែនការ។

128 នៀម ឆេង "ឥឡូវនេះ សេចក្តីសម្រេចរបស់តុលាការត្រូវបានចេញផ្សាយជាប្រភពឯកសារយោង"(*ភ្នំពេញប៉ុស្តិ៍,* ០៤ មករា ២០២១)។

129 JICA, ព័ត៌មានគម្រោង៖ បានបង្ហាញសាលក្រមថ្មីចំនួន ២០ នៅលើគេហទំព័ររបស់ក្រសួងយុត្តិធម៌ (១៣ មករា ២០២២)។

រដ្ឋប្បវេណីនិងព្រហ្មទណ្ឌត្រូវបានចេញផ្សាយ ដើម្បីធានាថាបុគ្គលម្នាក់ៗអាចទទួលបានព័ត៌មានទាក់ទងនឹងដំណើរប្រព្រឹត្តទៅរបស់តុលាការ។

### *ការរក្សាទុកបណ្ណាសារ*

យោងតាមក្រុមប្រឹក្សាអន្តរជាតិរៀបចំបណ្ណាសារ *«ដោយធានានូវសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលព័ត៌មានផ្លូវការនិងចំណេះដឹងអំពីប្រវត្តិសាស្ត្ររបស់ខ្លួន បណ្ណាសារគឺជាមូលដ្ឋានគ្រឹះមួយនៃការកំណត់អតសញ្ញាណលទ្ធិប្រជាធិបតេយ្យ គណនេយ្យភាព និងអភិបាលកិច្ចល្អ»។*[130] សិទ្ធិទទួលបានចំណេះដឹងអំពីប្រវត្តិសាស្ត្រនិងតួនាទីដ៏សំខាន់នៃបណ្ណាសារក្នុងការរក្សាសិទ្ធិនេះ ក៏ត្រូវបានទទួលស្គាល់ដោយអង្គការសហប្រជាជាតិផងដែរ។ *យោងតាមគោលការណ៍ដែលបានធ្វើបច្ចុប្បន្នភាពស្តីពីការការពារ និងលើកកម្ពស់សិទ្ធិមនុស្ស តាមរយៈសកម្មភាពប្រយុទ្ធប្រឆាំងនឹងនិទណ្ឌភាព* អង្គការសហប្រជាជាតិបានចែងថា *«មនុស្សគ្រប់រូបមានសិទ្ធិមិនអាចកាត់ផ្តាច់បានក្នុងការយល់ដឹងការពិត អំពីព្រឹត្តិការណ៍អតីតកាលទាក់ទងនឹងការប្រព្រឹត្តឧក្រិដ្ឋកម្មកាចសាហាវ និងអំពីកាលៈទេសៈ និងហេតុផលនានាដែលនាំទៅដល់ការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនោះ តាមរយៈការរំលោភបំពានទ្រង់ទ្រាយធំឬជាប្រព័ន្ធ»។*[131] ដើម្បីសម្រេចបាននូវសិទ្ធិក្នុងការយល់ដឹងនេះ អង្គការសហប្រជាជាតិបានអំពាវនាវឱ្យបណ្តារដ្ឋនានាចាត់វិធានការផ្សេងៗ ដែលរួមមានការធានាបាននូវការរក្សាទុក និងការប្រើប្រាស់បណ្ណាសារទាក់ទងនឹងការរំលោភសិទ្ធិមនុស្ស និងច្បាប់មនុស្សធម៌។[132]

មានការវិវត្តន៍គួរឱ្យកត់សម្គាល់ទាក់ទងនឹងការចងក្រងឯកសារបណ្ណាសារ អំពីការរំលោភសិទ្ធិមនុស្សក្នុងអំឡុងពេលនៃការសរសេររបាយការណ៍នៅកម្ពុជា។

> *"យើងនៅតែត្រូវរៀបចំ**បណ្ណាសារនូវរាល់សំណុំឯកសាររបស់សាលាក្តី** ហើយរៀបចំកន្លែង**រក្សាទុក និងដាក់តាំងបង្ហាញ ដើម្បីជាប្រយោជន៍ដល់យុវជនខ្មែរជំនាន់ក្រោយ** ដែលថ្ងៃណាមួយពួកគេនឹង**ទទួលបន្ទុកទប់ស្កាត់ការវិលត្រឡប់មកវិញនូវអំពើប្រល័យពូជសាសន៍**"។*
>
> *លោក ឈាង វុន សមាជិកសភា កាលពីខែវិច្ឆិកា ឆ្នាំ២០២១។*[133]

នៅខែសីហាឆ្នាំ២០២១ រដ្ឋាភិបាល និងអង្គការសហប្រជាជាតិបានចុះហត្ថលេខាលើសេចក្តីបន្ថែមលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិរដ្ឋាភិបាលស្តីពី អ.វ.ត.ក។ តាមរយៈសេចក្តីបន្ថែមនេះ អ.វ.ត.ក ដែលមានភារកិច្ចកាត់ទោសមេដឹកនាំខ្មែរក្រហម និងអ្នកទទួលខុសត្រូវបំផុតចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងអំឡុងរបបខ្មែរក្រហមពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ នៅកម្ពុជា បានទទួលសិទ្ធិអនុវត្តបន្តដែលនឹងចូលជាធរមាននៅពេលបញ្ចប់ការងារតុលាការរបស់ខ្លួន។ យោងតាមប្រការ ៣ នៃឧបសម្ព័ន្ធ ស្តីពីបណ្ណាសារបានចែងថា អង្គការសហប្រជាជាតិ និងរដ្ឋាភិបាល ឯកភាពថាការរក្សាទុកបណ្ណសាររបស់ អ.វ.ត.ក គឺជារឿងដ៏«សំខាន់» ហើយត្រូវតែ «ផ្តល់លទ្ធភាពប្រើប្រាស់ឱ្យបានទូលំទូលាយ តាម

---

[130] គេហទំព័របណ្ណសាររបស់ក្រុមប្រឹក្សាអន្តរជាតិ។

[131] អង្គការសហប្រជាជាតិ គោលការណ៍ការពារ និងលើកកម្ពស់សិទ្ធិមនុស្សតាមរយៈសកម្មភាពប្រយុទ្ធប្រឆាំងនឹងអំពើនិទណ្ឌភាព(ថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ២០០៥) គោលការណ៍ទី២។

[132] ដូចខាងលើ គោលការណ៍ទី ៥

[133] ព្រះមហាក្សត្រខ្មែរ ប្រកាសឱ្យប្រើច្បាប់ដើម្បីបញ្ចប់តុលាការខ្មែរក្រហម (*UCA News*, ថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២១)

ដែលអាចធ្វើទៅបាន»។[134] ច្បាប់បន្ថែមនេះត្រូវបានរដ្ឋសភាអនុម័តនៅចុងខែតុលា ឆ្នាំ២០២១ និងប្រកាសឱ្យប្រើដោយព្រះមហាក្សត្រនរោត្តមសីហមុនី ក្នុងខែវិច្ឆិកា ឆ្នាំ២០២១។ នៅថ្ងៃទី១២ ខែមករា ឆ្នាំ២០២២ ច្បាប់បន្ថែមនេះត្រូវបានប្រកាសចូលជាធរមានជាផ្លូវការ។[135]

បន្ទាប់ពី អ.វ.ត.ក បានប្រកាសសេចក្តីសម្រេចចុងក្រោយរបស់ខ្លួននៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២ លោក នេត្រ ភក្ត្រា ដែលជាអ្នកនាំពាក្យ អ.វ.ត.ក បានបញ្ជាក់ថា ការបង្កើតប្រព័ន្ធគ្រប់គ្រង និងរក្សាទុកបណ្ណសាររបស់ អ.វ.ត.ក បានធ្វើឡើងក្នុងចំណោមកិច្ចការដែលនៅសល់ចំនួនពីររបស់ អ.វ.ត.ក ដែលត្រូវអនុវត្តក្នុងរយៈពេលបីឆ្នាំខាងមុខ[136] ប្រព័ន្ធនេះនឹងអនុញ្ញាតឱ្យសាធារណៈជនចូលប្រើកំណត់ត្រាដោយសេរី និងងាយស្រួល។[137]

ប្រព័ន្ធនេះនៅតែគេចាំមើលថាប្រព័ន្ធអ្វីនឹងត្រូវអនុម័តយក។ យោងតាមការសិក្សាមតិស្តីពីការចាត់ចែង និងគ្រប់គ្រងបណ្ណសាររបស់ អ.វ.ត.ក នៅអំឡុងខែកញ្ញា ឆ្នាំ២០១៩ បានបង្ហាញថា ៩៦% នៃអ្នកឆ្លើយសំណួរបានរាយការណ៍ថា បណ្ណសាររបស់ អ.វ.ត.ក ចាំបាច់ត្រូវរក្សាទុកនៅកន្លែងដែលមានសុវត្ថិភាព និងសន្តិសុខ។ ការសិក្សាក៏បានរកឃើញថា *«អ្នកឆ្លើយសំណួរមានទស្សនៈយ៉ាងមុតមាំថា ស្ថាប័នដែលរក្សាទុកបណ្ណសារមិនត្រូវមានទំនាក់ទំនង ឬទទួលរងឥទ្ធិពលនយោបាយឡើយ»*[138] ដើម្បីបង្ការការកែប្រែ កែសម្រួល ឬបំផ្លាញចោលឯកសារ។[139]

## *អ្នកសារព័ត៌មានពិបាកទទួលព័ត៌មានដែលកាន់កាប់ដោយមន្រ្តីសាធារណៈ*

យោងតាមបទសម្ភាសន៍ដែលធ្វើឡើងជាមួយអ្នកសារព័ត៌មានសម្រាប់របាយការណ៍នេះ បង្ហាញថា អ្នកសារព័ត៌មានកំពុងធ្វើការក្នុងបរិយាកាសដែលពោរពេញដោយការលំបាក នៅពេលព្យាយាមទទួលព័ត៌មាន។ អ្នកសារព័ត៌មានចំនួន ១៦ នាក់ក្នុងចំណោម ១៨ នាក់ដែលបានផ្តល់សម្ភាសបានរាយការណ៍ថា ពួកគេមានការពិបាកក្នុងការទទួលព័ត៌មានចាំបាច់ដើម្បីសរសេរអត្ថបទរបស់ខ្លួន។ អ្នកសារព័ត៌មាន ១៤ នាក់ បានលើកឡើងថា ខ្លួនជួបប្រទះការលំបាកក្នុងការទទួលព័ត៌មានពីអាជ្ញាធរពាក់ព័ន្ធដោយម្នាក់និយាយថា «ពិបាកខ្លាំងណាស់» ក្នុងការទទួលព័ត៌មានពីមន្រ្តីសាធារណៈ។ យោងតាមអ្នកសារព័ត៌មានមួយចំនួនដែលបានផ្តល់សម្ភាស មន្រ្តី

---

[134] *សេចក្តីបន្ថែមលើកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាល និងអង្គការសហប្រជាជាតិ ស្តីពីការផ្តន្ទាទោសតាមច្បាប់កម្ពុជា ចំពោះបទល្មើសឧក្រិដ្ឋដែលបានប្រព្រឹត្តក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ តាមការរៀបចំចាត់ចែងអន្តរកាល និងការបញ្ចប់ការងាររបស់អង្គជំនុំជម្រះវិសាមញ្ញ មាត្រា ៣។* (អ.វ.ត.ក, សីហា ២០២១)

[135] អ.វ.ត.ក, សេចក្តីប្រកាសព័ត៌មាន៖ សេចក្តីបន្ថែមលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ-រដ្ឋាភិបាល ចូលជាធរមាន (១២ មករា ២០២២)។

[136] ឡាយ សាមាន "ទទួលបានយុត្តិធម៌៖ សាលាក្តីខ្មែរក្រហមបិទសំណុំរឿងផ្លូវច្បាប់ចុងក្រោយ" (*ភ្នំពេញប៉ុស្តិ៍,* ២២ កញ្ញា ២០២២)។

[137] វួន ដារ៉ា "អ.វ.ត.ក បិទសំណុំរឿងចុងក្រោយត្រឹមដំណាច់ឆ្នាំ" (*ភ្នំពេញប៉ុស្តិ៍,* ០៧ កក្កដា ២០២២)។

[138] នៀម ឆេង "ការអង្កេត៖ បណ្ណសាររបស់ អ.វ.ត.ក គួរតែរក្សាទុកនៅស្ថាប័ន 'អព្យាក្រឹត' (*ភ្នំពេញប៉ុស្តិ៍,* ០៦ កញ្ញា ២០១៩) សាយ មុន្នី "យោងតាមការអង្កេតបង្ហាញថា ភាគច្រើនចង់ឱ្យអង្គការឯករាជ្យរៀបចំបណ្ណសាររបស់ អ.វ.ត.ក" (*វីអូអេ,* ២៥ កញ្ញា ២០១៩)។

[139] លី លីវសៀ, "ភាពប្រទាញប្រទង់គ្នាលើបណ្ណសារ អ.វ.ត.ក" (*ខ្មែរថាមស៍,* ១២ កញ្ញា ២០១៩)។

សាធារណៈមានភាពស្ទាក់ស្ទើរក្នុងការផ្តល់ព័ត៌មានដល់អ្នកសារព័ត៌មាន អំពីប្រធានបទដែលមានលក្ខណៈរសើប ដូចជាបញ្ហាដីធ្លី ល្បែងស៊ីសងខុសច្បាប់ និងអំពើពុករលួយជាដើម។

ម.ស.ម.ក បានកត់សម្គាល់ផងដែរថា អ្នកនាំពាក្យដែលអ្នកសារព័ត៌មានបានទាក់ទងក្នុងអំឡុងពេលនៃការសរសេររបាយការណ៍ជាញឹកញាប់មិនអាច ឬមិនចង់ផ្តល់ព័ត៌មាន ឬធ្វើអត្ថាធិប្បាយលើករណីនានានោះទេ។ ជាក់ស្តែង នៅពេលដែលអ្នកសារព័ត៌មានវីអូឌីទាក់ទងលោក ផៃ ស៊ីផាន អ្នកនាំពាក្យរដ្ឋាភិបាលអំពីការធ្វើឯកជនភាវូបនីយកម្មលើដីរដ្ឋរាប់រយហិកតា ដែលត្រូវបានផ្តល់ឱ្យបុគ្គលដែលមានទំនាក់ទំនងល្អក្នុងខែមេសា ឆ្នាំ២០២២ លោកបានបង្វែរសំណួរមួយចំនួនទៅកាន់សាលារាជធានីភ្នំពេញ និងក្រសួងដែនដី។ គ្មានអ្នកណាអាចទាក់ទងសុំការអត្ថាធិប្បាយបានទេ។[140] ស្រដៀងគ្នានេះដែរ នៅពេលលោក អ៊ឹង ឆៃ ដែលអ្នកនាំពាក្យសាលាខេត្តកំពត ត្រូវបានអ្នកសារព័ត៌មានវីអូឌី សាកសួរអំពីការធ្វើឯកជនភាវូបនីយកម្មផ្ទៃដីសមុទ្រសម្រាប់សាងសង់កំពង់ផែតម្លៃរាប់លាននៅកំពតនោះ លោកថាលោកមិនមានសមត្ថកិច្ចដែលត្រូវនិយាយអំពីគម្រោងនេះទេ។[141] អ្នកសារព័ត៌មានក៏ត្រូវបានមន្ត្រីសាធារណៈប្រាប់ជាញឹកញាប់ថាពួកគេ «កំពុងជាប់ប្រជុំ» ឬជាប់រវល់ខ្លាំងមិនអាចឆ្លើយសំណួរបានទេ។

គាក់ទិកដែលមន្ត្រីសាធារណៈបានប្រើក្នុងការបណ្តេញអ្នកសារព័ត៌មានបែបនេះ បង្កឱ្យមានការរិះគន់ពីសំណាក់អ្នកធ្វើការក្នុងវិស័យសារព័ត៌មានជាច្រើន ដោយបានចោទប្រកាន់ថ្កោលទោសអាជ្ញាធរថាមិនឆ្លើយតបនៅពេលសួរសំណួរដែលតានតឹង ឬរើសអើងអ្នកសារព័ត៌មានឯករាជ្យ ដោយមានទំនោរទៅរកអ្នកសារព័ត៌មានមកពីស្ថាប័នដែលជាបក្សសម្ព័ន្ធរបស់រដ្ឋាភិបាល។ ឆ្លើយតបនឹងការរិះគន់បែបនេះ កាលពីខែមីនា ឆ្នាំ២០២២ លោក ខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មាន បានប្រាប់មន្ត្រីឱ្យសហការ និងមិនរើសអើងអ្នកសារព័ត៌មាន បង្កើនទំនាក់ទំនងជាមួយប្រព័ន្ធផ្សព្វផ្សាយ និងផ្តល់យោបល់ទាន់ពេលវេលា នៅពេលទាក់ទងមក ដើម្បីឱ្យអ្នកសារព័ត៌មានរាយការណ៍ព័ត៌មានបានត្រឹមត្រូវ។[142]

បញ្ហានៃភាពទាន់ពេលវេលាត្រូវបានលើកឡើងដោយអ្នកសារព័ត៌មានពីររូប ដែលបានផ្តល់សម្ភាសសម្រាប់របាយការណ៍នេះ៖ អ្នកទាំងពីរបាននិយាយថា ពួកគេមានការពិបាកក្នុងការទទួលព័ត៌មានពីមន្ត្រីសាធារណៈ ហើយនៅពេលដែលពួកគេបានទទួលព័ត៌មានដែលបានស្នើសុំនោះ ជារឿយៗគឺមិនពាក់ព័ន្ធទៀតទេ។ នៅខែកញ្ញា ឆ្នាំ២០២១ រដ្ឋាភិបាលបានចេញប្រកាសស្តីបន្ទោសតាមពាក្យបណ្តឹងរបស់អ្នកសារព័ត៌មានដែលចោទថាអ្នកនាំពាក្យមិនបានផ្តល់ចម្លើយដែលពួកគេត្រូវការឱ្យបានទាន់ពេលវេលា។ លោក ផៃ ស៊ីផាន អ្នកនាំពាក្យរដ្ឋាភិបាល ព្យាយាមបង្វែរការស្តីបន្ទោសដោយលើកឡើងថា អ្នកសារព័ត៌មានខ្វះជំនាញវិជ្ជាជីវៈដែលជាហេតុនាំឱ្យអ្នកនាំពាក្យឆ្លើយតបយឺតយ៉ាវ។ លោកក៏បានពន្យល់ពីភាពស្ទាក់ស្ទើររបស់រដ្ឋាភិបាលក្នុងការ

---

[140] ម៉ិច តារា "បងប្អូនស្រីហ៊ុន សែន ធនាគារកាណាឌីយ៉ា គ្រួសារសមាជិកព្រឹទ្ធសភា ទទួលបានដីរដ្ឋ" (*វីអូឌី,* ១ មេសា ២០២២)។
[141] ម៉ិច ដារ៉ា "ផ្ទៃដីសមុទ្រទំហំ ៦០០ហិកតា ត្រូវបានធ្វើឯកជនភាវូបនីយកម្មសម្រាប់គម្រោងកំពង់ផែកំពត" (*វីអូឌី,* ៩ សីហា ២០២២)
[142] រ៉ូសានេ ជើរីន (Roseanne Gerin) "រដ្ឋមន្ត្រីក្រសួងព័ត៌មានកម្ពុជាប្រាប់អ្នកនាំពាក្យរដ្ឋឲ្យធ្វើការជាមួយប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ" (*វិទ្យុអាស៊ីសេរី,* ២៥ មីនា ២០២២)។

ឆ្លើយតបនឹងអ្នកសារព័ត៌មានដោយនិយាយថា ពេលខ្លះសកម្មជននយោបាយបានក្លែងបន្លំធ្វើជាអ្នកសារព័ត៌មានដើម្បីទាក់ទងអ្នកនាំពាក្យដើម្បីរិះគន់រដ្ឋាភិបាលនៅពេលក្រោយ។[143] ទោះយ៉ាងណា ប៉ុន្មានខែក្រោយមក លោកហាក់ដូចជានិយាយផ្ទុយពីនេះទៅវិញ នៅពេលដែលគាត់ទទួលស្គាល់ថាមាន *«ការរើសអើងអ្នកសារព័ត៌មានក្នុងចំណោមមន្ត្រី»* ហើយបាននិយាយថា *«សូម្បីតែក្នុងនាមជាអ្នកនាំពាក្យ ក៏មន្ត្រីមិនធ្វើការងាររបស់ខ្លួនដែរ បែរជាគេចពីប្រព័ន្ធផ្សព្វផ្សាយទៅវិញ»*។[144]

ទោះយ៉ាងណា មានការវិវត្តន៍ជាវិជ្ជមានគួរឱ្យកត់សម្គាល់គឺ ការរៀបចំសន្និសីទសារព័ត៌មានប្រចាំឆ្នាំរបស់អង្គភាពអ្នកនាំពាក្យរដ្ឋាភិបាល ដែលរយៈពេលពីរឆ្នាំចុងក្រោយនេះ បានផ្តល់ឱ្យអ្នកសារព័ត៌មាន *«នូវឱកាសដើម្បីសាកសួរបញ្ហាប្រឈម និងសមិទ្ធិផលនានារបស់ក្រសួង-ស្ថាប័នរដ្ឋាភិបាល»*។[145] ទោះបីជាគោលដៅនៃសន្និសីទសារព័ត៌មានបែបនេះគឺជារឿងមួយគួរឱ្យសាទរក៏ដោយ ប៉ុន្តែមិនអាចដើរតួនាទីជំនួសការផ្លាស់ប្តូរព័ត៌មានទៅវិញទៅមកជាទៀងទាត់ និងទាន់ពេលវេលារវាងមន្ត្រីសាធារណៈ និងតួអង្គប្រព័ន្ធផ្សព្វផ្សាយនោះទេ។

### *ការវិឡវិល្លឆ្ពោះទៅរកការអនុម័តច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន*

អស់រយៈពេលជាច្រើនឆ្នាំមកហើយចាប់តាំងពីរដ្ឋាភិបាល បានប្រកាសជាសាធារណៈនូវការប្តេជ្ញាចិត្តរបស់ខ្លួនចំពោះសិទ្ធិទទួលព័ត៌មាន។ ដោយមានការលើកទឹកចិត្តយ៉ាងខ្លាំងពីបណ្តាប្រទេសម្ចាស់ជំនួយ និងសង្គមស៊ីវិល រដ្ឋាភិបាលបានទទួលស្គាល់ពីភាពចាំបាច់នៃច្បាប់ស្តីពីសេរីភាពព័ត៌មាន និងបានបង្កើតគោលនយោបាយស្តីពីសិទ្ធិទទួលព័ត៌មាននៅឆ្នាំ២០០៧ ដែលមានគោលដៅបង្កើតរដ្ឋាភិបាលប្រកបដោយតម្លាភាព កាត់បន្ថយអំពើពុករលួយ និងលើកកម្ពស់ទំនុកចិត្តលើរដ្ឋាភិបាល។[146] អស់រយៈពេលមួយទសវត្សរ៍កន្លះក្រោយមកហើយ ដែលច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានមិនទាន់ត្រូវបានអនុម័តនៅក្នុងប្រទេសកម្ពុជានៅឡើយ។ ទោះយ៉ាងណា សេចក្តីព្រាងច្បាប់នេះហាក់ដូចជាជិតដល់ពេលត្រូវអនុម័ត។

ក្រសួងសំខាន់ៗបានបញ្ចប់ការកែសម្រួលលើសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន នៅអំឡុងខែសីហា ឆ្នាំ២០១៩។[147] កាលពីខែឧសភា ឆ្នាំ២០២១ ក្រសួងព័ត៌មានបានសន្យាថានឹងបញ្ចប់ការពិគ្រោះយោបល់លើសេចក្តីព្រាងច្បាប់នេះជាមួយក្រសួងយុត្តិធម៌ *«ឆាប់ៗនេះ»* ហើយបានលើកឡើងថាសេចក្តីព្រាងច្បាប់នេះនឹងត្រូវដាក់ជូនទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋសភាដើម្បីអនុម័តមុនដំណាច់ឆ្នាំ២០២១ ។[148] នៅចុងឆ្នាំ

---

143 យិន សឿម "រដ្ឋាភិបាលបដិសេធការមិនបានឆ្លើយតបរបស់អ្នកនាំពាក្យ" ( *ខ្មែរថាមស៍,* ០៣ កញ្ញា ២០២១ )។

144 នូវ ស៊ីវុត្ថា "ផៃ ស៊ីផាន៖ ច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាននឹងដាក់កាតព្វកិច្ចលើអ្នកនាំពាក្យត្រូវប្រឈមមុខនឹងសារព័ត៌មាន" ( *ភ្នំពេញប៉ុស្តិ៍,* ១០ កុម្ភៈ ២០២២ )។

145 ដូចខាងលើ។

146 ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច (MoNASRI), "សិទ្ធិទទួលព័ត៌មាន៖ ក្របខណ្ឌគោលនយោបាយច្បាស់លាស់សម្រាប់កម្ពុជា" (២២ កក្កដា ២០០៧) ទំព័រ ៤ វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ ការណែនាំអំពីសិទ្ធិទទួលព័ត៌មាននៅកម្ពុជា ( សីហា ២០១០ ) ទំព័រទី ១១។

147 វួន ដារ៉ា "ច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាននឹងបញ្ចប់នៅខែក្រោយ" ( *ភ្នំពេញប៉ុស្តិ៍,* ២១ សីហា ២០១៩ )។

148 រី សុចាន់ "ច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានគ្រោងនឹងអនុម័តក្នុងឆ្នាំនេះ ក្រសួងសន្យា" ( *ភ្នំពេញប៉ុស្តិ៍,* ២៨ ឧសភា ២០២១ )។

២០២១ ក្រសួងព័ត៌មានបានលើកឡើងថាដំណើរការនៃសេចក្តីព្រាងច្បាប់នេះស្ថិតក្នុងដំណាក់កាលចុងក្រោយ ហើយនឹងពន្លឿនការរៀបចំឱ្យបានចប់សព្វគ្រប់ដើម្បីដាក់ជូនទីស្តីការគណៈរដ្ឋមន្ត្រី។[149]

អស់រយៈពេលប្រាំមួយខែឈានចូលឆ្នាំ២០២២ តំណាងអង្គការសង្គមស៊ីវិលចំនួន ៣៣ បានប្រមូលផ្តុំគ្នាដាក់ញត្តិជូនលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដោយអំពាវនាវឱ្យសមាជិកសភាទទួលពិចារណានូវមតិរបស់អង្គការសង្គមស៊ីវិល[150] ដើម្បីកែសម្រួលសេចក្តីព្រាងច្បាប់ និងពន្លឿនការបញ្ចប់ច្បាប់ឱ្យរួចរាល់។ ឆ្លើយតបនឹងញត្តិនេះ ក្រសួងព័ត៌មានបានបើកកិច្ចប្រជុំត្រួតពិនិត្យសេចក្តីព្រាងច្បាប់នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២ ហើយបានប្រកាសថា មានភាពយឺតយ៉ាវនូវវឌ្ឍនភាពនៃសេចក្តីព្រាងច្បាប់នេះ។[151] ជាការឆ្លើយតបទៅនឹងញត្តិ ក្រសួងព័ត៌មានបានរៀបចំកិច្ចប្រជុំមួយដើម្បីពិនិត្យសេចក្តីព្រាងច្បាប់នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២២ និងបានប្រកាសថាវឌ្ឍនភាពនៃសេចក្តីព្រាងច្បាប់អាចមានដំណើរការយឺត។[152] ពីរថ្ងៃក្រោយមក អ្នកនាំពាក្យក្រសួងព័ត៌មានបាននិយាយថា សេចក្តីព្រាងច្បាប់នេះនឹងត្រូវដាក់ជូនទីស្តីការគណៈរដ្ឋមន្ត្រីរហូតទាល់តែមានការអនុម័តចុងក្រោយពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន។[153]

កាលពីខែកញ្ញា ឆ្នាំ២០២២ អ្នកនាំពាក្យក្រសួងព័ត៌មានបាននិយាយថា មានហេតុផលបីយ៉ាងសម្រាប់ការយឺតយ៉ាវក្នុងការអនុម័តសេចក្តីព្រាងច្បាប់នេះ៖ ជាការពិតណាស់ ភាគីពាក់ព័ន្ធកំពុងតែចូលរួមផ្តល់មតិយោបល់ មានភាពចាំបាច់ដើម្បីធានាថាច្បាប់នេះគោរពតាមក្របខណ្ឌច្បាប់ជាតិ និងអន្តរជាតិ និងបញ្ហាប្រឈមនានាដែលបង្កឡើងដោយការឆ្លងរាតត្បាតជាសកលនៃក្របខណ្ឌកូវីដ-១៩។ លោកបានរំលឹកឡើងវិញនូវការប្តេជ្ញាចិត្តរបស់ក្រសួងព័ត៌មានក្នុងការបញ្ចប់សេចក្តីព្រាងច្បាប់នេះ និងអនុម័តឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។[154] នៅចុងខែតុលា ឆ្នាំ២០២២ ក្រសួងព័ត៌មានបានអះអាងថាសេចក្តីព្រាងច្បាប់នេះត្រូវបានបញ្ជូនទៅគណៈរដ្ឋមន្ត្រីដើម្បីពិនិត្យ។ ទោះបែបនេះក៏ដោយ ពេលវេលាពីការអនុម័តច្បាប់មិនត្រូវបានផ្តល់ឡើង។ មានតែពេលវេលាទេដែលកំណត់ថា តើសិទ្ធិទទួលព័ត៌មាននឹងត្រូវបានដាក់បញ្ចូលក្នុងក្របខណ្ឌច្បាប់ជាតិរបស់កម្ពុជាក្នុងឆ្នាំ២០២២ ដែរឬយ៉ាងណានោះ។ [155]

---

149 ស សុជាតិ "សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានកំពុងស្ថិតនៅដំណាក់កាលចុងក្រោយ និងត្រូវពន្លឿន" (*ខ្មែរថាមស៍*, ៥ វិច្ឆិកា ២០២១)។

150 យួន ណារីម "អង្គការសង្គមស៊ីវិលអំពាវនាវឱ្យអនុម័តច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន" (*សារព័ត៌មានខេមបូចា*, ១៦ មិថុនា ២០២២)។

151 ឡាយ សាមៀន "អង្គការសង្គមស៊ីវិលអំពាវនាវឱ្យអនុម័តច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន" (*ភ្នំពេញប៉ុស្តិ៍*, ១៦ មិថុនា ២០២២)។

152 "ការពិនិត្យមើលសេចក្តីព្រាងច្បាប់សិទ្ធិទទួលព័ត៌មានត្រូវបានរៀបចំឡើង" (*Khmer Times*, ០៣ កក្កដា ២០២២); "សេចក្តីព្រាងច្បាប់សិទ្ធិទទួលព័ត៌មានជាប់គាំងដើម្បីធ្វើការពិនិត្យឡើងវិញ" (*ភ្នំពេញប៉ុស្តិ៍*, ០២ កក្កដា ២០២២)។

153វួន ដារ៉ា"សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានស្ថិតក្នុងដំណាក់កាលចុងក្រោយ"សិទ្ធិទទួលព័ត៌មាន"(*ភ្នំពេញប៉ុស្តិ៍*, ០៥ កក្កដា ២០២២)។

154វួន ដារ៉ា"ក្រសួងពន្យល់ពីវឌ្ឍនភាពជុំវិញការតាក់តែងសេចក្តីព្រាងច្បាប់ស្តីពី "សិទ្ធិទទួលព័ត៌មាន"(*ភ្នំពេញប៉ុស្តិ៍*,០២ កញ្ញា ២០២២)

155 យួន ណារីម "ច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានដែលរង់ចាំជាយូរ កំពង់រង់ចាំការអនុម័តពីទីស្តីការគណៈរដ្ឋមន្ត្រី"(*សារព័ត៌មានខេមបូចា*, ២៨ តុលា ២០២២)។

## VI. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

សិទ្ធិសេរីភាពខាងការបញ្ចេញមតិ និងសេរីភាពសារព័ត៌មាន បន្តរងការប៉ះពាល់នៅក្នុងអំឡុងពេលនៃរបាយការណ៍នេះ ហើយជាញឹកញាប់អ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្សបានក្លាយជាជនរងគ្រោះម្តងហើយម្តងទៀត ពីការបន្តការយាយីរបស់រដ្ឋាភិបាល ដើម្បីបំបិទសំឡេងរិះគន់។ ការយាយីតាមប្រព័ន្ធតុលាការ ការវាយប្រហារលើរូបរាងកាយ ការដាក់កំហិតខ្លួនឯង និងការបំភិតបំភ័យ ជាការគំរាមកំហែងមួយចំនួនមកលើអ្នកដែលហ៊ាននិយាយអំពីបញ្ហារសើប ឬបញ្ចេញទស្សនៈរិះគន់រដ្ឋាភិបាល។ ចំពោះសិទ្ធិទទួលព័ត៌មាននៅក្នុងប្រទេសកម្ពុជា ចំណុចជាច្រើនដែលត្រូវកែលម្អដើម្បីអនុវត្តសិទ្ធិនេះបានពេញលេញ។ ខណៈពេលដែលសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានរបស់រដ្ឋាភិបាលគឺជាជំហានមួយទៅរកទិសដៅដ៏ត្រឹមត្រូវនោះ នៅមានឧបសគ្គ ជាច្រើនរារាំងចំពោះការគោរព និងការពារសិទ្ធិនេះឱ្យបានពេញលេញ ហើយកម្ពុជានៅតែមានកិច្ចការជាច្រើនទៀតដែលត្រូវបំពេញ មុនពេលសិទ្ធិទទួលព័ត៌មានត្រូវបានធានាពេញលេញ។ ស្ថានភាពក៏អាចបង្កឱ្យមានការព្រួយបារម្ភផងដែរចំពោះការបោះឆ្នោតសកលឆ្នាំ២០២៣ ដែលខិតជិតមកដល់។ ខណៈពេលដែលសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មានគួរតែបានរក្សាការពារ និងគោរពគ្រប់ពេលវេលា ហើយសិទ្ធិទាំងនោះរឹតតែមានសារៈសំខាន់ថែមទៀតក្នុងអំឡុងពេលបោះឆ្នោត ព្រោះជាពេលវេលាដែលប្រជាពលរដ្ឋត្រូវតែអនុវត្តសេរីភាពមូលដ្ឋាន រួមទាំងសេរីភាពខាងការបញ្ចេញមតិ និងសិទ្ធិទទួលព័ត៌មានដែលអាចជឿទុកចិត្តបាន ដើម្បីចូលរួមពេញលេញក្នុងជីវភាពនយោបាយរបស់ប្រទេសជាតិខ្លួន និងធ្វើការសម្រេចចិត្ត ប្រកបដោយការយល់ដឹងខ្ពស់អំពីការជ្រើសរើសមេដឹកនាំរបស់ខ្លួន។

ការគោរពសិទ្ធិមនុស្សអាចត្រូវបានធានា ហើយលទ្ធិប្រជាធិបតេយ្យអាចរីកចម្រើនទៅបាន លុះត្រាតែប្រជាពលរដ្ឋគ្រប់រូបមានសេរីភាពក្នុងការអនុវត្តសិទ្ធិសេរីភាពខាងការបញ្ចេញមតិ ដែលមានរួមមកជាមួយនឹងកន្សោមចំនួនពីរគឺ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាន ដែលជាធាតុសម្រាប់សិទ្ធិផ្សេងទៀត។ នៅឆ្នាំ១៩៩១ កម្ពុជាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ប្តេជ្ញាការពារសិទ្ធិមនុស្សសេរីភាពមូលដ្ឋាន និងលើកកម្ពស់លទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេសរបស់ខ្លួន។ សាមសិបឆ្នាំក្រោយមកការសន្យានេះមិនទាន់ត្រូវបានបំពេញនៅឡើយទេ ដោយប្រជាជនកម្ពុជាចង់បានសង្គមមួយយុត្តិធម៌ ដែលសិទ្ធិរបស់ខ្លួនរួមទាំងសិទ្ធិសេរីភាពខាងការបញ្ចេញមតិ ត្រូវបានគោរពយ៉ាងពេញលេញ។[156] ដូច្នេះហើយ ជារឿងសំខាន់ដែលរដ្ឋាភិបាលត្រូវតែដោះស្រាយជាបន្ទាន់ នូវស្ថានភាពធ្លាក់ចុះនៃសេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា។ សកម្មភាពជាក់ស្តែងគឺត្រូវការជាចាំបាច់ដើម្បីប្រែក្លាយការប្តេជ្ញាចិត្តទាំងនេះឱ្យក្លាយជាការពិត។

ដូច្នេះ ម.ស.ម.ក សូមជំរុញលើកទឹកចិត្តឱ្យរដ្ឋាភិបាល ចាត់វិធានការជាក់ស្តែង ដើម្បីបំពេញកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់ខ្លួន និងសូមផ្តល់នូវអនុសាសន៍ដូចខាងក្រោម៖

---

[156] ម.ស.ម.ក "កំណត់ត្រាសង្ខេបស្តីពីការបំពេញកតាព្វកិច្ចលើកិច្ចព្រមព្រៀទីក្រុងបារីសងរបស់កម្ពុជា, ៣០ឆ្នាំក្រោយមក"(ម.ស.ម.ក ២០២១)

| | |
|---|---|
| ១ | លុបចោលអនុក្រឹត្យស្ដីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ ឱ្យស្របតាមកាតព្វកិច្ចរបស់កម្ពុជាដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដើម្បីធានាថាសិទ្ធិខាងការបញ្ចេញមតិ និងសិទ្ធិទទួលព័ត៌មានរបស់បុគ្គលគ្រប់រូបត្រូវបានការពារនៅក្នុងប្រទេសកម្ពុជា។ |
| ២ | ធ្វើការពិគ្រោះយោបល់ប្រកបដោយបរិយាប័ន្ន និងស្របច្បាប់ជាមួយភាគីពាក់ព័ន្ធដោយមានចក្ខុវិស័យក្នុងការធ្វើវិសោធនកម្មច្បាប់ស្ដីពីការគ្រប់គ្រងប្រទេសជាតិក្នុងភាពអាសន្ន ដើម្បីឱ្យច្បាប់នេះអនុលោមតាមកាតព្វកិច្ចសិទ្ធិមនុស្សរបស់ខ្លួន។ |
| ៣ | ពិភាក្សាជាមួយភាគីពាក់ព័ន្ធលើសេចក្ដីព្រាងច្បាប់ស្ដីពីសិទ្ធិទទួលព័ត៌មាន ដើម្បីធានាថាសេចក្ដីព្រាងច្បាប់ចុងក្រោយស្របតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិពាក់ព័ន្ធនឹងការទទួលព័ត៌មាន ដើម្បីធានាថាសិទ្ធិទទួលព័ត៌មានត្រូវបានគោរពពេញលេញនៅកម្ពុជា និងអនុម័តឱ្យទាន់ពេលវេលា។ ស្រដៀងគ្នានេះដែរ សូមពិនិត្យមើលរាល់ច្បាប់ជាធរមានផ្សេងទៀត ដែលធ្វើឱ្យប៉ះពាល់ដល់នីត្យានុកូលភាពនៃសេរីភាពខាងការបញ្ចេញមតិ ដើម្បីនាំច្បាប់ទាំងនោះអនុលោមតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដូចជាច្បាប់ស្ដីពីរបបសារព័ត៌មាន ឬអនុក្រឹត្យថ្មីស្ដីពីការគ្រប់គ្រង និងការប្រើប្រាស់ឈ្មោះដែនជាតិ ជាដើម។ |
| ៤ | លុបចោលបទប្រមាថចំពោះអង្គព្រះមហាក្សត្រចេញពីក្រមព្រហ្មទណ្ឌ ដោយសារតែមាត្រានេះបង្កើតជាផ្នែកមួយនៃការរឹតត្បិតដែលមិនអាចអនុញ្ញាតបានចំពោះសេរីភាពខាងការបញ្ចេញមតិ ស្របតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ និងប៉ះពាល់ដល់សេរីភាពខាងការបញ្ចេញមតិ និងសេរីភាពសារព័ត៌មាន។ |
| ៥ | បញ្ឈប់រាល់ការយាយីតាមប្រព័ន្ធតុលាការលើអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស ដោយសារការអនុវត្តសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន និងធានានូវបរិយាកាសអំណោយផល ដែលអាចអនុវត្តសកម្មភាពស្របច្បាប់ ដោយសេរី ដោយគ្មានការភ័យខ្លាច ឬឧបសគ្គ ការរារាំង ឬការយាយីតាមប្រព័ន្ធតុលាការ និងការយាយីតាមរូបភាពផ្សេងៗទៀត។ |
| ៦ | ដោះលែងជាបន្ទាន់នូវអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្សទាំងអស់ដែលកំពុងជាប់ពន្ធនាគារដោយសារតែការអនុវត្តសេរីភាពខាងការបញ្ចេញមតិ និងទម្លាក់ការចោទប្រកាន់ដែលមាន ដូចជាសកម្មជនបរិស្ថានមាតាធម្មជាតិកម្ពុជាដែលត្រូវបានផ្ដន្ទាទោសនាពេលថ្មីៗនេះ ជាដើម។ |
| ៧ | ត្រូវធានាថា ការវាយប្រហារ និងបទល្មើសដែលប្រព្រឹត្តទៅលើអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស ត្រូវបានស៊ើបអង្កេតយ៉ាងច្បាស់លាស់ ហ្មត់ចត់ និងឯករាជ្យ ហើយជនល្មើសត្រូវបាននាំយកទៅកាត់ទោស ដើម្បីបញ្ឈប់និទណ្ឌភាពចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តលើអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស ដើម្បីឱ្យពួកគេធ្វើការដោយសុវត្ថិភាព។ |
| ៨ | ត្រូវបញ្ឈប់ការគំរាមកំហែង និងការបំភិតបំភ័យអ្នកសារព័ត៌មានដែលរាយការណ៍អំពីបញ្ហាទាំងឡាយដែលមានលក្ខណៈ «រសើប» ដូចជាការរាតត្បាតជំងឺកូវីដ-១៩ ជម្លោះដីធ្លី ឬអំពើពុករលួយជាដើម ដើម្បីធានាថាអ្នកសារព័ត៌មានអាចបំពេញតួនាទីដ៏សំខាន់របស់ខ្លួន ក្នុងការរាយការណ៍ដល់សាធារណជន |

| | |
|---|---|
| | លើបញ្ហាទាំងឡាយណាដែលពាក់ព័ន្ធនឹងផលប្រយោជន៍សាធារណៈ ដោយមិនគិតពីរបៀបដែលរដ្ឋាភិបាលយល់ឃើញបែបណានោះឡើយ។ |
| ៩ | លើកទឹកចិត្តប្រព័ន្ធផ្សព្វផ្សាយពហុនិយម និងចម្រុះបែបដោយការអនុញ្ញាតឱ្យប្រព័ន្ធផ្សព្វផ្សាយឯករាជ្យអាចស៊ើបអង្កេត និងរាយការណ៍រាល់បញ្ហាដែលមានសារៈសំខាន់សម្រាប់សាធារណជនដោយគ្មានការខ្លាចពីការតបតពីរដ្ឋាភិបាល បង្កើតបានជាទិដ្ឋភាពប្រព័ន្ធផ្សព្វផ្សាយបើកចំហមួយដែលអនុញ្ញាតឱ្យធ្វើការផ្សព្វផ្សាយ និងស្វែងរកបានដោយសេរី និងជាសាធារណៈ នូវទស្សនៈ និងគំនិតចម្រុះបែប។ |
| ១០ | លុបចោលលក្ខខណ្ឌដែលតម្រូវឱ្យស្ថាប័នសារព័ត៌មានត្រូវតែមានអាជ្ញាបណ្ណពីក្រសួងព័ត៌មាន មុននឹងអាចបោះពុម្ពផ្សាយ និងបង្កើតនូវស្ថាប័នគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យដាច់ដោយឡែកមួយពីរដ្ឋាភិបាល ដើម្បីធានាថាបទប្បញ្ញត្តិពាក់ព័ន្ធនឹងប្រព័ន្ធផ្សព្វផ្សាយ ត្រូវបានធ្វើឡើងដោយគោរពសេរីភាពសារព័ត៌មាន និងមិនលម្អៀងទាំងអស់។ |
| ១១ | ត្រូវធានាថាគ្រប់នាយកដ្ឋានរបស់រដ្ឋាភិបាល ស្ថាប័នសាធារណៈ និងស្ថាប័នឯកជនដែលមានមុខងារសាធារណៈទាំងអស់ប្រកាន់ខ្ជាប់នូវគោលការណ៍នៃការបង្ហាញព័ត៌មានជាអតិបរមា និងយល់ព្រមរាល់សំណើសុំឱ្យបង្ហាញព័ត៌មាន ជាពិសេសសំណើពីអ្នកសារព័ត៌មានស្នើសុំទិន្នន័យដែលគ្រប់គ្រងដោយរដ្ឋាភិបាល ដើម្បីឱ្យព័ត៌មានមានសារៈសំខាន់ចំពោះផលប្រយោជន៍សាធារណៈអាចផ្សព្វផ្សាយបានដោយសេរីនៅក្នុងប្រទេស និងបង្កើនតម្លាភាព និងគណនេយ្យភាពចំពោះសកម្មភាពរដ្ឋាភិបាល។ |
| ១២ | ត្រូវបោះជំហានដើម្បីលុបបំបាត់រាល់អាកប្បកិរិយារើសអើងចំពោះអ្នកសារព័ត៌មានជាស្ត្រី និងអ្នកការពារសិទ្ធិមនុស្សស្ត្រី និងអ្នកស្រឡាញ់ភេទដូចគ្នា តាមរយៈវគ្គបណ្តុះបណ្តាលស្តីពីការយល់ដឹងផ្នែកយេនឌ័រ និងយុទ្ធនាការអប់រំផ្សេងៗ ដើម្បីអាចអនុវត្តសេរីភាពខាងការបញ្ចេញមតិ និងធ្វើការងារស្របច្បាប់របស់ពួកគេចាកឆ្ងាយពីការរើសអើង។ |

## VII. ឧបសម្ព័ន្ធ

### កម្រងសំណួរសម្រាប់អ្នកសារព័ត៌មាន

១. តើអ្នកគិតថាអ្វីជាការគំរាមកំហែងធំបំផុតទៅលើសេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាននៅកម្ពុជានាពេលសព្វថ្ងៃនេះ?

២. តើអ្នកធ្លាប់ទទួលរងនូវការរឹតត្បិត/រំលោភបំពានលើសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិក្នុងនាមជាអ្នកសារព័ត៌មានពីសំណាក់រដ្ឋាភិបាល និង/ឬភាគីទីបីដែរឬទេ? បើអ្នកធ្លាប់ តើអ្នកបានដាក់ពាក្យបណ្តឹងដែរឬទេ? បើបានដាក់ពាក្យបណ្តឹង តើអ្នកទទួលការឆ្លើយតបចំពោះបណ្តឹងនោះដែរឬទេ?

៣. តើអ្នកមានអារម្មណ៍ថាអ្នកអាចធ្វើការងាររបស់អ្នកដោយសេរី និងដោយគ្មានការភ័យខ្លាចពីការតប ត ឬទេ?

៤. តើអ្នកបានធ្វើអ្វីខ្លះដើម្បីសម្របខ្លួនទៅនឹងបរិយាកាសដែលមានគ្រោះថ្នាក់កាន់តែធ្ងន់ធ្ងរឡើងៗសម្រាប់អ្នកសារព័ត៌មាន?

៥. តើអ្នកមានការលំបាកក្នុងការទទួលព័ត៌មានសម្រាប់អត្ថបទរបស់អ្នកទេ? បើមាន តើអ្នកអាចផ្តល់ឧទាហរណ៍ខ្លះបានដែរឬទេ?

៦. តើមានប្រធានបទណាខ្លះដែលអ្នកមិនសរសេរដែរឬទេ? បើមាន ហេតុអ្វី?

៧. តើអ្នកធ្លាប់ជួបផលវិបាកនៅពេលដែលអនុវត្តសេរីភាពខាងការបញ្ចេញមតិក្នុងនាមជាអ្នកសារព័ត៌មាន ដោយសារយេនឌ័ររបស់អ្នកដែរឬទេ? (សម្រាប់សម្ភាសន៍ជាមួយស្ត្រី)

### កម្រងសំណួរសម្រាប់អ្នកការពារសិទ្ធិមនុស្ស

១. តើអ្នកគិតថាអ្វីជាការគំរាមកំហែងធំបំផុតទៅលើសេរីភាពខាងការបញ្ចេញមតិនៅកម្ពុជានាពេលសព្វថ្ងៃនេះ?

២. តើអ្នកធ្លាប់ទទួលរងនូវការរឹតត្បិត/រំលោភបំពានលើសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិក្នុងនាមជាអ្នកការពារសិទ្ធិមនុស្សពីសំណាក់រដ្ឋាភិបាល និង/ឬភាគីទីបីដែរឬទេ? បើអ្នកធ្លាប់ តើអ្នកបានដាក់ពាក្យបណ្តឹងដែរឬទេ? បើបានដាក់ពាក្យបណ្តឹង តើអ្នកទទួលការឆ្លើយតបចំពោះបណ្តឹងនោះដែរឬទេ?

៣. តើអ្នកមានអារម្មណ៍ថាអ្នកអាចធ្វើការងាររបស់អ្នកដោយសេរី និងគ្មានការភ័យខ្លាចពីការតបតឬទេ?

៤. តើអ្នកបានធ្វើអ្វីខ្លះដើម្បីសម្របខ្លួនទៅនឹងបរិយាកាសដែលមានគ្រោះថ្នាក់កាន់តែធ្ងន់ធ្ងរឡើងៗសម្រាប់អ្នកការពារសិទ្ធិមនុស្ស?

៥. តើបញ្ហាសិទ្ធិមនុស្សណាខ្លះដែលអ្នកមិនធ្វើការតស៊ូមតិដែរឬទេ? បើមាន ហេតុអ្វី?

៦. តើអ្នកធ្លាប់ជួបផលវិបាកនៅពេលដែលអ្នកអនុវត្តសេរីភាពខាងការបញ្ចេញមតិក្នុងនាមជាអ្នកការពារសិទ្ធិមនុស្ស ដោយសារយេនឌ័ររបស់អ្នកដែរឬទេ? (សម្រាប់សម្ភាសន៍ជាមួយស្ត្រី)។

------